# ទឹក និង ប្រេង?
## ការសិក្សាអំពីព្រះពុទ្ធសាសនា និង លទ្ធិស្ត្រីនិយមនៅកម្ពុជា

ខែធ្នូ ឆ្នាំ២០២០

ក្លាហាន
klahaan
brave

ការស្រាវជ្រាវនេះទទួលបានការគាំទ្រមូលនិធិដ៏សប្បុរសពីម្ចាស់មូលនិធិរួមមាន៖  RFSU, DCA និង HBS។
ការបោះពុម្ពរបាយការណ៍នេះក៏បានទទួលការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។
ខ្លឹមសារទាំងស្រុងនៃរបាយការណ៍នេះជាការទទួលខុសត្រូវផ្ទាល់របស់អង្គការក្លាហាន និងមិនឆ្លុះបញ្ចាំងទស្សនៈរបស់សហភាពអឺរ៉ុបទេ។



# មាតិកា


១ សេចក្តីផ្តើម
១.១ គោលបំណងស្រាវជ្រាវ
១.២ សំណួរស្រាវជ្រាវ
១.៣ សេចក្តីសង្ខេបរបកគំហើញសំខាន់ៗ

២ វិធីសាស្រ្ត
២.១ គោលបំណងស្រាវជ្រាវ
២.២ សំណួរស្រាវជ្រាវ

៣ សមភាពយេនឌ័រមានជាប់មកជាមួយស្រាប់( ? )
៣.១ ទស្សនៈដកស្រង់ចេញពីឯកសារស្រាវជ្រាវ
៣.២ ទស្សនៈរបស់អ្នកតបសម្ភាស

៤ តួនាទីយេនឌ័រក្នុងស្ថាប័ន
៤.១ ទស្សនៈដកស្រង់ពីឯកសារស្រាវជ្រាវ
៤.២ ទស្សនៈរបស់អ្នកតបសម្ភាស

៥ អំពើហិង្សាផ្អែកលើយេនឌ័រ
៥.១ ទស្សនៈដកស្រង់ពីឯកសារស្រាវជ្រាវ
៥.២ ទស្សនៈរបស់អ្នកតបសម្ភាស

៦ សិទ្ធិផ្លូវភេទ/បន្តពូជ
៦.១ ទស្សនៈដកស្រង់ពីឯកសារស្រាវជ្រាវ
៦.២ ទស្សនៈរបស់អ្នកតបសម្ភាស

៧ ការឆ្លុះបញ្ចាំង &អនុសាសន៍
៧.១ វិថីឆ្ពោះទៅបង្កើនកិច្ចសហប្រតិបត្តិការ

៨ របកគំហើញសំខាន់ៗ & សេចក្តីសន្និដ្ឋាន
៨.១ សេចក្តីសង្ខេបរបកគំហើញ
៨.២ សន្និដ្ឋាន

# ការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម

សមាជិកក្រុមស្រាវជ្រាវរបស់អង្គការក្លាហាន

- បុណ្យ រចនា
- Kate Seewald
- ជិន ដាលីន
- វ៉ាន់លី កែវមុជា
- គង់ សុមណីជាតិ
- ហុង សុភ័ក្ត្រវឌ្ឍនៈ

សមាជិកក្រុមស្រាវជ្រាវប្រតិបត្តិស្នូល

- ឡុញ សុខជា
- កែវ វិថៃ
- សែន ស្រីនីន
- រួន ដាលីន
- ង៉ឹម វាស្នា
- ម៉ែន ចាន់ណាត
- ផន ស៊ីភាង


យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នាដែលបានចូលរួមនៅក្នុងគម្រោងសិក្សាស្រាវជ្រាវនេះ និង បានលះបង់នូវពេលវេលាដ៏មានតម្លៃរបស់ខ្លួនដោយសប្បុរសដើម្បីធ្វើឲ្យការស្រាវជ្រាវនេះប្រព្រឹត្តទៅបានដោយជោគជ័យ។ ក្នុងចំណោមអ្នកចូលរួមទាំងអស់រួមមាន ពុទ្ធបរិស័ទ គ្រហស្ថ រួមជាមួយនឹងបព្វជិតផ្នែកសាសនាដូចជា ព្រះសង្ឃ ព្រះសង្ឃជាន់ខ្ពស់ និង យាយជី/តាជី នៅក្នុងខេត្តបាត់ដំបង នឹងអ្នកឯកទេសផ្នែកសិទ្ធិស្ត្រីនៅក្នុងរាជធានីភ្នំពេញ។

អង្គការ ក្លាហាន សូមថ្លែងអំណរគុណនិងកោតសរសើរជាពិសេសដល់ក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋានដែលមានស្ត្រីវ័យក្មេងបីរូប និងព្រះសង្ឃបួនអង្គនៅក្នុងខេត្តបាត់ដំបង។ អ្នកស្រាវជ្រាវគ្រប់រូបបានលះបង់នូវពេលវេលាផ្ទាល់ខ្លួន ព្រមទាំងប្តេជ្ញាចិត្ត និងក្តីសោមនស្សដែលធ្វើឲ្យការស្រាវជ្រាវកាន់តែមានភាពប្រសើរខ្លាំង។

# សទ្ទានុក្រម

### អាចារ្យ

អាចារ្យជាគ្រហស្ថបុរសដែលមិនស្នាក់នៅក្នុងវត្តទេ ប៉ុន្តែដឹកនាំពុទ្ធសាសនិកជនក្នុងការរៀនសូត្រអំពីព្រះធម៌ និងអំពីរបៀបរៀបចំពិធីសាសនា។

### ដូនជី/យាយជី

សីលវតីដែលរស់នៅក្នុងវត្ត។ ដូនជីសំដៅទៅដល់ស្ត្រីដែលបដិបត្តិសីល១០ ចំណែកយាយជីសំដៅដល់ស្ត្រីដែលបដិបត្តិសីល៨។

### កម្ម

ជាកម្លាំងដែលកើតឡើងដោយទង្វើរបស់មនុស្សនៅក្នុងមួយជីវិតរបស់ខ្លួននិងជះឥទ្ធិពលទៅលើផលដែលកើតឡើងក្នុងអនាគតជាតិ។

### សិទ្ធិបន្តពូជ

ជាសិទ្ធិសម្រេចចិត្តអំពីចំនួនកូននិងគម្លាតក្នុងការមានកូន និងសិទ្ធិក្នុងការទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយដែលត្រូវការចាំបាច់ដើម្បីប្រើប្រាស់សិទ្ធិនេះ។

### ស្វ័យភាពផ្លូវភេទ

ជាសមត្ថភាពរបស់បុគ្គលក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី អំពីការចូលរួមនៅក្នុងទម្រង់ណាមួយនៃទំនាក់ទំនងស្និទ្ធស្នាលផ្លូវភេទ។ ផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី និងសមាជិកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា។

### តាជី

សីលវន្ត ដែលរស់នៅក្នុងវត្ត។

### ភិក្ខុនី

ព្រះសង្ឃស្រីដែលទទួលបានការបំបួសពេញលេញ។ ពូជពង្សខ្សែស្រឡាយនៃភិក្ខុនីក្នុងព្រះពុទ្ធសាសនាថេរវាទ ត្រូវបានសន្មត់ថាបានបញ្ចប់នៅក្នុងសតវត្សទី១៣ ប៉ុន្តែគេឃើញមានចលនាបំបួសភិក្ខុនីឡើងវិញនៅទីកន្លែងមួយចំនួនដូចនៅក្នុងប្រទេសថៃជាដើម។

### ស្ត្រីនិយមបែបអន្តរវិស័យ

ជាការវិភាគពេញលេញគ្រប់ជ្រុងជ្រោយដែលទទួលស្គាល់ថាឧបសគ្គរាំងក្នុងការទទួលបានសមភាពយេនឌ័រមានភាពខុសប្លែកគ្នាអាស្រ័យលើទិដ្ឋភាពផ្សេងៗនៃអត្តសញ្ញាណរបស់ស្ត្រី ដោយរួមបញ្ចូលទាំង អាយុ ពូជសាសន៍ និងវណ្ណៈ ហេតុដូច្នេះគឺជាក្របខណ្ឌនៃការវិភាគដើម្បីដោះស្រាយវិសាលគមបញ្ហាផ្សេងៗរបស់ស្ត្រី។

### សីលវន្ត

ជាពាក្យសម្រាប់អ្នកបដិបត្តិសាសនាព្រះពុទ្ធដែលរស់នៅក្នុងវត្ត (តាជី យាយជី និង ដូនជី)។

### សិទ្ធិផ្លូវភេទ

ជាសិទ្ធិមនុស្សដែលជាប់ទាក់ទងទៅនឹងរឿងរ៉ាវផ្លូវភេទ។ បើយោងទៅតាម IPPF សិទ្ធិផ្លូវភេទ គឺជាបណ្តុំនៃសិទ្ធិដែលផ្តល់ឲ្យនៅក្នុងច្បាប់សិទ្ធិមនុស្ស។ សិទ្ធិទាំងនេះរួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបាន សេរីភាព សមភាព ស្វ័យភាព សុចរិតភាព ឯកជនភាព និងសេចក្តីថ្លៃថ្នូរ។

### បទដ្ឋានសង្គមនិងវប្បធម៌

គឺជាវិធានឬការរំពឹងទុកនានា អំពីអាកប្បកិរិយា និងការគិតដោយផ្អែកទៅលើជំនឿរួមគ្នានៅក្នុងក្រុមសង្គមឬក្រុមវប្បធម៌ជាក់លាក់ណាមួយ។

### ពុទ្ធសាសនាថេរវាទ

គឺជានិកាយមួយនៃនិកាយទាំងបីនៅក្នុងព្រះពុទ្ធសាសនា។ ផ្តោតអាទិភាពក្នុងការទទួលបាននូវកុសលព្រមទាំងការធ្វើសមាធិ។ មានប្រជាប្រិយភាពបំផុតនៅក្នុងប្រទេសស្រីលង្កាល ថៃ ភូមា ឡាវ កម្ពុជា និងផ្នែកខ្លះនៃប្រទេសចិន (Aiken and Strand, ២០០៥)

# ១ សេចក្តីផ្តើម

ក្នុងបរិបទប្រទេសកម្ពុជាដែលដូចទៅនិងប្រទេសភាគច្រើនជុំវិញពិភពលោកដែរ វាហាក់ដូចជាមានភាពតានតឹងខ្លាំងរវាងគោលការណ៍សមភាពយេនឌ័រដែលកំពុងតែតស៊ូមតិដោយក្រុមស្រ្តី (ជាពិសេសទាក់ទងទៅនឹងស្វ័យភាពផ្លូវភេទនិងសិទ្ធិបន្តពូជរបស់ស្រ្តី) ជាមួយនិងគោលការណ៍ដែលទាក់ទង នឹងបទដ្ឋានយេនឌ័រ “បែបប្រពៃណី” តាមលក្ខណៈសាសនានិងវប្បធម៌។

ភាពតានតឹងដែលបានកើនឡើងនៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ បានបង្ហាញឲ្យឃើញកាន់តែច្បាស់ ជាក់ស្តែងគឺស្រ្តីតែងតែជួបការពិបាកក្នុងការទទួលបានការលែងលះ ទោះបីជាជារឿយៗពួកគេទទួលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារជាបន្តបន្ទាប់ក៏ដោយ[១]    នៅក្នុងការដែលរដ្ឋាភិបាលផ្អាកសកម្មភាពសម្តែងរបស់សិល្បៈករនិងសិល្បៈការិនីពីការងារដោយសារតែការស្លៀកពាក់របស់ពួកគេត្រូវបានចាត់ទុកថា “ស៊ិចស៊ីពេក” ដែលជាការប្រឆាំងនឹងវប្បធម៌ខ្មែរ[២] និង នៅមានបទដ្ឋានរស់នៅប្រចាំថ្ងៃផ្សេងទៀតដែលជារឿយៗដែលមិនសូវមានការចាប់អារម្មណ៍ ប៉ុន្តែមានភាពលម្អៀងទៅមនុស្សប្រុសនិងរើសអើងទៅលើស្រ្តី។ បទដ្ឋានទាំងអស់នេះបានពង្រឹងសុពលភាពនៃបទដ្ឋានយេនឌ័រដែលកំណត់តាមលក្ខណៈប្រពៃណីដែលកំណត់អំពីតួនាទីភាពជាអ្នកដឹកនាំនិងការត្រួតត្រាសម្រាប់បុរស និងកំណត់អំពីតួនាទីជាអ្នកថែទាំ ឬ តួនាទីតូចទាបស្ថិតក្រោមបង្គាប់របស់បុរសដល់ស្រ្តី។

ភាពរីកសាយភាយនៃបទដ្ឋានទាំងអស់នេះនៅតែជាបញ្ហាប្រឈមសម្រាប់ក្រុមអ្នកតស៊ូមតិផ្នែកសិទ្ធិស្រ្តីព្រោះវាជាឧបសគ្គរាំងដល់ការសម្រេចបានសមភាពនៃសិទ្ធិនិងទទួលបាននូវឱកាសរវាងបុរសនិងស្រ្តី (ព្រមទាំងក្រុមដែលមិនកំណត់អត្តសញ្ញានយេនឌ័ររបស់ខ្លួន)។ ការស្ទង់មតិថ្នាក់ជាតិមួយដែលធ្វើឡើងដោយអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៣ បានរកឃើញថាបុរសចំនួន៦៣% និងស្រ្តីចំនួន ៥៨% យល់ស្របថាបុរសគួរតែជាអ្នកមានសិទ្ធិសម្រេចចុងក្រោយទៅលើរាល់បញ្ហាទាំងអស់នៅក្នុងគ្រួសារ ខណៈដែលបុរស៨២% និងស្រ្តី៩៣% បានរាយការណ៍ថាពួកគេជឿថាតួនាទីសំខាន់បំផុតរបស់ស្រ្តីគឺការមើលថែទាំផ្ទះនិងចម្អិនម្ហូបអាហារសម្រាប់គ្រួសារ [៣]។

[១] អង្គការនារីដើម្បីសន្តិភាព និងអង្គការផ្សេងទៀត (២០២០)៖ រក្សាភាពសុខដុមរមនា ឬ រារាំងយុត្តិធម៌? អនឡាញ៖ <https://bit.ly/37gwsrL>.
[២] ស៊ុំ វុទ្ធី និងអ្នកផ្សេងទៀត, ‘តារាសម្តែងត្រូវបានហាមមិនឲ្យសម្តែងដោយសារការស្លៀកពាក់ស៊ិចស៊ី’, ភ្នំពេញប៉ុស្ដិ៍ (អនឡាញ, ថ្ងៃទី២៧ មេសា ២០១៧) <https://bit.ly/34g1qOZ>.
[៣] Emma Fulu et al, ហេតុអ្វីបានជាបុរសប្រើប្រាស់អំពើហិង្សាទៅលើស្រ្តី និងតើយើងអាចទប់ស្កាត់ដោយរបៀបណា? (ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣) <https://bit.ly/3qS9FdB>.

## ទិន្នន័យប្រជាសាស្ត្រនៃអ្នកកាន់សាសនាក្នុងប្រទេសកម្ពុជា




Source: US State Department, *International Religious Freedom Report for 2018*: *Cambodia*

ប្រជាជនកម្ពុជាប្រហែល៩៥% កំណត់ខ្លួនថាជាអ្នកកាន់ពុទ្ធសាសនាថេរវាទ[៤]។ តើបច្ចុប្បន្ននេះទំនាក់ទំនងរវាងព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមនៅក្នុងសង្គមកម្ពុជាមានលក្ខណៈដូចម្ដេច? តើប្រជាជនកម្ពុជាដែលមកពីសាវតារផ្សេងៗគ្នាយល់ឃើញថាព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមជាក្របខណ្ឌទស្សនៈដែលមានភាពប្រទាញប្រទង់ជាប់មកជាមួយកម្រិតណា? តើមនុស្សភាគច្រើនយល់ឃើញថាព្រះពុទ្ធ សាសនានិងលទ្ធិស្ត្រីនិយមមានលក្ខណៈពង្រឹងគ្នាទៅវិញទៅមកដែរឬទេ? តើគោលការណ៍ណាខ្លះដែលមានភាពប្រទាញប្រទង់គ្នាខ្លាំងបំផុតនោះ?

ការស្រាវជ្រាវនេះត្រូវបានសហការបង្កើតឡើងដោយសហគមន៍ផ្សេងៗគ្នាដែលមានបទពិសោធន៍ផ្ទាល់លើបញ្ហាជាប់ទាក់ទងទាំងនេះ (រួមមានស្ត្រីវ័យក្មេង និងព្រះសង្ឃ) និងមានបំណងផ្ដល់វិភាគទានដើម្បីរួមចំណែកទៅបង្កើនការយល់ដឹងឲ្យកាន់តែប្រសើរឡើងចំពោះបញ្ហាទាំងអស់នេះ។

## ១.១ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះមានពីរផ្នែក៖

១ **១.(វិ)សង្គតិភាពនៃលទ្ធិជំនឿ៖** ដើម្បីពិនិត្យមើលថាតើអ្នកបដិបត្តិ ព្រះពុទ្ធសាសនានិង/ឬលទ្ធិស្ត្រីនិយមយល់ឃើញថា ក្របខណ្ឌទស្សនៈទាំងនេះមានលក្ខណៈប្រទាញប្រទង់ ឬបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកដោយរបៀបណា។

២ **២.បុព្វហេតុរួម៖** ដើម្បីឈ្វេងយល់អំពីរបៀបដែលក្រុមបុគ្គលស្ត្រីនិយមអាចធ្វើការរួមគ្នាជាមួយនិងអ្នកបដិបត្តិឬបព្វជិតព្រះពុទ្ធសាសនាដើម្បីកែលម្អតវិយាបទចំពោះសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា។

[៤] ក្រសួងការបរទេសសហរដ្ឋអាមេរិច, នាយកដ្ឋានប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ, របាយការណ៍សេរីភាពសាសនាអន្តរជាតិឆ្នាំ២០១៨ សម្រាប់កម្ពុជា (របាយការណ៍, ២០១៨) ១, <https://bit.ly/37btHb8>.

## ១.២ សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះមានសំណួរគន្លឹះសំខាន់ៗចំនួន២និងមានសំណួរពាក់ព័ន្ធមួយចំនួន៖

១ តើមានផ្នែកសំខាន់ៗអ្វីខ្លះដែលស្របគ្នានិងមានភាពតានតឹងរវាងព្រះពុទ្ធសាសនា និងលទ្ធិស្រ្តីនិយម ហើយតើចំណុចទាំងអស់នោះស្តែងឡើងដូចម្តេចនៅក្នុងបរិបទសង្គមកម្ពុជា?

១.១ តើប្រជាពលរដ្ឋខ្មែរដែលបដិបត្តិតាមព្រះពុទ្ធសាសនាយល់និងបកស្រាយអំពីការបង្រៀនរបស់ព្រះពុទ្ធសាសនាយ៉ាងដូចម្តេចជាមួយនិងសមភាពយេនឌ័រនិងបញ្ហាជាប់ទាក់ទងផ្សេងៗទៀត?

១.២ តើក្រុមបុគ្គលស្រ្តីនិយមឈ្វេងយល់និងបកស្រាយអំពីការបង្រៀនបែបពុទ្ធសាសនាយ៉ាងដូចម្តេចខ្លះ? តើពួកគេបានសម្គាល់ឃើញចំណុចស្រប និង មានភាពតានតឹងអ្វីខ្លះ?

២ ចំពោះព្រះពុទ្ធសាសនាបែបស្រ្តីនិយមនិង/ឬស្រ្តីនិយមបែបពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា៖ តើអ្វីជាបញ្ហាប្រឈមនិងអ្វីជាឱកាសសំខាន់បំផុតសម្រាប់ការបង្កើនកិច្ចសហប្រតិបត្តិការ?

## ១.៣ សេចក្តីសង្ខេបអំពីរបកគំហើញសំខាន់ៗ

១ ហាក់បីដូចជាមានការបើកចំហច្រើនពីបព្វជិតសាសនាក្នុងការសហការណ៍ជាមួយអ្នកតស៊ូមតិផ្នែកយេនឌ័រដើម្បីកាត់បន្ថយអំពើហិង្សានៅក្នុងសហគមន៍ និងដើម្បីបង្រៀនប្រជាជនអំពីគោលការណ៍សមភាពយេនឌ័រដែលពួកគេជឿថាមានស្រាប់ក្នុងការអប់រំបែបព្រះពុទ្ធសាសនា។

២ ខណៈពេលដែលពុទ្ធបរិស័ទ្ធជាគ្រហស្ថជាច្រើន ដូចជាតាជីនិងយាយជី មានតួនាទីកំណត់ជាក់លាក់នោះ ព្រះសង្ឃមានដីកាថាតួនាទីទាំងអស់នេះមិនបានកំណត់ជាក់លាក់នោះទេ ហើយថា**ឧបសគ្គដែលរារាំងយាយជីមិនឲ្យធ្វើការងារសំខាន់ៗនោះ គឺដោយសារតែកត្តាវប្បធម៌ ជាជាងការកំណត់ក្នុងសាសនា**។ ចំណុចនេះជាការបង្ហាញនូវឱកាសក្នុងការលើកទឹកចិត្តដល់យាយជីឱ្យចាប់យកតួនាទីសំខាន់ៗបន្ថែមទៀតនៅក្នុងវត្តនិងសម្រាប់តាជីក្នុងការរួមចំណែកធ្វើការងារបោសសម្អាតនិងការងារចម្អិនអាហារ។

៣ អ្នកចូលរួមជាច្រើនមានអារម្មណ៍ថាបុគ្គលម្នាក់មានលទ្ធភាពមិនត្រឹមតែជាអ្នកជឿនិងតស៊ូមតិដើម្បីសមភាពយេនឌ័រខណៈកំពុងតែបដិបត្តិព្រះពុទ្ធសាសនានោះទេ ពួកគេថែមទាំងមានអារម្មណ៍ថា **ព្រះពុទ្ធសាសនាផ្ទាល់បានលើកកម្ពស់សមភាពយេនឌ័រស្រាប់ហើយ**។ អ្នកឆ្លើយតបច្រើនជាង ២/៣ (៦៨%) មានអារម្មណ៍ថាព្រះពុទ្ធសាសនាចាត់ទុកស្ត្រី និងបុរសមានភាពស្មើគ្នាពីកំណើត។

៤ ទិន្នន័យមិនឆ្លុះបញ្ចាំងការជំទាស់ផ្នែកមនោគមវិជ្ជាពីពុទ្ធបរិស័ទ្ធ ឬព្រះសង្ឃចំពោះគំនិតដែលថា**ស្ត្រីអាចបំបួសជាព្រះសង្ឃនោះទេ**។ ការពន្យល់អំពីការមិនអាចបំបួសស្ត្រីបាននោះគឺស្ថិតនៅត្រង់បញ្ហាបច្ចេកទេស (ការខ្វះខាតភិក្ខុនី ដើម្បីបំបួសភិក្ខុនីជំនាន់ក្រោយ) ព្រមទាំងបញ្ហាជាក់ស្តែង (ភិក្ខុនី និងភិក្ខុ មិនអាចស្នាក់នៅជិតគ្នាបានដើម្បីរក្សាភាពបរិសុទ្ធនៃចិត្ត និងការតមមិនរួមភេទ)។ អ្នកតបសម្ភាសនៅក្នុងការសិក្សានេះមិនបានសំដៅដល់គំនិតដែលថាស្ត្រីគ្មានភាពសក្តិសមពីកំណើតដើម្បីទទួលបានការបំបួសនៅក្នុងពុទ្ធសាសនានោះទេ។

៥ អ្នកតបសម្ភាសដែលជាបុគ្គលស្ត្រីនិយមទាំងអស់នៅក្នុងការស្រាវជ្រាវនេះបានបង្ហាញអំពីកម្រិតនៃភាពមិនស្រួលក្នុងចិត្ត ឬការមិនយល់ស្របមួយចំនួន ជាមួយនឹងការរឹតត្បិតយេនឌ័រក្នុងពេលបច្ចុប្បន្ននៅក្នុងស្ថាប័នសាសនា។ ក៏ប៉ុន្តែ បុគ្គលស្ត្រីនិយមដែលតបសម្ភាសភាគច្រើន (៥/៦) បានសម្តែងមតិថាពួកគេមានអារម្មណ៍ថាអាច**ប្រើពាក្យសម្គាល់ “អ្នកតស៊ូមតិផ្នែកយេនឌ័រ/ស្ត្រីនិយម” និង “ពុទ្ធសាសនិក” ក្នុងពេលជាមួយគ្នាតែមួយបាន**។

៦ ទោះបីជា**ការរំលូតកូនត្រូវបានយល់ឃើញស្ទើរតែជាឯកច្ឆន្ទថាជាទង្វើរដែលត្រូវបានហាមឃាត់នៅក្នុងពុទ្ធសាសនាក៏ដោយ**ក៏គំនិតអំពី “ការប្រព្រឹត្តមិនគប្បីផ្នែកផ្លូវភេទ” ហាក់បីដូចជាមានការប្រែប្រួលទៅតាមការបកស្រាយបែបជឿនលឿនមួយចំនួន។ ឧទាហរណ៍យោងតាមអ្នកចូលរួមជាគ្រហស្ថម្នាក់“ពុទ្ធសាសនាមិនអនុញ្ញាតឱ្យមានការបៀតបៀនផ្លូវភេទ ឬបង្កការឈឺចាប់ផ្លូវភេទទៅលើអ្នកដទៃឡើយ”។ ចំណុចនេះចង្អុលបង្ហាញថា **អាចមានបព្វជិតសាសនានិងបុគ្គលស្ត្រីនិយមធ្វើការរួមគ្នាទាក់ទងនឹងរឿងរ៉ាវផ្លូវភេទ**។

៧ ការយល់ឃើញអំពី**ការរួមភេទរវាងដៃគូដែលមិនទាន់រៀបការ** ហាក់មិនសូវរឹងត្អឹងដូចជារវាងដៃគូរដែលគ្មានភក្តីភាពចំពោះប្តីឬប្រពន្ធនោះទេ។ ចំណុចនេះអាចស្របជាមួយក្រុមអ្នកតស៊ូមតិសមភាពយេនឌ័រ នៅក្នុងការងារលើកកម្ពស់ស្វ័យភាពផ្លូវភេទរបស់ស្ត្រី។

៨ ទិន្នន័យដែលប្រមូលបានពីក្នុងការស្រាវជ្រាវនេះមិនត្រឹមតែបង្ហាញថា **គ្មានការរឹតត្បិត** ទៅលើការពន្យារកំណើតនៅក្នុងពុទ្ធសាសនាកម្ពុជានោះទេក្នុងនោះក៏មានអ្នកតបសម្ភាសជាព្រះសង្ឃ២អង្គថែមទាំងបានស្នើឡើងថា **ព្រះសង្ឃអាចមានតួនាទីសកម្មនៅក្នុងការអប់រំសហគមន៍អំពីវិធីសាស្រ្តរៀបចំផែនការគ្រួសារទៀតផង**។

៩ អ្នកតបសម្ភាសទាំងអស់**បានសម្តែងមតិគាំទ្រ ទៅលើការផ្សារភ្ជាប់ក្រុមអ្នកស្រលាញ់ភេទដូចគ្នាជាមួយនឹងព្រះពុទ្ធសាសនា**ទោះបីជាមួយចំនួនមានអារម្មណ៍ថាទង្វើផ្លូវភេទរវាងដៃគូប្រុសស្រលាញ់ប្រុសដូចគ្នាអាចជា “ទង្វើមិនគប្បីផ្នែកផ្លូវភេទ” តាមរយៈទស្សនៈពុទ្ធសាសនាក៏ដោយ។

១០ **អំពើហិង្សាលើស្ត្រីត្រូវបានមើលឃើញជាឯកច្ឆន្ទ**ក្នុងចំណោមអ្នកតបសម្ភាសទាំងអស់ថាជាការរំលោភបំពានទៅលើការបង្រៀនរបស់ពុទ្ធសាសនា។ ចំណុចនេះបង្ហាញនូវឱកាសដ៏មានសក្តានុពលមួយសម្រាប់អ្នកតស៊ូមតិផ្នែកយេនឌ័រ ក្នុងការដាក់បញ្ចូលទស្សនៈទាននៅក្នុងទស្សនៈអប់រំបែបព្រះពុទ្ធសាសនាដូចជាសិក្ខាបទផ្សេងៗដើម្បីធ្វើអន្តរាគមន៍បញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ។



# ២ វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះអនុវត្ត ការស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) នៅគ្រប់ដំណាក់កាលទាំងអស់ ចាប់តាំងពីការរៀបចំផែនការ និងសកម្មភាពស្រាវជ្រាវរហូតដល់បញ្ចប់។ យោងតាម APWLD ដែលបានផ្តួចផ្តើមឱ្យមានការស្រាវជ្រាវបែបនេះមុនគេនៅក្នុងតំបន់ FPAR គឺជាវិធីសាស្ត្រមួយនៃការអង្កេតស្រាវជ្រាវទៅលើបញ្ហាសង្គមដែលចូលរួមពាក់ព័ន្ធដោយផ្ទាល់ពីអ្នកដែលទទួលរងការគាបសង្កត់ និងប្រជាជនធម្មតានៅក្នុងការលើកឡើងអំពីបញ្ហា និងដំណោះស្រាយ។ វាគឺជា “វិធីមួយសម្រាប់អ្នកស្រាវជ្រាវ និងអ្នកចូលរួមបានចូលជាមួយគ្នាដោយសាមគ្គីភាពនៅក្នុងការចាត់វិធានការរួមគ្នាទាំងវិធានការរយៈពេលខ្លី និងរយៈពេលវែងដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម”[៥]។ FPAR ក៏បានបញ្ចូលទស្សនៈស្ត្រីនិយមនិងដំណើរការបែបស្ត្រីនិយមទាំងស្រុង ក៏ដូចជាការកសាងសមត្ថភាពនិងការចែករំលែកចំណេះដឹងផងដែរ។

## អ្នកតបសម្ភាស

| ប្រភេទអ្នកតបសម្ភាស | ចំនួន |
|---|---|
| ព្រះសង្ឃ | ១៦ |
| គ្រហស្ថ | ២៧ |
| យាយជី | ៨ |
| តាជី | ២ |
| អ្នកតស៊ូមតិផ្អែកយេនឌ័រ | ៦ |
| សរុប | ៥៩ |

ត្រង់ចំណុចនេះ ក្រុមអ្នកស្រាវជ្រាវសកម្មនៅកម្រិតមូលដ្ឋាន បានចូលរួមការសហការរៀបចំផែនការស្រាវជ្រាវនេះ។ ក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋាននេះ រួមមានយុវតីហ្វឹកហាត់ការងារពីរនាក់ នៅរាជធានីភ្នំពេញ (ស្ត្រីទាំងពីរ) និស្សិតស្ត្រីវ័យក្មេងបីនាក់មកពីខេត្តបាត់ដំបង និងព្រះសង្ឃបួនអង្គមកពីខេត្តបាត់ដំបង។ ក្រុមស្រាវជ្រាវនេះទទួលបានការបណ្តុះបណ្តាលអំពីគោលការណ៍ក្រមសីលធម៌ក្នុងការស្រាវជ្រាវ និងបច្ចេកទេសប្រមូលទិន្នន័យព្រមទាំងបានចូលរួមនៅក្នុងដំណើរការទាំងស្រុងនៃការសិក្សាស្រាវជ្រាវនេះ។ វិធីសាស្ត្របែបគុណវិស័យបានប្រើប្រាស់ការសម្ភាសនិងការពិភាក្សាក្រុម ការថតរូប និងការថតសម្លេង។ វិធីសាស្ត្រនេះអនុញ្ញាតឱ្យក្រុមស្រាវជ្រាវមានឱកាសសម្រាប់ការពិភាក្សាក្រៅផ្លូវការ និងរឹតចំណងទំនាក់ទំនង កាន់តែមានភាពស៊ីជម្រៅរវាងសមាជិកក្រុមស្រាវជ្រាវ។

សមាជិកក្រុមស្រាវជ្រាវសកម្មនៅកម្រិតមូលដ្ឋានបានចូលរួមយ៉ាងសកម្មនៅគ្រប់ដំណាកកាលទាំងអស់គឺមិនត្រឹមតែជាអ្នក “ប្រមូលទិន្នន័យ” ដែលគ្រាន់តែផ្តល់កម្រងសំណួរស្ទង់មតិ និងបញ្ជូនត្រឡប់មកវិញនោះទេ។ ការបណ្តុះបណ្តាលបែបអនុវត្តជាក់ស្តែងស្តីពីការវិភាគទិន្នន័យតាមប្រធានបទ ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ ហើយទិន្នន័យសម្ភាសត្រូវបានវិភាគនិងបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយផ្ទាល់ពីអ្នកស្រាវជ្រាវវ័យក្មេងទាំងនោះ។

[៥] វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពី ស្ត្រី, ច្បាប់ និងការអភិវឌ្ឍន៍ (APWLD), ‘ការស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR)’, *APWLD* <https://apwld.org/feminist-participatory-action-research-fpar/>.



# ៣ សមភាពយេនឌ័រមានជាប់មកជាមួយស្រាប់( ? )

## ទិដ្ឋភាពរួមនៃភាពស្របគ្នារវាងលទ្ធិស្ត្រីនិយម និងព្រះពុទ្ធសាសនា

## ៣.១ សមភាពយេនឌ័រមានជាប់មកជាមួយស្រាប់? ទស្សនៈចេញមកពីឯកសារស្រាវជ្រាវ

នៅពេលស្វែងរកវិធីក្នុងការដាក់ប្រភពឯកសារពុទ្ធសាសនានិងស្រ្តីនិយមនៅក្នុងការសន្ទនាដំបូងវាមានសារៈសំខាន់នៅក្នុងទទួលស្គាល់ថាទ្រឹស្តីព្រះពុទ្ធសាសនា ការបកស្រាយ និងការអនុវត្តនានាមានភាពខុសគ្នាសម្បើមណាស់។ ដូច Gayley បានលើកទឡ្ហីករណ៍ថាសូម្បីតែយើងបន្ថយពុទ្ធសាសនាឱ្យនៅត្រឹមតែការផ្តោតទៅលើអត្ថបទគម្ពីរ “...នៅតែមិនមានសង្គតិភាពទាំងស្រុងដែលយើងអាចចង្អុលបង្ហាញ “ថាជាពុទ្ធសាសនាពិតប្រាកដបាន"[៦]។

សម្រាប់ការស្រាវជ្រាវរបស់យើងការដែលពុទ្ធសាសនាស្ថិតនៅក្រោមការបកស្រាយផ្សេងៗគ្នាជាច្រើននោះគឺជាបញ្ហាប្រឈមមួយដែលធ្វើឱ្យកាន់តែមានការលំបាក ដោយសារតែគម្លាតខុសគ្នាខ្លាំងនៅក្នុងឯកសារដែលមានស្រាប់។ ដូចដែល Kanukollu និង Epstein-Ngo បានសរសេរថា “មានឯកសារស្រាវជ្រាវចំនួនតិចតួចណាស់ហើយពេលខ្លះមានសារដែលខ្វែងគំនិតគ្នាទៅលើប្រធានបទទាក់ទងនឹងយេនឌ័រ តួនាទីយេនឌ័រ និងអំពើហិង្សាយេនឌ័រនៅក្នុងពុទ្ធសាសនាផង” [៧]។

មានការសិក្សាស្រាវជ្រាវតិចតួចណាស់ ដែលពាក់ព័ន្ធជាពិសេសទៅដល់ពុទ្ធសាសនាថេរវាទ (ហើយជាពិសេសទៀតនោះ គឺពុទ្ធសាសនាថេរវាទដែលបដិបត្តិដោយប្រជាជនកម្ពុជាប្រហែល ៩៥% នាពេលបច្ចុប្បន្ននេះ) និងទំនាក់ទំនងប្រសព្វគ្នារវាងព្រះពុទ្ធសាសនាថេរវាទ និងលទ្ធិស្រ្តីនិយម។

ដូច្នេះ ឯកសារដែលមានស្រាប់ភាគច្រើនដែលដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះ ត្រូវបាន សរសេរឡើងដោយអ្នកប្រាជ្ញ ដែលធ្វើការសង្កេតទូលំទូលាយអំពីភាពស្របគ្នារវាងព្រះពុទ្ធសាសនា ជាមួយនឹងលទ្ធិស្រ្តីនិយមដោយបង្កើតជាទូទៅនីយកម្មនានា ដើម្បីគ្របដណ្តប់ទៅលើបរិបទភូមិសាស្រ្តផ្សេងគ្នា។

ដើម្បីជៀសវាងហានិភ័យនៃការប៉ាន់ប្រមាណលក្ខណៈចាំបាច់និយមឬការប៉ាន់ប្រមាណរាក់កំភែលនិងដើម្បីធានាថាការស្រាវជ្រាវនេះស្ថិតនៅក្នុងបរិបទប្រទេសកម្ពុជាពេញលេញនោះ យើងក៏បានបញ្ចូលការស្រាវជ្រាវជាក់លាក់អំពីប្រទេសកម្ពុជាតាមដែលអាចរកបានរួមជាមួយនឹងទិន្នន័យដែលប្រមូលមកពីការស្រាវជ្រាវនៅក្នុងអំឡុងពេលធ្វើការស្រាវជ្រាវវាលនៅក្នុងរាជធានីភ្នំពេញ និងខេត្តបាត់ដំបងក្នុងកំឡុងឆ្នាំ២០២០។ របកគំហើញពីទិន្នន័យដែលប្រមូលបានមាននៅក្នុងផ្នែកទី៣.២ ៤.២ ៥.២ និង ៦.២ នៃរបាយការណ៍នេះ។

[៦] Holly Gayley, ‘តើយើងស្វែងរកស្រ្តីនិយមតាមបែបពុទ្ធសាសនា នៅកន្លែងណា?’, (ខែកញ្ញា ឆ្នាំ២០១៦) ៣(១) The Arrow៖ ពុទ្ធសាសនានិងស្រ្តីនិយម ១៤
[៧] Shanta N Kanukollu and Quyen Epstein-Ngo, ‘អំពើហិង្សាលើស្រ្តី តាមរយៈទស្សនៈពុទ្ធសាសនា’ នៅក្នុង Andy J Johnson(ed), សាសនានិងអំពើហិង្សាបុរសទៅលើស្រ្តី (Springer Science Business Media New York, 2015) 343, 346.

## លទ្ធិស្ត្រីនិយមបែបអន្តរវិស័យគឺជា(ប្រភេទនៃលទ្ធិស្ត្រីនិយម) ប្រភេទដែលមានភាពស្របគ្នាច្រើនជាមួយនឹងអភិក្រម ព្រះពុទ្ធសាសនាក្នុងការដោះស្រាយទុក្ខនិងការឈឺចាប់។

SHOTWELL, ២០១៦

បន្ថែមលើភាពចាំបាច់ ក្នុងការទទួលស្គាល់អំពីទម្រង់ផ្សេងៗគ្នានៅក្នុងពុទ្ធសាសនានោះ យើងក៏គួរបញ្ជាក់ឱ្យច្បាស់អំពីទម្រង់ជាក់លាក់នៃលទ្ធិស្ត្រីនិយមដែលយើងកំពុងតែពិភាក្សាដែរ។ Shotwell បានបំបែកទ្រឹស្តីលទ្ធិស្ត្រីនិយមជាផ្នែកតូចៗ (ដូចជាលទ្ធិស្ត្រីនិយមបែបសេរី លទ្ធិស្ត្រីនិយមបែបជ្រុលនិយម និងលទ្ធិស្ត្រីនិយមបែបអន្តរវិស័យ) ព្រមទាំងប៉ាន់ប្រមាណអំពីភាពស្របគ្នានៃការបង្រៀនផ្នែកព្រះពុទ្ធសាសនានីមួយៗ។ ចុងក្រោយនាងបានរកឃើញថាលទ្ធិស្ត្រីនិយមបែបអន្តរវិស័យ "មានភាពស្របគ្នាបំផុតជាមួយនឹងវិធីសាស្ត្ររបស់ព្រះពុទ្ធសាសនាក្នុងការដោះស្រាយអំពីទុក្ខនិងការឈឺចាប់"[៨]។

ស្របជាមួយនឹងការវិភាគនេះនិងអភិក្រមផ្ទាល់របស់យើងចំពោះការអនុវត្តលទ្ធិស្ត្រីនិយម យើងនឹងពិនិត្យពិច័យទៅលើការបដិបត្តិព្រះពុទ្ធសាសនាថេរវាទ[៩] ដោយសារតែវាស្របគ្នាជាមួយនឹងស្ត្រីនិយមបែបអន្តរវិស័យ។ ស្ត្រីនិយមបែបអន្តរវិស័យគឺជាការវិភាគគ្រប់ជ្រុងជ្រោយមួយដែលទទួលស្គាល់ថាឧបសគ្គនានាក្នុងការទទួលបានសមភាពយេនឌ័រមានភាពខុសប្លែកគ្នា ដោយយោងទៅតាមទិដ្ឋភាពនានានៃអត្តសញ្ញាណដូចជា ភេទ ពូជសាសន៍ វណ្ណៈ ឬសាសនា[១០]។ វាដោះស្រាយទៅលើវិសាលគមទូលំទូលាយមួយនៃបញ្ហារបស់ស្ត្រីហើយមានលក្ខណៈបរិយាប័ន្នដោយគិតគូរដល់អ្នកផ្លាល់ប្តូរយេនឌ័រ ការប្តូរយេនឌ័រ អន្តរភេទ និងបុគ្គលដែលមិនកំណត់អត្តសញ្ញាណយេនឌ័រ។

របាយការណ៍នេះនឹងបង្ហាញតាមប្រធានបទពីមួយទៅមួយអំពី "ចំណុចប៉ះទង្គិច" សំខាន់ៗរវាងពុទ្ធសាសនាថេរវាទកម្ពុជានិងស្ត្រីនិយមអន្តរវិស័យ។ យើងចាប់ផ្តើមនៅក្នុងផ្នែកនេះជាមួយនឹងការប៉ាន់ប្រមាណលើសញ្ញាណដ៏ទូលំទូលាយមួយអំពីសមភាពយេនឌ័រនៅក្នុងទ្រឹស្តីនិងការអនុវត្តរបស់ព្រះពុទ្ធសាសនា។

ចំណុចចាប់ផ្តើមដ៏សមស្របមួយសម្រាប់ការប៉ាន់ប្រមាណបែបនេះគឺអាចតាមរយៈសំណួរដូចខាងក្រោម៖ តើស្ត្រីនិងបុរសត្រូវបានចាត់ទុកថាមានភាពស្មើគ្នាពីកំណើតដែរទេនៅក្នុងព្រះពុទ្ធសាសនា? ក្នុងការពិចារណាទៅលើការសង្កេតរបស់ Gayley ដែលថាព្រះពុទ្ធសាសនាមិនមានសង្គតិភាពទាំងមូលនោះយើងអាចហៅថា "មានការយល់ព្រមព្រៀងគ្នាតិចតួចណាស់នៅក្នុងប្រពៃណីនានាទាក់ទងទៅនឹងអ្វីដែលគេហៅថាជាអត្ថបទគម្ពីរគោលសាសនា (ត្រៃបិតក)"។ សំណួរនេះជាសំណួរពិបាកឆ្លើយ[១១]។

នៅក្នុងផ្នែកនេះយើងចាប់ផ្តើមដោយការពិនិត្យពិច័យទៅលើទស្សនៈរបស់អ្នកប្រាជ្ញនានាដែលលើកទឡ្ហីករណ៍ថាស្ត្រីនិយមនិងពុទ្ធសាសនាមានភាព "សំយោគចូលគ្នា" នៅក្នុងវិសាលភាពដ៏ទូលំទូលាយមួយមុនពេលដែលយើងបន្តទៅពិនិត្យលើអ្នកប្រាជ្ញមួយចំនួនផ្សេងទៀតដែលធ្វើការព្រមានថាប្រសិនបើមិនបញ្ចូលការបកស្រាយពុទ្ធសាសនាតាមបែបមូលដ្ឋាននីយកម្ម (ឧទាហរណ៍តាមប្រទេសជាក់លាក់) ទេនោះ ការអះអាងទូទៅពេកអំពីភាពស៊ីគ្នានេះអាចមានហានិភ័យក្នុងការបង្កើតការសន្មតជាទូទៅនីយកម្មដែលមិនមានហេតុផលគ្រប់គ្រាន់នៅក្នុងពិភពជាក់ស្តែង។

[8] Alexis Shotwell, 'បើមានពុទ្ធសាសនា នោះនឹងមានស្ត្រីនិយម, ប៉ុន្តែ តើស្ត្រីនិយមប្រភេទអ្វី?', (ខែកញ្ញា ឆ្នាំ២០១៦) ៣(១) The Arrow៖ ពុទ្ធសាសនានិងស្ត្រីនិយម ៤, ១២
[9] Dictionary.com (អនឡាញ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០) 'ស្ត្រីនិយមអន្តរជាតិ' (និយមន័យ ១), <https://bit.ly/3oVAdJn>.
[10] ជាទូទៅ គេកំណត់ថា ពុទ្ធសាសនិក ស្ថិតនៅក្នុងនិកាយមួយនៃនិកាយទាំងបី រួមមាន ថេរវាទ ("ការបង្រៀនរបស់ចាស់ទុំ"), មហាយាន ("យានធំ") និង វជរយាន "យានពេជ្រចរណៃ")។ នៅក្នុងនិកាយនេះ តួនាទីសាសនិក គឺដើម្បីទទួលបានកុសលកម្មឬកុសលបុណ្យ តាមរយៈការគាំទ្រតួនាទីមេដឹកនាំសាសនា តាមរយៈការបរិច្ចាគ ជាហិរញ្ញវត្ថុឬជាអ្វីផ្សេងទៀត។ ពុទ្ធសាសនាថេរវាទ មានប្រជាប្រិយភាពបំផុតក្នុងប្រទេសស្រីលង្កា ប្រទេសថៃ ប្រទេសភូមា ប្រទេសឡាវ ប្រទេសកម្ពុជា និងតំបន់ខ្លះនៃប្រទេសចិន។ (Aiken and Strand, 2005).
[11] Gayley, (n 6).



# 'ការចាក់ទឹកទៅក្នុងទឹក...'

## ទស្សនៈអះអាងថាមនោគមវិជ្ជាផ្នែកលទ្ធិស្ត្រីនិយម និងព្រះពុទ្ធសាសនាមានលក្ខណៈស្របគ្នាឥតខ្ចោះ

**សម្រាប់អ្នកប្រាជ្ញមួយចំនួនព្រះពុទ្ធសាសនា និងលទ្ធិស្ត្រីនិយមមានសារៈសំខាន់ និងភាពស្របគ្នាច្រើន។** យោងទៅតាម Tsomo ព្រះពុទ្ធមាន "បានបញ្ជាក់យ៉ាងច្បាស់អំពីសក្តានុពលសម្រាប់ស្ត្រីក្នុងការសម្រេចបាននូវគោលដៅស្មារតីខ្ពស់បំផុតតាមរយៈការអះអាងថារាល់ភាវៈដែលមានញាណទាំងអស់មានសក្តានុពលស្មើគ្នាក្នុងការត្រាស់ដឹង"[១២]។

Tsomo បានពង្រីកតក្កភាពផ្នែកស្មារតីនេះទៅដល់ការវិភាគសង្គមដោយបានលើកទឡ្ហីករណ៍ថាការបង្រៀនព្រះពុទ្ធសាសនាមានវិសាលភាពជាលក្ខណៈបរិយាបន្ន ហេតុដូច្នេះហើយគួរតែអាចបង្កលក្ខណៈងាយស្រួលស្មើគ្នាសម្រាប់ស្ត្រីនិងបុរស។ សម្រាប់ Tsomo ចំណុចនេះជំរុញឱ្យមាន "វោហាស័ព្ទនៃសមភាពខាងស្មារតី" នៅក្នុងអត្ថបទព្រះពុទ្ធសាសនាថ្វីត្បិតតែស្ត្រីបន្តប្រឈមនឹងឧបសគ្គជាច្រើន ក្នុងកិច្ចខិតខំប្រែងដើម្បីទទួលបានការអប់រំផ្នែកពុទ្ធសាសនា និងការបំបួសពេញលេញនៅក្នុងកន្លែងជាច្រើនក៏ដោយ [១៣]។

អ្នកសិក្សាស្រាវជ្រាវផ្នែកស្ត្រីនិយមនិងជាអ្នកបូជាពុទ្ធសាសនាដ៏ល្បីល្បាញ Rita Gross បានអះអាងថាការច្របាច់បញ្ចូលគ្នារវាងពុទ្ធសាសនានិងស្ត្រីនិយមគឺដូចជា "ចាក់ទឹកចូលទៅក្នុងទឹក" មានន័យថាលទ្ធិពីរនេះអាចរលាយចូលគ្នាតែមួយដោយឥតខ្ចោះ។ កាន់តែសំខាន់ជាងនេះទៀតនោះ Gross បានលើកទឡ្ហីករណ៍ថាការប្តេជ្ញាចិត្តតាមគោលការណ៍ស្នូលរបស់ពុទ្ធសាសនា ក៏ជាការ ប្តេជ្ញាចិត្តមួយទៅក្នុងគោលការណ៍ស្នូលនៃស្ត្រីនិយមដែរ[១៤]។

Gross ធ្វើការពិភាក្សាអំពីចំណុចដែលព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមមានភាពដូចគ្នាសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ទាំងព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមប្រកាន់យកការពិតជាសំខាន់និងមានសមត្ថភាព "តបតចំពោះអ្វីដែលមិនមែនជាការពិត" ទោះជាតាមរូបភាពណាក៏ដោយ

[១២] Karma L Tsomo, ស្ត្រីពុទ្ធសាសនិកនិងយុត្តិធម៌សង្គមៈ ឧត្តមភាព ការប្រឈម និងសមិទ្ធផល (សាកលវិទ្យាល័យរដ្ឋញូយ៉ក, អាល់បានី, ២០០៤) ២។
[១៣] Tsomo (n 12) 2.
[១៤] In Shotwell (n 8) 4.

## ការប្ដេជ្ញាចិត្តចំពោះគោលការណ៍ស្នូលរបស់ពុទ្ធសាសនា ក៏ជាការប្ដេជ្ញាចិត្តចំពោះគោលការណ៍ស្នូលរបស់ស្ត្រីនិយមដែរ។

DR RITA GROSS

- ទាំងលទ្ធិស្ត្រីនិយមនិងព្រះពុទ្ធសាសនាបានស្វែងរកមើលអំពីរបៀបដែលការកសាងផ្លូវចិត្តមានអំណាចនៅក្នុងការធ្វើឱ្យឧបសគ្គនៅតែបន្តកើតមានដល់ការរួចដោះ។ ក្នុងព្រះពុទ្ធសាសនា អត្តទត្ថភាព និងនិន្នាការជាទម្លាប់ត្រូវបានពិនិត្យពិច័យ ខណៈដែលក្នុងស្ត្រីនិយមលក្ខខណ្ឌសង្គម និងតួនាទីយេនឌ័រតាមបែបប្រពៃណីត្រូវបានធ្វើការពិនិត្យពិច័យ។
- លទ្ធិស្ត្រីនិយមនិងព្រះពុទ្ធសាសនាមានគំនិតស្រដៀងគ្នាអំពីការរួចរំដោះចំពោះស្ថានភាពមួយចំនួន។ នៅក្នុងព្រះពុទ្ធសាសនាការរួចរំដោះត្រូវបានបញ្ញត្តិថាជាសេរីភាពចេញផុតពីពិភពលោកនេះ និងជាសេរីភាពចេញផុតពីទុក្ខវេទនាដែលមានជាប់មកជាមួយ។ លទ្ធិស្ត្រីនិយមមើលឃើញការរួចរំដោះជាសេរីភាពចេញផុតពីតួនាទីយេនឌ័រ ផ្នត់គំនិតយេនឌ័រ និងការគាបសង្កត់។

Shortwell បន្តអនុវត្តក្របខណ្ឌរបស់ Gross ដើម្បីបង្កើតគោលការណ៍លទ្ធិស្ត្រីនិយមដែលទទួលព័ត៌មានពីព្រះពុទ្ធសាសនា ហើយផ្ទុយមកវិញព្រះពុទ្ធសាសនាដែលទទួលព័ត៌មានពីលទ្ធិស្ត្រីនិយម។ គាត់បានលើកទឡ្ហីករណ៍ថាការណែនាំរបស់ព្រះពុទ្ធសាសនាក្នុងការប្រតិបត្តិសេចក្ដីករុណាក៏ត្រូវទាមទារឱ្យអ្នកបដិបត្តិជំនឿពិនិត្យពិច័យទៅលើ “ទុក្ខវេទនាដែលស្របគ្នាជាមួយនឹងបន្ទាត់យេនឌ័រ និងត្រូវធ្វើអ្វីដែលយើងអាចធ្វើបានដើម្បីកាត់បន្ថយទុក្ខវេទនានោះ”[១៥]។ ចុងក្រោយនាងបាននិយាយថាដើម្បី "ក្លាយជាពុទ្ធសាសនិកល្អ យើងគួរបដិបត្តិពុទ្ធសាសនាពិតប្រាកដ ដែលមានន័យថាគួរធ្វើជាបុគ្គលស្ត្រីនិយមដ៏ល្អដែរ”។

Kanukollu និង Quyen Epstein-Ngo ក៏បានលើកទឡ្ហីករណ៍ថា “លទ្ធិស្ត្រីនិយមមានភាពស្របគ្នាល្អនៅក្នុងក្របខណ្ឌព្រះពុទ្ធសាសនា”[១៦]។ ហើយចុងក្រោយ Howes បានលើកទឡ្ហីករណ៍ដែរថាលទ្ធិស្ត្រីនិយមបែបអន្តរវិស័យមានភាពស្របគ្នាជាមួយនិងអភិក្រមរបស់ព្រះពុទ្ធសាសនាក្នុងការដោះស្រាយទុក្ខវេទនា និងការឈឺចាប់៖

> អន្តរវិស័យភាពស្របគ្នាយ៉ាងរលូនជាមួយនឹងទស្សនៈ *[ពុទ្ធសាសនា]* ដែលថា ... ការធ្វើសកម្មភាពដើម្បីរំដោះទុក្ខវេទនាត្រូវមានសេចក្ដីល្អជាមូលដ្ឋាន ហើយថាសេចក្ដីករុណាគ្មានដែនកំណត់  មានន័យថាយើងត្រូវដោះស្រាយទុក្ខរបស់ភាវៈមានជីវិតទាំងអស់”*[១៧]*។

[១៥] Shotwell (n 8) 8.
[១៦ Kanukollu and Epstein-Ngo (n 8) 347.
[១៧] In Shotwell (n 8) 12.

## កុំប្រញាប់សន្និដ្ឋានពេក ...

### ទឡ្ហីករណ៍ដែលគាំទ្រដល់ការធ្វើបរិបទនីយកម្ម ជាជាងការធ្វើទូទៅនីយកម្ម

Gayley បានចាប់យកអភិក្រមមួយផ្សេងទៀតក្នុងការប៉ាន់ប្រមាណអំពីភាពស្របគ្នារវាងលទ្ធិស្រ្តីនិយម និងព្រះពុទ្ធសាសនា។ គាត់បានលើកទឡ្ហីករណ៍ថាពីព្រោះគ្មាន "គម្ពីរ" កំណត់ណាមួយអំពីអត្ថបទព្រះពុទ្ធសាសនានោះ គេមិនអាចចេះតែសន្មតដោយងាយៗថា “ពុទ្ធសាសនិកគឺជាបុគ្គលស្រ្តីនិយមនោះទេ” [១៨]។ Gayley ក៏បានព្រមានប្រឆាំងទៅនឹងការពឹងផ្អែកទាំងស្រុងទៅលើអត្ថបទលទ្ធិសាសនា ក្នុងការប៉ាន់ប្រមាណអំពីសមភាពយេនឌ័រ នៅក្នុងពុទ្ធសាសនាផងដែរ។

នេះដោយសារតែនៅពេលដែលប៉ុនប៉ងធ្វើការផ្តល់និយមន័យអំពីគោលការណ៍ “ខ្លឹម” នៃព្រះពុទ្ធសាសនា យើងត្រូវតែពិចារណាអំពីការបកស្រាយនិងបែបបទនៃការបដិបត្តិពុទ្ធសាសនា ដ៏ច្រើននៅក្នុងបរិបទផ្សេងៗគ្នា។ បើមិនដូច្នេះទេយើងប្រឈមហានិភ័យ “ក្នុងការកាត់បន្ថយភាពចម្រុះនៃទស្សនៈនិងសំឡេងនានារបស់ពុទ្ធសាសនិកជននៅក្នុងទ្វីបអាស៊ីឱ្យមកនៅត្រឹមតែជាពុទ្ធសាសនាដែលមានទម្រង់តែមួយ ឬមានសំឡេងតែមួយ... ដែលជាការកាត់ផ្តាច់ពីបរិបទនិងមិនមានលក្ខណៈប្រវត្តិសាស្រ្ត”[១៩]។ ទង្វើនេះមិនត្រឹមតែផ្ទុយនឹងអភិក្រមស្រ្តីនិយមនោះទេគឺវាថែមទាំង “ប្រឈមហានិភ័យក្នុងការបង្កើតឡើងវិញនូវកេរដំណែលអាណានិគមនិងបូព៌ានិយមនៃការផ្តល់អាទិភាពទៅលើពុទ្ធសាសនា ដែលផ្អែកទៅលើតែ អត្ថបទ" ជាការបដិបត្តិតាមទម្រង់ដើមជាងការបដិបត្តិនាពេលបច្ចុប្បន្ននៅក្នុងទ្វីបអាស៊ីទៀតផង[២០]។

Gayley ក៏បានរំលេចឡើងដែរថាសូម្បីតែនៅក្នុងអត្ថបទផ្ទាល់ក៏មានទស្សនៈផ្សេងៗគ្នាជាច្រើនត្រូវបានលើកឡើងមកដែរដោយទស្សនៈមួយចំនួនមានការគាំទ្រទៅដល់គោលការណ៍ស្រ្តីនិយម ហើយទស្សនៈមួយចំនួនទៀតមិនមានការគាំទ្រទេ៖ “នៅក្នុងប្រភពឯកសារពុទ្ធសាសនាដំបូងមានឥរិយាបទជាច្រើនដែលបានសម្តែងឡើងទាក់ទងនឹងស្រ្តីរាប់តាំងពីការដាក់បញ្ចូលយ៉ាងច្បាស់ទៅក្នុងគម្រោងនៃការរំដោះឱ្យមានសេរីភាព រហូតដល់ការផាត់ស្រ្តីចេញពីការទទួលបានឱកាសតាមទស្សនៈដែលបង្ហាញភាពស្អប់ខ្ពើមទៅលើស្រ្តី”[២១]។

Simmer-Brown ក៏បានយល់ស្របថា មិនមានពុទ្ធសាសនាតែមួយទម្រង់នោះទេ ដូច្នេះហើយធាតុខ្លឹមចាំបាច់របស់ពុទ្ធសាសនាមិនអាចត្រូវបានគេរកឃើញឬធ្វើជាទូទៅនីយកម្មបានទេ។ ក្នុងការធ្វើដូច្នេះ Simmer បានលើកទឡ្ហីករណ៍ដែល “អះអាងអំពីបុព្វសិទ្ធិមួយដែលចេញមកពីទស្សនៈរបស់ពុទ្ធសាសនាបស្ចឹមប្រទេសរបស់ជនជាតិស្បែកស និងមានជីវភាពថ្នាក់កណ្តាល ដែលមិនផ្តល់ការគោរព និងមិនផ្តល់ភាពអង់អាចដល់ពុទ្ធសាសនាជាច្រើននៅជុំវិញពិភពលោក”[២២]។

[១៨] Gayley (n 6) 14.
[១៩] Gayley (n 6) 15.
[២០] Gayley (n 6) 15.
[២១] Gayley (n 6) 15.
[២២] Judith S Brown, ‘ទឹកអ្វី? ស្រ្តីនិយម, ពុទ្ធសាសនា Shambhala និងគោលការណ៍ស្រ្តីនិយម’ (២០១៦) ៣(១) *The arrow*: ពុទ្ធសាសនានិងស្រ្តីនិយម ២២, ២៣។




ដើម្បីឈ្វេងយល់អំពីវិសមភាពក្នុងពុទ្ធសាសនា ចាំបាច់ត្រូវពិនិត្យពិច័យ មិនត្រឹមតែទៅលើអត្ថបទ និងរចនាសម្ព័ន្ធរបស់ស្ថាប័នពុទ្ធសាសនាទេ ប៉ុន្តែថែមទាំងត្រូវមើលទៅលើឥរិយាបទ និងបែបផែននៃសង្គមនីយកម្មដែលបានវិវត្តន៍នៅក្នុងស្ថាប័នទាំងនេះដែរ។

TSOMO, ២០០៥, ទំ. ៥

ខណៈដែល Gross និង Shortwell អាចនឹងយល់ត្រូវថាអាចមានការវេញត្របាញ់បញ្ចូលគ្នាតាមទ្រឹស្តីដែលអាចជាសក្តានុពលមួយរវាងលទ្ធិស្រ្តីនិយមនិងព្រះពុទ្ធសាសនានោះតាមរយៈការវិភាគរបស់ Gayley យើងក៏អាចមើលឃើញថាបញ្ហាដែលមានជាប់មកជាមួយទាំងនោះមានភាពស្មុគស្មាញច្រើននៅក្នុងការអនុវត្តជាក់ស្តែង។
ការដែលគ្រាន់តែនិយាយយ៉ាងសាមញ្ញថា “ពុទ្ធសាសនិកគឺជាបុគ្គលស្រ្តីនិយមនោះ” មិនទាន់ផ្តល់នូវការវិភាគស៊ីជម្រៅគ្រប់គ្រាន់ទៅលើអន្តរទំនាក់ទំនងរវាងមនោគមវិជ្ជាទាំងនេះនៅក្នុងបទពិសោធន៍ផ្ទាល់របស់ស្រ្តីនិងបុរសនៅក្នុងបរិបទជាក់លាក់មួយចំនួននោះទេ។ ដូច្នេះយើងត្រូវតែពិចារណាអំពីការបកស្រាយតាមតំបន់ (នៅក្នុងរណីនេះ គឺប្រទេសកម្ពុជា) អំពីពុទ្ធសាសនា។ ការបកស្រាយបែបនេះទទួលរងឥទ្ធិពលយ៉ាងខ្លាំងនិងត្រូវបានបកស្រាយដោយផ្អែកលើបទដ្ឋានវប្បធម៌ ជាពិសេសការយល់ឃើញអំពីយេនឌ័រនៅក្នុងសង្គមខ្មែរ [២៣]។

តួនាទីយេនឌ័រក្នុងប្រទេសកម្ពុជាមានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងតួនាទីយេនឌ័រក្នុងប្រទេសថៃ។ ក្នុងន័យនេះគឺថាតួនាទីទាំងនោះត្រូវបាន “ចាក់ពុម្ពដោយឋានានុក្រមនៃក្រឹតក្រមសង្គមដែលដើរតួនាទីយ៉ាងធំនៅក្នុងរចនាសម្ព័ន្ធគ្រួសារ ទម្លាប់ និងទំនាក់ទំនងសង្គមតាំងពីវ័យកុមារមក”[២៤]។ ក្រឹតក្រមសង្គមទាំងនេះទទួលបានមកពីពុទ្ធសាសនាថេរវាទប៉ុន្តែក៏ពុំមែនទាំងស្រុងដែរដូចដែលបានបកស្រាយនៅក្នុងបរិបទប្រទេសកម្ពុជាទេ។
ឧទាហរណ៍ Kent បានសរសេរថាច្បាប់ស្រីរបស់ប្រទេសកម្ពុជានៅសតវត្សទី១៤ និពន្ធដោយព្រះសង្ឃខ្មែរ និងរៀបរាប់បង្ហាញអំពីស្រ្តីខ្មែរល្អឥតខ្ចោះជាស្រ្តីមានគុណធម៌ និងលះបង់ខ្លួនដើម្បីសុខុមាលភាពរបស់គ្រួសារឬសង្គម”[២៥]។ គុណធម៌របស់ស្រ្តីកម្ពុជាជាពិសេសទាក់ទងនឹងរឿងរ៉ាវផ្លូវភេទនៅតែបន្តមានភាពសំខាន់ខ្លាំងសម្រាប់ឋានៈខ្លួនឯងផ្ទាល់និងឋានៈរបស់សាច់ញាតិជាបុរសរបស់នាងដែរ [២៧]។

ដូច្នេះយើងអាចឃើញថាឆ្លងតាមពេលវេលាកន្លងមក ព្រះពុទ្ធសាសនាបានជះឥទ្ធិពលទៅលើការបង្កើតវប្បធម៌និងសង្គមកម្ពុជាទំនើបហើយដែលក្នុងពេលបច្ចុប្បន្នបានជះឥទ្ធិពលទៅលើរបៀបដែលប្រជាជនកម្ពុជា បដិបត្តិសាសនាវិញ។ របៀបដែលសាសនានិងវប្បធម៌វេញត្របាញ់បញ្ចូលគ្នាយ៉ាងជិតស្និទ្ធនៅក្នុងប្រទេសកម្ពុជារហូតដល់ចំណុចមួយដែលមានភាពមិនច្បាស់លាស់ថាបញ្ចប់នៅកន្លែងណាហើយចាប់ផ្តើមនៅកន្លែងណានោះ នឹងត្រូវវិភាគនៅក្នុងអត្ថបទនេះទាំងមូល។

[២៣] Alexandra Kent, ‘ជ្រកក្រោមព្រះធម៌៖ ឆ្លុះបញ្ចាំងទៅលើយេនឌ័រ សន្តិសុខ និងសាសនា ក្នុងប្រទេសកម្ពុជា’ (២០១១) ៤២(២) ព្រឹត្តិប័ត្រស្រាវជ្រាវអាស៊ីអាគ្នេយ៍ ១៩៣។
[២៤] Areewan Klunklin and Jennifer Greenwood, ‘ពុទ្ធសាសនា, ឋានៈរបស់ស្រ្តីនិងការរីករាលដាលនៃជំងឺ/មេរោគអេដស៍ ក្នុងប្រទេសថៃ’ (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៦) ២៦(១) ការថែទាំសុខភាពសម្រាប់ស្រ្តីអន្តរជាតិ ៤៦។
[២៥] Kent (n 23) 197.
[២៦] Kent (n 23) 197.

# ៣.២ សមភាពយេនឌ័រមានជាប់មកជាមួយ(?) ទស្សនៈពីអ្នកតបសម្ភាស

ក្រោយពីពិនិត្យមើលការប៉ាន់ប្រមាណឯកសារស្រាវជ្រាវជាច្រើនអំពីរបៀបដែលគេមើលឃើញលទ្ធិស្ត្រីនិយមនិងព្រះពុទ្ធសាសនាអាចមានភាពស្របគ្នានោះ ឥឡូវនេះយើងអាចនិយាយបានដូចខាងក្រោម៖

> តើគោលការណ៍ព្រះពុទ្ធសាសនា និងលទ្ធិស្ត្រីនិយម **មានសមត្ថភាព**អាចសម្របចូលគ្នាកម្រឹតណាជាមួយនឹងគោលការណ៍ដែលមានលក្ខណៈ**ទូលំទូលាយ**នោះ?
>
> ### មានសមត្ថភាព
>
> បើដូច្នេះតើព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមអាចសម្របចូលគ្នាកម្រឹតណានៅក្នុងការបកស្រាយការអនុវត្ត និងការសង្កេតនៅក្នុងបរិបទជាក់លាក់ណាមួយនោះ?
>
> ### មិនចាំបាច់ទេ

យើងនឹងត្រឡប់ទៅពិនិត្យពិច័យទៅលើឥរិយាបទនិងការយល់ឃើញរបស់អ្នកបដិបត្តិពុទ្ធសាសនាខ្មែរប្រភេទផ្សេងៗគ្នាចំពោះគោលការណ៍លទ្ធិស្ត្រីនិយមស្តីពីសមភាពយេនឌ័រវិញ។ អ្នកចូលរួមត្រូវបានសាកសួរសំណួរមួយចំនួនឱ្យឆ្លុះបញ្ចាំងថាតើពួកគេមានអារម្មណ៍ថាព្រះពុទ្ធសាសនាចាត់ទុកសំណួរទាក់ទងជាមួយនឹងសមភាពយេនឌ័រយ៉ាងដូចម្តេចខ្លះ។

វាសំខាន់ណាស់ដែលយើងត្រូវកត់សម្គាល់ថាអ្វីដែលយើងកំពុងតែធ្វើការប៉ាន់ប្រមាណនេះ មិនមែនថាតើព្រះពុទ្ធសាសនាចាត់ទុកស្ត្រីស្មើភាពគ្នាឬមិនចាត់ទុកស្ត្រីថាមានភាពស្មើគ្នានោះទេ។ ផ្ទុយទៅវិញយើងចង់ដឹងថាតើអ្នកកាន់សាសនានិងអ្នកបដិបត្តិសាសនារាល់ថ្ងៃនេះមានទស្សនៈយល់ឃើញយ៉ាងដូចម្តេចខ្លះទៅលើចំណុចនេះ។ ដូច្នេះនេះគឺជាការសិក្សាអំពីទស្សនៈយល់ឃើញជាជាងការប៉ាន់ប្រមាណទៅលើទិន្នន័យដែលប្រមូលបានមកថា តើពុទ្ធសាសនា មានលក្ខណៈឆ្លើយតបទៅនិងយេនឌ័រតាមលក្ខណៈមនោគមវិជ្ជាដែរឬទេ។

**ការសង្ខេបសម្រាប់ផ្នែកនេះ៖** ផ្នែកនេះពិនិត្យពិច័យទៅលើទស្សនៈយល់ឃើញរបស់អ្នកតបសម្ភាសអំពីសមភាពយេនឌ័រក្នុងពុទ្ធសាសនានៅកម្ពុជា។ យើងអាចចាប់ផ្តើមដោយនិយាយថារបកគំហើញទាំងអស់នេះបានប្រាប់នូវរឿងរ៉ាវដែលមានលក្ខណៈស្មុគស្មាញមួយ៖ ទីមួយអ្នកចូលរួមជាច្រើនមានអារម្មណ៍ថាមនុស្សម្នាក់មិនត្រឹមតែអាចជឿនិងតស៊ូមតិដើម្បីសមភាពយេនឌ័ររវាងភេទទាំងពីរ ខណៈពេលដែលបដិបត្តិពុទ្ធសាសនានោះទេ ប៉ុន្តែព្រះពុទ្ធសាសនាផ្ទាល់ក៏បានលើកកម្ពស់សមភាពយេនឌ័រស្រាប់ទៅហើយ។ អ្នកខ្លះទៀតមានអារម្មណ៍ថាព្រះពុទ្ធសាសនាមានវិធានស្មុគស្មាញជាច្រើនដែលមានបញ្ហានិងមិនចាត់ទុកថាជាការរំដោះស្ត្រីឱ្យមានសេរីភាពនោះទេ។




តើអ្នកគិតថាលទ្ធិព្រះពុទ្ធសាសនាចាត់ទុកបុរស និងស្ត្រីមានភាពស្មើគ្នាដែរឬទេ ?

## តើពុទ្ធសាសនាចាត់ទុកស្ត្រី និងបុរសមានភាពស្មើគ្នាពីកំណើតដែរឬទេ ? ចម្លើយមានលក្ខណៈវិជ្ជមាន។

អ្នកតបសម្ភាសដែលបានរាយការណ៍អំពីការយល់ឃើញដែលថាព្រះពុទ្ធសាសនាលើកកម្ពស់សមភាពយេនឌ័រយ៉ាងសកម្មនោះមានទាំងអ្នកឆ្លើយតបដែលជាព្រះសង្ឃនាពេលបច្ចុប្បន្ននេះផងដែរ។ មូលហេតុដែលផ្តល់ដោយអ្នកតបសម្ភាសទាំងនេះផ្តោតជុំវិញគំនិតដូចដែលព្រះសង្ឃមួយអង្គមានដីកាថា៖ “ព្រះពុទ្ធសាសនាគាំទ្រស្ត្រីជាជាងរារាំងស្ត្រី។” ព្រះសង្ឃមួយអង្គទៀតមានដីកាថាព្រះពុទ្ធសាសនាលើកកម្ពស់សិទ្ធិស្ត្រី ហើយមិនផ្តល់ការរឹតត្បិតសេរីភាពបញ្ចេញមតិ ការអប់រំ ឬការជជែកវែកញែកនោះទេ។ ព្រះសង្ឃមួយអង្គទៀតបានចង្អុលទៅដល់ការដែលថាស្ត្រីអាចចូលរួមនៅក្នុងកិច្ចការសង្គមតាមរយៈព្រះពុទ្ធសាសនាដោយភាពវិជ្ជមានដូចជាតាមរយៈការធ្វើទាន ដើម្បីលើកជាទឡ្ហីករណ៍ថាស្ត្រីអាចទទួលបានចំណេះដឹងនិងព័ត៌មានដ៏មានតម្លៃតាមរយៈសាសនារបស់ខ្លួន។

គ្រហស្ថនិងបព្វជិតក្នុងសាសនាជាច្រើន (ព្រះសង្ឃ ព្រះសង្ឃជាន់ខ្ពស់ យាយជី និងតាជី [២៧]) ក៏បានលើកឡើងអំពីជំនឿរបស់ខ្លួនថាពុទ្ធសាសនាគឺសាសនាមួយដែលមានគោលការណ៍រឹងមាំអំពី **ការមិនរើសអើង** ហើយគោលការណ៍នេះយកមកអនុវត្តទាក់ទងជាមួយនឹងសមភាពយេនឌ័រដែរ។ ឧទាហរណ៍ ព្រះសង្ឃមួយអង្គមានដីកាថាព្រះអង្គមានអារម្មណ៍ថា “ពុទ្ធសាសនាអាចជួយសម្រេចបានសមភាពយេនឌ័រ នៅក្នុងសង្គមបានពីព្រោះមនុស្សគ្រប់គ្នាមានការទទួលខុសត្រូវដូចគ្នា។ ជនណាក៏អាចបដិបត្តិព្រះពុទ្ធសាសនានិងរួមចំណែកជួយដល់សង្គមដែរ។”

ស្រដៀងគ្នានេះដែរព្រះសង្ឃមួយអង្គទៀតមានដីកាថា “ព្រះពុទ្ធគាំទ្រសមភាពរវាងបុរសនិងស្ត្រីទៅលើរាល់បញ្ហាទាំងអស់ដូចជាការថែទាំគ្រួសារជាដើម” ខណៈអ្នកតបសម្ភាសជាគ្រហស្ថម្នាក់បាននិយាយថា “ខ្ញុំគិតថាការបង្រៀនរបស់ព្រះពុទ្ធសាសនាអាចជួយប្រទេសកម្ពុជាឱ្យសម្រេចបានសមភាពយេនឌ័រតាមរយៈការនាំមកនូវសន្តិភាពផ្លូវចិត្តដល់មនុស្សទាំងអស់គ្នានិងបង្រៀនមនុស្សទាំងអស់គ្នាកុំឱ្យរើសអើងគ្នាទៅវិញទៅមក។”

នៅក្នុងក្រុមដែលមានទស្សនៈវិជ្ជមានទាក់ទងនឹងសំណួរថាតើព្រះពុទ្ធសាសនាបានគាំទ្រដល់គោលការណ៍សមភាពយេនឌ័រនៅក្នុងលទ្ធិស្ត្រីនិយមដែរ ឬទេនោះមានអ្នកឆ្លើយតបដែលបានលើកឡើងថា ខណៈដែលព្រះពុទ្ធសាសនាមានសក្តានុពលជាកម្លាំងមួយដើម្បីសមភាពយេនឌ័រនោះ វាអាចពឹងផ្អែកទៅលើកត្តាមួយចំនួនផ្សេងទៀតដែរ។

[២៧] យាយជី និង តាជី បកប្រែជាភាសាអង់គ្លេសថា female nuns និង male nuns។

## “ពុទ្ធសាសនាផ្តល់ការគាំទ្រដល់ស្ត្រីជាជាងរារាំងស្ត្រី។”

អ្នកតបសម្ភាសជាព្រះសង្ឃ

ជាក់ស្តែងព្រះសង្ឃមួយអង្គមានដីកាថា៖ “ការបង្រៀនរបស់ពុទ្ធសាសនាអាចដឹកនាំឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រ ប៉ុន្តែវាក៏អាស្រ័យទៅលើអ្នកបង្រៀនដែលត្រូវមានចំណេះដឹងពេញលេញដែរ។” អ្នកតបសម្ភាសជាគ្រហស្ថម្នាក់ផ្សេងទៀតបានសង្កេតឃើញថាគោលការណ៍សមភាពយេនឌ័រតាមបែបសាសនានិងមេត្តាធម៌គឺមានប្រយោជន៍តែនៅទីណាដែលគេយកវាទៅអនុវត្តយ៉ាងសកម្មដោយខ្ជាប់ខ្ជួនប៉ុណ្ណោះ៖

> “ការបង្រៀនបែបព្រះពុទ្ធសាសនាលើកកម្ពស់សមភាពយេនឌ័រតាមរយៈការបង្រៀនថា ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នានិងថាដៃគូស្និតស្នាលគួរជួយគ្នាទៅវិញទៅមក។ ប៉ុន្តែនៅទីបញ្ចប់វាអាស្រ័យទៅលើការប្តេជ្ញាចិត្តរបស់បុគ្គលចំពោះព្រះពុទ្ធដែរ។”

អ្នកឆ្លើយតបជាច្រើនបានលើកឡើងថាមានការបែងចែកខុសគ្នារវាងពុទ្ធសាសនានិងវប្បធម៌ខ្មែរទាក់ទងនឹងការប្រព្រឹត្តទៅលើស្ត្រីនៅក្នុងសង្គមបច្ចុប្បន្ន។ ព្រះសង្ឃមួយអង្គមានដីកាថា “ការរើសអើងយេនឌ័រមិនមែនជាបញ្ហារបស់ពុទ្ធសាសនាទេវាគឺជាបញ្ហាសង្គម។”

ស្រដៀងគ្នានេះដែរ ព្រះសង្ឃមួយអង្គទៀតមានដីកាថា “ព្រះពុទ្ធបង្រៀនមនុស្សមិនឱ្យរើសអើងទៅលើអ្នកដទៃដោយសារតែឋានៈឡើយ គ្រប់គ្នាអាចរៀនសូត្រនិងធ្វើការដោយស្មើភាពគ្នា។ ព្រះពុទ្ធសាសនាមិនដែលចែងថាស្ត្រីត្រូវតែធ្វើការងារផ្ទះទេ តែផ្ទុយទៅវិញនោះគឺជាបទដ្ឋាននិង ទំនៀមទម្លាប់សង្គមដែលតម្រូវឱ្យធ្វើបែបនេះ។” បន្ថែមពីលើនេះទៀតអ្នកឆ្លើយតបជាគ្រហស្ថម្នាក់បានអះអាងថា “ការបង្រៀនពុទ្ធសាសនាជួយឲ្យមានសមភាពយេនឌ័រ១០០%។ ព្រះពុទ្ធសាសនាមិនបានដាក់កំហិតលើស្ត្រីទេ... គឺបទដ្ឋានសង្គមទេដែលបែងចែកតួនាទីយេនឌ័រ។ ប្រភពដើមនៃការបែងចែកនេះ គឺប្រហែលមកពីព្រហ្មញ្ញសាសនាដែលជះឥទ្ធិពលទៅលើសង្គមកម្ពុជាមុនពេលមានវត្តមានរបស់ពុទ្ធសាសនា។”

សំណួរអំពីសាសនានិងវប្បធម៌ទាំងអស់នេះព្រមទាំងខ្សែបន្ទាត់ចែកគ្នាមិនច្បាស់លាស់រវាងសាសនានិងវប្បធម៌នឹងត្រូវបានពិនិត្យវិភាគនៅក្នុងផ្នែកបន្តបន្ទាប់នីមួយៗនៃការស្រាវជ្រាវនេះ។ នេះគឺដោយសារតែចំណុចទាំងអស់នេះមានសារៈសំខាន់ខ្លាំងក្នុងការពិនិត្យពិច័យប្រកបដោយអត្ថន័យទៅក្នុងការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីពុទ្ធសាសនានៅក្នុងសង្គមបច្ចុប្បន្ន។

## តើពុទ្ធសាសនាចាត់ទុកបុរសនិងស្ត្រីមានភាពស្មើគ្នាពីកំណើតដែរឬទេ?
## ការឆ្លើយតប បែបអវិជ្ជមាន៖

ជាការសំខាន់ណាស់ក្នុងការសង្កត់ធ្ងន់ជាថ្មីម្តងទៀតថាអ្នកតបសម្ភាសភាគច្រើនដែលបានចូលរួមនៅក្នុងការសិក្សានេះ ពិតជាមានអារម្មណ៍ថាព្រះពុទ្ធសាសនាមានភាពស្របជាមួយនឹងសមភាពយេនឌ័រ ហើយថែមទាំងបានលើកកម្ពស់សមភាពយេនឌ័រ និងគោលការណ៍ស្ត្រីនិយមផ្សេងៗទៀតផង។

ក៏ប៉ុន្តែអ្នកតបសម្ភាសមួយចំនួនក៏បានសង្កេតឃើញដែរថាមានភាពតានតឹងមួយចំនួនរវាងមនោគមវិជ្ជាទាំងពីរនេះ។ ឧទាហរណ៍ព្រះសង្ឃមួយអង្គបញ្ជាក់ថា “អាត្មាគិតថាព្រះពុទ្ធសាសនាដាក់កំហិតទៅលើសិទ្ធិស្ត្រីដោយសារតែព្រះពុទ្ធសាសនាបានដាក់កំហិតទៅលើសកម្មភាពរបស់ស្ត្រីជាក់ស្តែងដូចជានៅក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងព្រះសង្ឃ។ ដូចគ្នានេះដែរពុទ្ធសាសនាបានរារាំងទៅលើរបៀបដែលស្ត្រីស្លៀកពាក់នៅវត្ត ហើយមិនអនុញ្ញាតឱ្យស្ត្រីនិយាយជាមួយព្រះសង្ឃជាលក្ខណៈឯកជនឆ្ងាយពីភ្នែករបស់មនុស្សដទៃទៀយ។” អ្នកតបសម្ភាសជាគ្រហស្ថម្នាក់បានលើកឡើងនូវចំណុចស្រដៀងគ្នានេះដែរហើយជាអ្វីដែលហៅថា “ការរឹតត្បិតយេនឌ័រ” ដូចជាមិនអនុញ្ញាតឲ្យស្ត្រីចូលទៅក្នុងវត្តក្នុងពេលមានឈាមរដូវជាដើម។

ខណៈដែលទស្សនៈទាំងអស់នោះប្រហែលជាមានការពិតក្នុងនោះវាជាការដែលគួរឱ្យកត់សម្គាល់ចំពោះការលើកជាទឡ្ហីករណ៍ថានេះមិនមែនស្នូលមនោគមវិជ្ជារបស់ព្រះពុទ្ធសាសនាដែលកំពុងតែពិភាក្សាជាការប្រឆាំងជាមួយនឹងសមភាពយេនឌ័រទេ។ ប៉ុន្តែផ្ទុយទៅវិញវាឆ្លុះបញ្ចាំងអំពីទស្សនៈយល់ឃើញអំពីទំនៀមទម្លាប់និងការអនុវត្តមួយចំនួននៅជុំវិញវត្តដែលមានទំនោរយេនឌ័រមួយដែលលម្អៀងទៅខាងបុរសជាង។ ទោះបីជាវាឆ្លុះបញ្ចាំងអំពីឥទ្ធិពលសង្គមពីខាងក្រៅទៅលើស្ថាប័នពុទ្ធសាសនា ឬថាតើវាបង្ហាញអំពីការធ្វើប៉ាន់ស្មានទុកជាមុនមួយទាក់ទងជាមួយនឹងការប្រកាន់ភេទដែលបានបណ្តុះនៅក្នុងខ្លួនមនុស្សនៅក្នុងសាសនានេះ ឬនៅចំណុចណាមួយនៅចន្លោះនោះក៏ដោយក៏វាជាសំណួរដ៏ស្មុគស្មាញមួយដែលត្រូវការធ្វើការស្រាវជ្រាវបន្ថែមទៀត។

គ្រហស្ថពីរនាក់បានលើកឡើងអំពីមន្ទិលសង្ស័យកាន់តែខ្លាំងអំពីភាពបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមករវាងមនោគមវិជ្ជាព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយម។ គ្រហស្ថទីមួយបានលើកឡើងថា “ការបង្រៀនបែបព្រះពុទ្ធសាសនាក្នុងពេលបច្ចុប្បន្ននេះមិនអាចជួយលើកកម្ពស់សមភាពយេនឌ័របានទេ ប៉ុន្តែវាអាចបណ្តុះចិត្តគំនិតបាន។” គ្រហស្ថម្នាក់ទៀតអះអាងថាតាមពិតទៅព្រះពុទ្ធមិនបានឱ្យបុរសនិងស្ត្រីស្មើគ្នានោះទេ៖ “ព្រះពុទ្ធបង្រៀនថាបុរសនិងស្ត្រីកើតមកមិនមានភាពស្មើគ្នាទេប៉ុន្តែបានផ្តល់តម្លៃស្មើគ្នានៅក្នុងការងារ។” នេះបង្ហាញថាពុទ្ធសាសនិកមួយចំនួនយល់ឃើញថាសាសនានេះមិនស្របជាមួយនឹងគំនិតអំពីសមភាពយេនឌ័រទេ។

## ការអនុវត្តពុទ្ធសាសនានាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាមានការលាយចូលគ្នាជាមួយវប្បធម៌តាមរបៀបមួយដែលសម្រួលដល់ផ្នត់គំនិតបិតាធិបតេយ្យ។ ហើយប្រការនេះធ្វើឲ្យមានការលំបាកណាស់សម្រាប់យើងជាបុគ្គលស្ត្រីនិយម ក្នុងការធ្វើការងារនេះ ជាពិសេសនៅពេលជំនះទៅនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាផ្លូវភេទ។

**អ្នកតបសម្ភាសជាអ្នកស្ត្រីនិយម**

បុគ្គលស្ត្រីនិយមជាជនជាតិកម្ពុជា[២៧] ក្នុងការសិក្សានេះក៏មានការយល់ឃើញខុសគ្នាទៅលើសំណួរថា តើពួកគេគិតថាពុទ្ធសាសនាក្រសោបយកគំនិតសមភាពយេនឌ័រមកជាប់ជាមួយនឹងសាសនានេះស្រាប់ឬក៏យ៉ាងណានោះនៅក្នុងនោះមានម្នាក់បានឆ្លើយថាៈ

> "តើព្រះពុទ្ធសាសនាប៉ះទង្គិចជាមួយនឹងស្ត្រីនិយមដែរឬទេ? ខ្ញុំគិតថាបញ្ហាមួយក្នុងនោះគឺការត្រួតត្រាទៅលើរាងកាយនិងការសម្រេចចិត្តរបស់យើង។ នេះគឺជាការប៉ះទង្គិចដ៏ធំមួយ។ ហើយជំនឿទាក់ទងទៅនឹងកម្មផលនៅពេលដែលអំពើហិង្សាក្នុងគ្រួសារកើតឡើងមកលើយើង។ តាមពិតទៅជារឿយៗមនុស្សនិយាយថាការកើតមកជាមនុស្សស្រីគឺជាផលនៃកម្មពីជាតិមុន។
>
> ដូច្នេះចំណុចនេះមានការប៉ះទង្គិចជាមួយនឹងលទ្ធិស្ត្រីនិយមពីព្រោះវាមិនឆ្លុះបញ្ចាំងពីសមភាពទេ។ ហើយការដែលមានអំណាចផ្ទាល់ខ្លួនការធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន។ អ្នកបានឃើញហើយនូវការប៉ះទង្គិចពិតប្រាកដមួយជាមួយនឹងលទ្ធិស្ត្រីនិយមនៅពេលដែលពុទ្ធសាសនាមានការរួមផ្សំជាមួយនឹងការអនុវត្តតាមបែបប្រពៃណីក្នុងស្រុក។ បញ្ញត្តិព្រះពុទ្ធសាសនានិងទំនៀមទម្លាប់ប្រពៃណីតែងផ្តល់តម្លៃយ៉ាងខ្លាំងឱ្យទៅបុរសនៅក្នុងសង្គមនេះ។"

អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយមម្នាក់ទៀតបានឆ្លើយស្រដៀងគ្នានេះដែរថាខណៈដែលការលើកឡើងអំពីឧទាហរណ៍បន្ថែមទៀតដូចជា ស្ត្រីមិនអាចឈរនៅក្បែរព្រះសង្ឃបានដោយសារតែស្ត្រីអាចនឹងធ្វើឲ្យមានភាពល្អក់កករទៅដល់ព្រះសង្ឃ។ អ្នកតបសម្ភាសមានអារម្មណ៍ថាចំណុចនេះបង្ហាញ "នូវវប្បធម៌បន្ទោសមនុស្សស្ត្រីនៅក្នុងពុទ្ធសាសនា។" និងថា "ស្ត្រីមិនគួរត្រូវបានគេបន្ទោសដោយសារតែអាកប្បកិរិយារបស់មនុស្សប្រុសឡើយ។"

ការយល់ខុសឆ្គងអំពីសេចក្តីប្រាថ្នានៅក្នុងពុទ្ធសាសនាក៏បានលើកឡើងដែរដោយអ្នកចូលរួមបានពន្យល់ថានៅពេលដែលគេជឿថា សេចក្តីប្រាថ្នារបស់មនុស្សប្រុសរួមមានគតិបណ្ឌិត និងការជួយអ្នកដទៃនោះគេនិយាយថាស្ត្រីមានសេចក្តីប្រាថ្នាចង់បានសម្រស់ស្អាតនិងប្តីល្អទៅវិញ។ ហើយក៏មានគំនិតទស្សនៈថាការក្លាយទៅជាព្រះសង្ឃមួយអង្គ ទោះជាក្នុងរយៈពេលខ្លីយ៉ាងណាក៏ដោយក៏ជននោះអាចសងគុណម្តាយបានដែរ។ ហើយដើម្បីសងគុណឪពុកបុគ្គលម្នាក់ត្រូវតែបានបំបួសពេញលេញ។ អ្នកចូលរួមម្នាក់ពន្យល់ថាសម្រាប់នាង ចំណុចនេះ "លើកកម្ពស់ភាពជាបុរសគួរដ៏ពិសពុល"។

រឿងជាតកសាសនានិងទេវកថាសាសនាក៏ទំនងជាឆ្លុះបញ្ចាំងអំពីជំនឿបែបបិតាធិបតេយ្យដែរ បើយោងទៅតាមអ្នកឆ្លើយតបជាអ្នកស្ត្រីនិយមជាច្រើន។ មានការលើកជាឧទាហរណ៍ដោយរួមបញ្ចូលទាំងរឿងដែលទាក់ទងជាមួយនឹងទេវៈបុរសដែលមានប្រពន្ធមួយម៉ឺននាក់នៅឋានសួគ៌ជាដើម។

[២៧] គួរកត់សម្គាល់ថា អ្នកចូលរួមម្នាក់ពេញចិត្តពាក្យ "អ្នកតស៊ូមតិយេនឌ័រ" ជាងពាក្យ ស្ត្រីនិយម។

ជាថ្មីម្តងទៀតការលើកឡើងអំពីបញ្ហានៃចំណុចដែលមានភាពមិនច្បាស់លាស់រវាងវប្បធម៌និងសាសនា អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយមម្នាក់បានលើកក្តីបារម្ភថាការអនុវត្តប្រពៃណីជាក់លាក់មួយចំនួននៅក្នុងប្រទេសកម្ពុជាដែលគេយល់ថាមានជាលក្ខណៈពុទ្ធសាសនានោះមានការប្រទាញប្រទង់ផ្ទុយនឹងគុណតម្លៃបែបស្ត្រីនិយម។ ឧទាហរណ៍ដូចជាការអនុវត្តបែបទ្រឹស្តីលោកធាតុនិយមទៅលើការដាក់ទណ្ឌកម្មឬការមិនអនុញ្ញាតឱ្យដៃគូបានរៀបអាពាហ៍ពិពាហ៍ដោយយោងតាមការបកស្រាយទៅលើថ្ងៃខែឆ្នាំកំណើតរបស់ពួកគេទៅវិញ។ ដូចដែលអ្នកតបសម្ភាសម្នាក់បានសង្ខេបថា៖

> ខ្ញុំគិតថាដោយសារតែពុទ្ធសាសនាមានសារៈសំខាន់មែនទែននៅក្នុងជីវិតរបស់ប្រជាជនកម្ពុជា អស់រយៈពេលជាច្រើនសតវត្សមកហើយនោះវាបានក្លាយទៅជាទំនៀមទម្លាប់មួយតាមរបៀបដែលការអនុវត្តបែបវប្បធម៌របស់យើង ទាំងអស់មានការវេញត្របាញ់ចូលគ្នាជាមួយនឹងគំនិតពុទ្ធសាសនា។ ដូច្នេះពុទ្ធសាសនានៅកម្ពុជាខុសប្លែកពីពុទ្ធសាសនាដែលអនុវត្តនៅកន្លែងផ្សេងទៀត។ ខ្ញុំគិតថាច្បាប់ស្រីមិនមែនជាពុទ្ធសាសនា “ពិតប្រាកដ” នោះទេ។ ហើយគ្រូទាយដែលមានអំណាចក្នុងការប្រាប់ស្ត្រីអំពីជោគវាសនារបស់ខ្លួន ហើយធ្វើឱ្យស្ត្រីមួយចំនួនទទួលរងការអាប់ឱនកិត្តិយសនោះ... តើនេះជាពុទ្ធសាសនាឬ? ខ្ញុំពិតជាមិនចូលចិត្តគំនិតបែបនេះទេ។
>
> ចំណុចនេះប៉ះពាល់ទៅលើស្ត្រីខ្លាំងជាងបុរស។ តាមលក្ខណៈប្រពៃណីដោយសារស្ត្រីគួរតែចុះញ៉មទៅនឹងគំនិតដែលថាស្ត្រីគួរធ្វើជាភរិយាល្អឥតខ្ចោះនិងនាំមកនូវភាពសុខដុមរមនា។ គំនិតទាំងអស់នេះបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំង។ ស្ត្រីមិនអាចគ្រប់គ្រងលើខ្លួនឯងបាន។ ការមានជំនឿមិនមែនជាបញ្ហានោះទេប៉ុន្តែនៅពេលដែលជំនឿនោះប៉ះពាល់ទៅលើសិទ្ធិរបស់អ្នកដទៃខ្ញុំមានអារម្មណ៍ថានោះមិនមែនជារឿងត្រឹមត្រូវទេ។

វាជាការសំខាន់ក្នុងការកត់សម្គាល់ថាអ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយមភាគច្រើន (៥ ក្នុងចំណោម ៦នាក់) ក៏បានលើកឡើងថានៅពេលវែកញែកពិភាក្សាអំពីបញ្ហាស្មុគស្មាញទាំងនោះ ពួកគេអាចនៅតែប្រើប្រាស់ពាក្យសម្គាល់ថា "អ្នកតស៊ូមតិយេនឌ័រ/ស្ត្រីនិយម” និងជាពុទ្ធសាសនិកក្នុងពេលដំណាលគ្នាបានដែរ៖

“លទ្ធិស្ត្រីនិយមរបស់ខ្ញុំមានភាពស្របគ្នាជាមួយនឹងពុទ្ធសាសនាតាមបែបវិជ្ជមាន។ យើងអាចបកស្រាយយ៉ាងសាមញ្ញថាភាពជាពុទ្ធសាសនិកគឺជាការលើកទឹកចិត្តឱ្យព្យាយាមធ្វើអំពើល្អសម្រាប់អ្នកដទៃ។ អ្វីៗវាអាស្រ័យទៅលើការបកស្រាយទាំងអស់។ ខ្ញុំគិតថាព្រះពុទ្ធសាសនាអាចធ្វើឲ្យប្រសើរនិងពង្រឹងការអនុវត្តលទ្ធិស្ត្រីនិយមតាមវិធីនេះបាន។

**អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយម**




## ការយល់ឃើញអំពីការដាក់បញ្ចូលអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងការបកស្រាយពុទ្ធសាសនានៅកម្ពុជា

ក្នុងចំណោមអ្នកចូលរួមទាំងអស់មានទស្សនៈយល់ឃើញខុសប្លែកគ្នាអំពីថាតើព្រះពុទ្ធសាសនាក្រសោបយកដោយបើកចំហទៅលើភាពពហុរូបនៃនិន្នាការផ្លូវភេទនិងឬអត្តសញ្ញាណយេនឌ័រដោយរបៀបណានោះ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលគឺថាមិនមានអ្នកតបសម្ភាសណាម្នាក់លើកឡើងអំពីទស្សនៈដែលថាអ្នកដែលស្រលាញ់ភេទដូចគ្នាត្រូវបានហាមឃាត់មិនឱ្យប្រតិបត្តិព្រះពុទ្ធសាសនានោះទេ។ មនុស្សជាច្រើនបានលើកឡើងអំពីទស្សនៈស្របជាមួយនឹងទស្សនៈថា “ព្រះពុទ្ធសាសនា មិនបានហាមឃាត់មនុស្សមិនឱ្យស្រលាញ់ភេទដូចគ្នានោះទេ” ពីព្រោះ “ពុទ្ធសាសនា ទាក់ទងនឹងសភាពនៃចិត្ត ហើយពុទ្ធសាសនាមិនមានការរើសអើងទេ ឱ្យតែពួកគេមានចេតនាល្អ។”

ក្នុងចំណោមព្រះសង្ឃគំនិតគាំទ្រក្នុងព្រះពុទ្ធសាសនាទៅលើសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ក៏ត្រូវបានលើកឡើងដែរថា៖ “ព្រះពុទ្ធសាសនាមិនបានរើសអើងទៅលើសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាទេគឺកត្តាសង្គមទេដែលដើរតួជាឧបសគ្គ។ ព្រះពុទ្ធសាសនាចាត់ទុកមនុស្សគ្រប់រូបស្មើភាពគ្នា។” ព្រះសង្ឃមួយអង្គបានផ្តល់ឧទាហរណ៍មួយជាក់ស្តែងថា “មនុស្សស្រលាញ់ភេទដូចគ្នាក៏អាចរៀនជាមួយព្រះសង្ឃដែរគឺមានម្នាក់នៅក្នុងវត្តរបស់អាត្មា។” ក៏ប៉ុន្តែព្រះសង្ឃមួយចំនួនបានលើកឡើងអំពីទស្សនៈ (ដែលមានបញ្ហាបើផ្អែកតាមទស្សនៈស្ត្រីនិយម) ថាការស្រលាញ់ភេទដូចគ្នាគឺជាលទ្ធផលនៃកម្មពារ៖ “ការបង្រៀនរបស់ព្រះពុទ្ធមិនរើសអើងប្រឆាំងនឹងអ្នកស្រលាញ់ភេទដូចគ្នានោះទេ ប៉ុន្តែពួកគេមិនអាចសម្រេចបាននូវសន្តិភាពទេពីព្រោះក្រុមនោះត្រូវបានចាត់ទុកថាមានកម្មពារមិនល្អ។”

ចំណុចដែលមិនសូវមានការរីកចម្រើនដែរនោះគឺអ្នកដែលនិយាយថាខណៈដែលពុទ្ធសាសនាគាំទ្រដល់អ្នកស្រលាញ់ភេទដូចគ្នាការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍រវាងភេទផ្ទុយគ្នាត្រូវចាត់ទុកជា “ទង្វើមិនគប្បីខាងផ្លូវភេទ” ដូច្នេះហើយត្រូវហាមឃាត់ដាច់ខាត។

មិនតែប៉ុណ្ណោះវាជាការសំខាន់គួរឱ្យកត់សម្គាល់មួយដែរថាអ្នកតបសម្ភាសភាគច្រើនដែលស្ថិតនៅក្នុងសាសនាបានលើកឡើងអំពីទស្សនៈដែលមានការគាំទ្រយ៉ាងទូលាយចំពោះការផ្សព្វភ្ជាប់អ្នកស្រលាញ់ភេទដូចគ្នាជាមួយព្រះពុទ្ធសាសនា។ ខណៈដែលធ្វើការឆ្លុះបញ្ចាំងទៅលើតែសំណាកតូចមួយនេះវាបង្ហាញអំពីវិស័យសំខាន់មួយសម្រាប់ធ្វើការស្រាវជ្រាវបន្ថែមទៀត៖ ប្រសិនបើអ្នកនៅក្នុងសាសនាភាគច្រើនពិតជាចាត់ទុកថាព្រះពុទ្ធបានដាក់បញ្ចូលសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាមែននោះ វាប្រហែលជាមានសក្តានុពលក្នុងការឱ្យពួកគេចូលរួមនៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីលើកកម្ពស់សិទ្ធអ្នកស្រលាញ់ភេទដូចគ្នា និងសិទ្ធិរបស់អ្នកផ្លាស់ប្តូរយេនឌ័រក្នុងប្រទេសកម្ពុជាដែរ។

> ពុទ្ធសាសនាផ្តល់តម្លៃដល់អ្នកស្រលាញ់ភេទដូចគ្នាដូចបុគ្គលផ្សេងទៀតដែរ។ ពុទ្ធសាសនាបង្រៀនមនុស្សមិនឱ្យស្អប់ ឬរើសអើងទៅលើអ្នកដទៃឡើយ។
>
> **អ្នកតបសម្ភាសជាព្រះសង្ឃ**



# ៤ តួនាទីយេនឌ័រ ក្នុងស្ថាប័ន

## តួនាទីនិងភាពជាតំណាងរបស់ស្ត្រីក្នុងស្ថាប័នព្រះពុទ្ធសាសនានៅកម្ពុជា

បន្ទាប់ពីបានពិនិត្យទៅលើទស្សនៈយល់ឃើញអំពីសមភាពយេនឌ័រក្នុងពុទ្ធសាសនា នៅក្នុងបរិបទប្រទេសកម្ពុជារួចមក ឥឡូវនេះយើងត្រឡប់មកពិនិត្យមើលទៅលើបញ្ហាជាក់លាក់មួយចំនួន។ បញ្ហាទីមួយក្នុងចំណោមបញ្ហាទាំងនេះគឺពាក់ព័ន្ធនឹងតួនាទីនិងភាពជាតំណាងរបស់ស្ត្រីនៅក្នុងស្ថាប័នព្រះពុទ្ធសាសនា។ ដូចនៅក្នុងផ្នែកមុនដែរ ដំបូងយើងពិនិត្យមើលជាសង្ខេបទៅលើការស្រាវជ្រាវបែបសិក្សាធិការដែលមានស្រាប់ មុនពេលយើងបន្តទៅពិនិត្យមើលភាពលម្អិតនៃរបកគំហើញនៃការស្រាវជ្រាវរបស់យើងដែលធ្វើនៅទីតាំងស្រាវជ្រាវ។

## ៤.១ តួនាទីយេនឌ័រនៅស្ថាប័ន៖ ទស្សនៈចេញពីការស្រាវជ្រាវដែលមានស្រាប់

ការស្រាវជ្រាវដែលមានស្រាប់ដែលអាចរកបាន បានពិភាក្សាអំពីតួនាទីនិងភាពជាតំណាងរបស់ស្ត្រីនៅក្នុងពុទ្ធសាសនាតាមរបៀបផ្សេងៗគ្នា។ ឯកសារមួយចំនួនលើកជាទឡ្ហីករណ៍ថាវាមិនមានប្រយោជន៍អ្វីដែលស្ត្រីត្រូវតស៊ូឱ្យបានភាពជាតំណាងស្មើគ្នានៅក្នុងស្ថាប័នពុទ្ធសាសនានោះទេដោយសារតែ (ដូចគ្នានឹងសាសនាដទៃៗទៀតភាគច្រើនជុំវិញពិភពលោកដែរ) សាសនាភាគច្រើនមាន "ការរៀបចំចងក្រងតាមលក្ខណៈជាឋានានុក្រមឱបក្រសោបនិងផ្តល់អំណាចមនុស្សប្រុស"[២៨]។

នៅក្នុងការប៉ាន់ប្រមាណអំពីឋានៈរបស់ស្ត្រីក្នុងស្ថាប័នព្រះពុទ្ធសាសនា តាមទស្សនៈលទ្ធិស្ត្រីនិយមវាជាការចំបាច់ដែលមិនត្រូវមើលស្រាលដល់ភាពជាភ្នាក់ងារនៃការសម្រេចចិត្តរបស់ស្ត្រីកម្ពុជាជាច្រើនដែលក្នុងការរស់នៅក្នុងស្ថាប័ននេះ។ ស្ត្រីទាំងនេះមានសិទ្ធិទទួលបាននូវភាពស្វ័យសម្រេចផ្ទាល់ខ្លួន ដូចដែលTsomoបានលើកទឡ្ហីករណ៍ថាទោះបីជាសីលវន្តមិនសូវទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នាជាមួយនិងព្រះសង្ឃនៅក្នុងវត្តអារាមក៏ដោយក៏ជីវិតនៅវត្តអារាមផ្តល់នូវអត្ថន័យពេញលេញនិងប្រយោជន៍សម្រាប់ស្ត្រីច្រើនរាប់មិនអស់។ វាផ្តល់ឲ្យស្ត្រីនូវ "ជម្រើសផ្សេងក្រៅតែពីការរៀបការនិងការបង្កើតកូន។ វាក៏បានផ្តល់នូវចំណេះដឹង ឯករាជ្យភាព ភាពកក់ក្តៅនៃសហគមន៍ ព្រមទាំងអត្ថប្រយោជន៍ផ្នែកស្មារតីនៃការអនុវត្តពុទ្ធសាសនាដូចជាការជម្រះចិត្ត តុល្យភាព សន្តិភាពក្នុងចិត្ត បញ្ញា និងមេត្តាធម៌"[២៩]។

នៅក្នុងអត្ថបទឆ្នាំ២០១១ Kent បានបញ្ជាក់សាជាថ្មីម្តងទៀតទៅលើគំនិតទាក់ទងនិងវត្តអារាមថាបានផ្តល់នូវទីពឹងអាស្រ័យជាសក្តានុពលមួយសម្រាប់ស្ត្រី "ជ្រកក្រោមព្រះធម៌"។ ស្ត្រីជាច្រើនដែលចូលរួមនៅក្នុងការសិក្សារបស់គាត់គឺជនរងគ្រោះពីការរំលោភបំពាននិងការព្រងើយកន្តើយ ហើយពួកគេបានរកឃើញនូវសេចក្តីរម្ងាប់អារម្មណ៍និងសន្តិភាពនៅក្នុងព្រះវិហារ[៣០]។

ទោះបីជាមានសក្តានុពលនៃការទទួលបានអត្ថប្រយោជន៍ និងទស្សនៈនៃការដែល ស្ត្រីអាចរំដោះខ្លួនឱ្យមានសេរីភាពដោយជីវិតរស់នៅតាមវត្តអារាមនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ការពិតនោះគឺនៅតែថាសីលវតីមានឋានៈទាបនៅក្នុងវត្តអារាម និង បំពេញការងារត្រឹមតែជាអ្នកដាំស្លនិងបោសសម្អាតសម្រាប់ព្រះសង្ឃទៅវិញ[៣១]។ ព្រះសង្ឃត្រូវបានចាត់ទុកថាមានភាពខ្ពង់ខ្ពស់និងមាន"បុណ្យ"ច្រើនជាង ហើយតម្រូវការរបស់ព្រះសង្ឃត្រូវបានផ្តល់អាទិភាពជាងតម្រូវការរបស់ស្ត្រី[៣២]។

[២៨] Tsomo (n 12) 6.
[២៩] Tsomo (n 12) 6.
[៣០] Kent (n 23).
[៣១] Klunklin & Greenwood (n 24).
[៣២] Tsomo (n 12) 15.
[៣៣] Emily Wight and Vandy Muong, 'នយោបាយយេនឌ័រនៅក្នុងវត្តអារាម៖ សំឡេងស្ត្រីអំពាវនាវឲ្យមានការផ្លាស់ប្តូរ', ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣) <https://bit.ly/3mv2NiS>.

នៅក្នុងព្រះពុទ្ធសាសនាថេរវាទ ព្រះសង្ឃសិក្សាអំពីសីលធម៌និងសមាធិក៏ដូចជាដឹកនាំសហគមន៍ក្នុងនាមជាគ្រូបង្រៀននិងជាអ្នកដឹកនាំផ្នែកស្មារតី[៣៣]។ សីលវន្តមិនត្រូវបានបំបួសទេហើយមានការបែងចែកទៅតាមយេនឌ័រដោយមានតាជីជាបុរសដែលជាអ្នកធ្វើធម៌រស់នៅក្នុងវត្ត។ សម្រាប់ស្ត្រីដែលបដិបត្តិសីល១០គឺជាដូនជី ហើយស្ត្រីដែលបដិបត្តិសីល០៨ គឺជាយាយជី[៣៤]។

ខណៈដែលការបំបួសស្ត្រីពេញលេញមិនត្រូវបានចាត់ទុកថាអាចធ្វើបាននៅក្នុង ព្រះពុទ្ធសាសនាថេរវាទក៏ដោយ[៣៥] ស្ថានភាពជាក់ស្តែងមិនមែនសុទ្ធតែបែបនេះនោះទេ។ ព្រះពុទ្ធអង្គបានផ្តល់ការបំបួសម្តាយមីងរបស់ព្រះអង្គគឺមហាប្រាជាបទីជាស្ត្រីទីមួយបន្ទាប់ពីព្រះនាងនិងក្រុមបរិវារបាននាំគ្នាកោរសក់និងស្លៀកស្បង់របស់ព្រះសង្ឃ និងទាមទារឱ្យមានសិទ្ធិក្នុងការបំបួសដោយស្មើភាពគ្នា[៣៦]។

ទោះបីជាព្រះពុទ្ធបានព្រមព្រៀងក៏ដោយក៏ការបំបួសស្ត្រីកើតឡើងដោយមានការរឹតត្បិតមួយចំនួន។ ភិក្ខុនីរស់នៅក្រោមការចាត់ចែងរបស់ភិក្ខុសង្ឃ។ រាល់ភិក្ខុនីទាំងអស់ទោះបីជាមានឋានៈជាន់ខ្ពស់យ៉ាងណាក៏ដោយក៏តម្រូវឱ្យគោរពព្រះសង្ឃដែរ ទោះបីជាព្រះសង្ឃដែលទើបតែបំបួសថ្មីៗក៏ដោយ។ Leeបានលើកទឡ្ហីករណ៍ថាវិធានបែបនេះបង្ហាញថា "ថ្វីត្បិតតែភាពសាកលជាប់មកជាមួយនៅក្នុងការបង្រៀនរបស់ព្រះពុទ្ធសាសនាក៏ដោយក៏ស្ត្រីនៅជួបបញ្ហាក្នុងការទទួលបានភាពស្មើគ្នាជាមួយបុរសនៅក្នុងពុទ្ធសាសនាតាំងពីសម័យដំបូងមកដែរ"[៣៧]។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ស្ត្រីជាច្រើននៅក្នុងសម័យនោះភាពជាសង្ឃតំណាងឱ្យការគេចចេញពីបិតាធិបតេយ្យបែបព្រហ្មញ្ញសាសនាដែលមានលក្ខណៈគាបសង្កត់នៅសម័យកាលនោះ។ ភិក្ខុនីក៏បានចៀសផុតពីការរៀបអាពាហ៍ពិពាហ៍ដែលរៀបចំដោយក្រុមគ្រួសារ ហើយអាចបន្តការអភិវឌ្ឍផ្លូវចិត្តរបស់ខ្លួនតាមរយៈការសិក្សានិងការសមាធិ[៣៨]។

ឆ្លងកាត់រយៈកាលកន្លងមកសង្ឃជាភិក្ខុនីបានបាត់ស្រមោលបន្តិចម្តងៗនៅក្នុងប្រពៃណីថេរវាទហើយប្រហែលជានៅក្នុងសតវត្សទី១៣ខ្សែស្រឡាយនេះបានដាច់ពូជទៅ។ ដូច្នេះមានការទទួលស្គាល់ជាទូទៅថាកាលៈទេសៈនាពេលបច្ចុប្បន្ននេះគេមិនអនុញ្ញាតឱ្យមានការបំបួសភិក្ខុនីទៀតទេពីព្រោះគ្មានវត្តមានភិក្ខុនីដែលអាចធ្វើពិធីបំបួសភិក្ខុនីបាន (ត្រូវការមានភិក្ខុនីប្រាំអង្គដើម្បីចូលរួមធ្វើពិធីបំបួសភិក្ខុនី១អង្គ)[៣៩]។

ក្នុងបរិបទកម្ពុជា Leeបានលើកទឡ្ហីករណ៍ថាឋានៈតូចទាបរបស់ស្ត្រីត្រូវបានកំណត់នៅក្នុងលំដាប់ថ្នាក់នៃឋានុក្រមនៃព្រះពុទ្ធសាសនាថេរវាទ៖ ព្រះសង្ឃជាន់ខ្ពស់មានឋានៈលើព្រះសង្ឃថ្នាក់ទាប បងប្អូនបង្កើតដែលអាយុច្រើនជាងមានឋានៈលើអ្នកដែលមានអាយុទាបជាងហើយប្តីមានឋានៈលើប្រពន្ធ។ ពិធីកម្មពុទ្ធសាសនាខ្មែរបានផ្តល់នូវឧទាហរណ៍ដែលអាចមើលឃើញអំពីតួនាទីរបស់ស្ត្រីដែលជាអ្នកនៅក្រោមបង្គាប់ នៅក្នុងពុទ្ធសាសនាថេរវាទ តាមរយៈបទពិសោធន៍នៃការបន់ស្រន់ថ្វាយបង្គំរបស់ស្ត្រី (សូម្បីតែដូនជី) ក៏ពួកគេអង្គុយទាបជាងនិងគោរពបុរសដែលគេដាក់ឲ្យអង្គុយខ្ពស់ជាង៤០]។

ប៉ុន្តែLeeក៏បានពន្យល់ដែរថា "ទោះបីជាស្ត្រីមានឋានៈទាបនៅក្នុងព្រះពុទ្ធសាសនាថេរវាទក្តីក៏មានវិធីជាច្រើនដែលស្ត្រីអាចសន្សំបុណ្យនិងធ្វើឱ្យមានការរីកចម្រើនទៅលើតម្លៃនៃស្មារតីនេះ" ដោយរួមបញ្ចូលទាំងភាពជាម្តាយ ការប្រគេនទេយ្យទាន និងការប្រគេនចង្ហាន់ព្រះសង្ឃ"[៤១]។

[៣៤] Wight and Muong (n ៣៣).
[៣៥] ប្រពៃណីភិក្ខុនី មិនស្លាប់បាត់បង់ទាំងស្រុងនោះទេនៅក្នុងពុទ្ធសាសនាថេរវាទ នៅពេលដែលទីវត្តអារាមក្រៅផ្លូវការមួយ ដំណើរការនៅក្នុងប្រទេសថៃ ក្រោមការគ្រប់គ្រងរបស់ព្រះតេជគុណធម្មនន្ទ ដែលទទួលការបំបួសក្នុងប្រទេសស្រីលង្កា (Wight & Muong, n 33).
[៣៦] Nathaniel Adams, 'ចលនាដ៏ស្ងប់ស្ងៀមក្នុងប្រទេសកម្ពុជា៖ ស្ត្រីពុទ្ធសាសនិក ក្នុងការអភិវឌ្ឍន៍', កិច្ចសន្ទនាដើម្បីការអភិវឌ្ឍសេចក្តីជំនឿពិភពលោក (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១១) <https://bit.ly/37rc1sr>.
[៣៧] Susan H Lee, 'វិសមភាពមុន្នោគមវិជ្ជា៖ វប្បធម៌ខ្មែរនិងការយល់ឃើញរបស់ស្ត្រីមេម៉ាយអំពីការរៀបការឡើងវិញ' (ខែឧសភា ឆ្នាំ២០១៨) ១៩(៥) យេនឌ័រ, ភាពក្រីក្រ និងវិសមភាព៖ ការស្រាវជ្រាវស្វែងយល់ពីទស្សនៈដែលមានការផ្លាស់ប្តូរទាំងស្រុង នៃព្រឹត្តិបត្រស្រាវជ្រាវស្ត្រីអន្តរជាតិ ២៩, ទំ.៣៣-៣៤។
[៣៨38] Adams (n ៣៦).
[៣៩] Adams (n ៣៦).
[៤០] Lee (n ៤២) ៣៦.
[៤១] Lee (n ៤២) ៣៦.

## ៤.២ តួនាទីយេនឌ័រនៅក្នុងស្ថាប័ន ទស្សនៈចេញពីអ្នកតបសម្ភាស

**របកគំហើញសំខាន់ៗ៖** របកគំហើញដែលផុសចេញមកពីការប្រមូលទិន្នន័យរួមមានទស្សនៈផ្សេងៗគ្នាជាច្រើនទៅលើតួនាទីនិងភាពជាតំណាងរបស់ស្ត្រីក្នុងពុទ្ធសាសនា។ ខណៈដែលអ្នកតបសម្ភាសមួយចំនួន (ជាពិសេសគ្រហស្ថនិងអ្នកចូលរួមជាបុគ្គលស្ត្រីនិយម)បង្ហាញនូវក្ដីបារម្ភអំពីការដែលថាស្ត្រីមិនអាចទទួលបានឱកាសនិងតួនាទីនៅក្នុងស្ថាប័នពុទ្ធសាសនាដូចគ្នានឹងបុរសទេនោះ អ្នកចូលរួមមួយចំនួនយល់ថាប្រការនេះគឺជាការឆ្លុះបញ្ចាំងអំពីលំដាប់លំដោយក្នុងធម្មជាតិមួយដែលផ្អែកទៅលើឋានានុក្រមយេនឌ័រ ហើយក៏បានការពារទាំងបុរសនិងស្ត្រីពីទង្វើនិងគំនិតផ្លូវភេទដែលគ្មានគុណធម៌។

វាហាក់បីដូចជាមានកម្រិតនៃការបកស្រាយមួយអំពីតួនាទីរបស់ស្ត្រីដែលគេអនុញ្ញាតឱ្យកាន់តំណែងនាពេលបច្ចុប្បន្ននេះនៅក្នុងបរិបទពុទ្ធសាសនាកម្ពុជា ក្នុងនោះអ្នកតបសម្ភាសពីរនាក់បានលើកឡើងថាស្ត្រីអាចត្រូវបានបំបួសហើយ។ អ្នកឆ្លើយតបមួយចំនួនទៀតជាពិសេសគឺព្រះសង្ឃបានលើកសម្មតិកម្មថាគេប្រហែលជាអាចបំបួសស្ត្រីបានក្នុងពេលអនាគតប៉ុន្តែក៏បានលើកឡើងនូវក្ដីបារម្ភមួយចំនួនអំពីលទ្ធភាពនៃការអនុវត្តបានជាក់ស្ដែងដូចជាការរៀបចំការរស់នៅជាដើម។

### អ្នកតបសម្ភាសជាគ្រហស្ថ៖

អ្នកតបសម្ភាសជាគ្រហស្ថមួយចំនួនបានលើកឡើងអំពីការឯកភាពទៅលើការអនុវត្តតាមស្ថាប័ននាពេលបច្ចុប្បន្នអំពីការបែងចែកតួនាទីតាមយេនឌ័រដោយរួមបញ្ចូលទាំងការស្វែងរកភាពច្បាស់លាស់ដែរ។ ដូចដែលអ្នកតបសម្ភាសជាគ្រហស្ថបុរសម្នាក់បាននិយាយថា "ព្រះសង្ឃនិងដូនជីមិនគួរស្មើភាពគ្នាទេ... គួរតែមានការបែងចែកតួនាទីឱ្យច្បាស់រវាងដូនជីអាចារ្យ[៤២] អ្នកសម្អាតនិងព្រះសង្ឃ។" អ្នកតបសម្ភាសដដែលនេះហាក់បីដូចជា"មិនសូវឱ្យតម្លៃទៅលើ"គម្លាតយេនឌ័រ៖ "ពុទ្ធសាសនាផ្ដល់សិទ្ធិដូចគ្នាក្នុងការទទួលបានការអប់រំ។ វាគ្រាន់តែថាស្ត្រីមិនអាចធ្វើជាព្រះសង្ឃ ប៉ុន្តែអាចត្រឹមតែជាដូនជី។"

"ការមិនសូវឱ្យតម្លៃ"ទៅលើឋានៈខុសគ្នារវាងបុរសនិងស្ត្រីទទួលបាននៅក្នុងវត្តគឺជាប្រធានបទមួយដែលកើតឡើងពាសពេញការឆ្លើយតបរបស់អ្នកចូលរួមជាគ្រហស្ថជាច្រើនជាពិសេសក្នុងចំណោមបុរស៖

> "មិនមានការបែងចែកអំពីឋានានុក្រមឬឋានន្តរសក្តិនៅក្នុងវត្តទេវាគ្រាន់តែមើលទៅហាក់បីដូចជាមានការបែងចែកកើតឡើងបែបនេះពីព្រោះស្ត្រីខ្វះការជំរុញទឹកចិត្តក្នុងការចូលរួម។ ស្ត្រីមិនមានសេចក្ដីក្លាហានក្នុងការដឹកនាំមនុស្សច្រើនទេ ដូច្នេះត្រូវទទួលយកការងារកំប៉ិចកំប៉ុកដូចជាលាងចានជាដើមវិញ។"

[៤២] អាចារ្យ សំដៅទៅលើគ្រហស្ថដែលមិនស្នាក់នៅក្នុងវត្ត ប៉ុន្តែ ដឹកនាំអ្នកកាន់ពុទ្ធសាសនាក្នុងការរៀនសូត្រអំពីធម៌និងរៀបចំពិធីសាសនា

## បើគ្មានឱកាសស្មើភាពគ្នាសម្រាប់ស្ត្រីក្នុងការក្លាយជាព្រះសង្ឃទេ យើងក៏មិនអាចនិយាយថាពុទ្ធសាសនាមានសមភាពយេនឌ័រនោះទេ។

**អ្នកតបសម្ភាសគ្រហស្ថជាស្ត្រី**

អ្នកឆ្លើយតបជាគ្រហស្ថវ័យចំណាស់មួយរូបបានផ្តល់នូវការវិភាគផ្សេងពីនេះដោយពន្យល់ថា  ការបែងចែករវាងយេនឌ័រគឺដោយសារតែវាគឺជាអ្វីដែលបានកើតឡើងអស់រយៈពេលច្រើនសតវត្សមកហើយ៖“ខ្ញុំគិតថាវាគឺជាការរៀបលំដាប់ដ៏ត្រឹមត្រូវមួយពីព្រោះថាមានប្រពៃណីទំនៀមទម្លាប់នេះតាំងតែពីយូរយារណាស់មកហើយ។ មនុស្សត្រូវគោរពព្រះសង្ឃច្រើនជាងយាយជីប៉ុន្តែនេះមិនមែនមានន័យថាជាការរើសអើងទៅលើយាយជីនោះទេ។”   អ្នកតបសម្ភាសម្នាក់ទៀតបានលើកឡើងថាការបែងចែកណាមួយទៅលើតួនាទីទាំងអស់នេះគឺគ្រាន់តែដើម្បីធ្វើឲ្យវត្តមានហេដ្ឋារចនាសម្ព័ន្ធនិងសណ្តាប់ធ្នាប់សង្គមមួយក្នុងការកែលម្អមុខងាររបស់វត្តតែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយអ្នកតបសម្ភាសជាគ្រហស្ថម្នាក់ផ្សេងទៀតបានលើកឡើងអំពីការដែលថាតាជីមិនបានចូលរួមពាក់ព័ន្ធជាមួយនឹងការងារដូចជាលាងចាន ដាំស្ល ឬបោសសម្អាត។ ចំណុចនេះចង្អុលបង្ហាញដូចដែលអ្នកតបសម្ភាសម្នាក់បាននិយាយថា  “នៅតែមានការយល់ឃើញថាបុរសខ្ពង់ខ្ពស់ជាងស្ត្រី” សូម្បីតែនៅក្រៅទំនាក់ទំនងឋានានុក្រមរវាងព្រះសង្ឃនិងសីលវន្តក៏ដោយ។

ឆ្លុះបញ្ចាំងបន្ថែមទៀតទៅលើការបែងចែកភារៈកិច្ចរវាងតាជី និងយាយជី/ដូនជី អ្នកតបសម្ភាសជាគ្រហស្ថមួយចំនួនយល់ឃើញថាតួនាទីទាំងអស់នេះគឺយ៉ាងហោចណាស់មានភាពស្មើគ្នាជាទូទៅដែរដោយបាននិយាយថាទាំងតាជីនិងយាយ/ដូនជី ត្រូវបានគេគោរពក្នុងនាមជាចាស់ទុំនៅក្នុងសហគមន៍។ អ្នកផ្សេងទៀតមានការយល់ឃើញថាវាជាការឆ្លុះបញ្ចាំងអំពីកម្រិតខុសគ្នាខ្លាំងដោយផ្អែកទៅលើយេនឌ័រដូចដែលសម្រង់សំដីខាងក្រោមពីបុគ្គលជាគ្រហស្ថបុរសម្នាក់បានបង្ហាញថា៖

> “ទាំងដូនជី/យាយជីនិងតាជីត្រូវបម្រើព្រះសង្ឃ ប៉ុន្តែតាមទិដ្ឋភាពជាក់ស្តែងភាគច្រើនគឺស្ត្រីនិងដូនជី/យាយជីជាអ្នកបម្រើព្រះសង្ឃពីព្រោះពួកគេដឹងតួនាទីរបស់ខ្លួនជាមនុស្សស្រី។ តាមច្បាប់ទាំងបុរសនិងស្ត្រីអាចមានតួនាទីជាតាជី ដែលពាក់ព័ន្ធទៅនឹងការបង្រៀនសាសនាមួយចំនួនដែរ។ ប៉ុន្តែនៅក្នុងតួថភាពជាក់ស្តែងស្ត្រីមិនអាចដើរតួនាទីជាតាជីបានទេដោយសារតែពួកគេខ្វះសមត្ថភាពនិងចំណេះដឹង។”

ដូច្នេះទស្សនៈរបស់អ្នកតបសម្ភាសជាគ្រហស្ថអំពីភាពជាតំណាងរបស់ស្ត្រីនៅក្នុងស្ថាប័នពុទ្ធសាសនាមានភាពផ្សេងៗពីគ្នា។ ប្រហែលជាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលអ្នកតបសម្ភាសគ្រហស្ថជាស្ត្រីហាក់ដូចជាយល់ឃើញអំពីគំនិតទាក់ទងជាមួយនឹងព្រះសង្ឃស្រីដែលមានភាពគួរជាទីគាប់ចិត្តជាងការយល់ឃើញរបស់អ្នកតបសម្ភាសជាគ្រហស្ថបុរស។ ពួកគេក៏បានឃើញអំពីកិច្ចការដែលផ្តល់ដល់ស្ត្រីជាទូទៅនៅក្នុងវត្តដូចជាការដាំស្ល និងការបោសសម្អាតថាជាការបែងចែកការងារដែលមានបញ្ហាជាងការយល់ឃើញរបស់បុរស។ ឧទាហរណ៍ អ្នកតបសម្ភាសគ្រហស្ថជាស្ត្រីម្នាក់បានរអ៊ូរទាំថា “ប្រសិនបើគ្មានឱកាសស្មើភាពគ្នានិងលទ្ធផលស្មើភាពគ្នាក្នុងការក្លាយទៅជាព្រះសង្ឃនោះទេយើងក៏មិនអាចនិយាយបានថាព្រះពុទ្ធសាសនាមានសមភាពយេនឌ័រនោះទេ។”

មានការបែងចែកតួនាទី [រវាងបុរសនិងស្ត្រី] ប៉ុន្តែការបែងចែកនេះគឺដើម្បីឱ្យមានការគោរពគ្នាទៅវិញទៅមក មិនមែនដើម្បីរើសអើងទៅលើភេទណាមួយទេ។

**អ្នកតបសម្ភាសជាព្រះសង្ឃ**

## អ្នកតបសម្ភាសជាបព្វជិតសាសនា

បញ្ហា"ទំនៀមទម្លាប់វប្បធម៌និងការអនុវត្តសាសនា"និងខ្សែបន្ទាត់ដែលមានភាពមិនច្បាស់លាស់ដែលស្ថិតនៅចន្លោះកណ្តាលនោះត្រូវបានលើកឡើងម្តងទៀតដោយព្រះសង្ឃនិងអ្នកតបសម្ភាសជាយាយជីនៅពេលពិភាក្សាអំពីតួនាទីរបស់ស្ត្រីនៅក្នុងវត្ត។ ឧទាហរណ៍ ព្រះសង្ឃមួយអង្គមានដីកាថាព្រះពុទ្ធសាសនាមិនរើសអើងរវាងយេនឌ័រទេតែផ្ទុយទៅវិញ "ក្រឹត្យក្រមប្រពៃណីទេដែលជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធនៅក្នុងវត្ត។" គាំទ្របន្ថែមពីលើចំណុចនេះព្រះសង្ឃមួយអង្គទៀតបានឆ្លុះបញ្ចាំងទៅលើការយល់ឃើញផ្ទាល់ព្រះអង្គអំពីសមភាពយេនឌ័រនៅក្នុងសាសនាថា៖ "មានការបែងចែកតួនាទីប៉ុន្តែការបែងចែកនេះគឺដើម្បីឲ្យមានការគោរពគ្នាទៅវិញទៅមកមិនមែនដើម្បីរើសអើងប្រឆាំងភេទណាមួយនោះទេ។"

សម្រង់សំដីទាំងនេះឆ្លុះបញ្ចាំងអំពីគំនិតដ៏សំខាន់មួយ៖ ប្រសិនបើពុទ្ធសាសនាត្រូវបានព្រះសង្ឃយល់ឃើញថាទទួលយកគំនិតអំពីសមភាពយេនឌ័រពិតមែននោះ ហើយវាពិតជាសង្គមទេដែលពង្រឹងការរើសអើងផ្អែកលើយេនឌ័រណាមួយនោះនេះអាចបង្ហាញអំពីឱកាសមួយសម្រាប់អ្នកអនុវត្តសាសនាដូចជាព្រះសង្ឃ ព្រះសង្ឃជាន់ខ្ពស់ តាជី និងយាយជី/ដូនជី ក្នុងការច្របាច់បញ្ចូលសមភាពយេនឌ័រទៅក្នុងការអនុវត្តសាសនានិងការបង្រៀនសាសនា។ សកម្មភាពនេះអាចមានភាពងាយៗដូចជាការលើកទឹកចិត្តឱ្យបុរសនៅក្នុងសហគមន៍ឲ្យមានទំនាក់ទំនងជាមួយស្ត្រីដោយការគោរពដូចដែលការបង្រៀនរបស់ពុទ្ធសាសនាដែលចាត់ទុកថាស្ត្រីនិងបុរសមានភាពស្មើគ្នាជាប់មកជាមួយពុទ្ធសាសនានេះដែរ។

អ្នកតបសម្ភាសជាយាយជីក៏ត្រូវបានសួរសំណួរដើម្បីឱ្យឆ្លុះបញ្ចាំងទៅលើការបែងចែកតួនាទីយេនឌ័រនៅក្នុងវត្តដែរ។ ពួកគេបានលើកឡើងថាខណៈដែលបុរសនិងស្ត្រីអាចមានតួនាទីនៅក្នុងគណៈកម្មការវត្តក្នុងមូលដ្ឋាននោះ តួនាទីរបស់អាចារ្យ(បុរសជាគ្រហស្ថដែលមិនរស់នៅក្នុងវត្តទេ ប៉ុន្តែដឹកនាំពុទ្ធបរិស័ទឱ្យរៀនសូត្រអំពីធម៌និងរបៀបរៀបចំពិធីសាសនា) ជាធម្មតាគឺជាតួនាទីផ្តាច់មុខរបស់បុរស។ ហេតុផលសម្រាប់បញ្ហានេះ គេយល់ឃើញថាគ្រហស្ថជាស្ត្រី "មិនទាន់មានចំណេះដឹងនៅឡើយ" ហើយមានការរវល់ក្នុងការមើលថែទាំកូននិងកិច្ចការងារផ្ទះ។ ហេតុដូច្នេះហើយ "ស្ត្រីមានពេលវេលាតិចតួចក្នុងការរៀនអំពីធម៌ខណៈពេលដែលបុរសមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀនសូត្រក្លាយទៅជាអាចារ្យ។"

ព្រះសង្ឃក៏ត្រូវបានសួរអំពីភាពរឹងត្អឹងនៃការបែងចែកកិច្ចការរវាងយាយជីនិងតាជីដែរនិងថាតើមានការបង្រៀនជាផ្លូវការណាដែលដូនជី/យាយជី គួរអនុវត្តការងារសម្អាតដែរឬទេ។ ព្រះសង្ឃមួយអង្គបានឆ្លើយថា៖

> "តួនាទីរបស់តាជី គឺដឹកនាំការសូត្រធម៌សម្រាប់គ្រហស្ថផ្សេងទៀត ខណៈដែលយាយជីត្រូវចាត់ចែងរៀបចំម្ហូបអាហារនិងបោសសម្អាតទីធ្លាវត្តអារាមឱ្យបានស្អាត។ ប៉ុន្តែព្រះពុទ្ធមិនបានចែងថាយាយជីត្រូវតែបម្រើព្រះសង្ឃនិងតាជីនោះទេ វាគឺដោយសារតែលក្ខខណ្ឌសង្គម និងដោយសារតែយាយជីភាគច្រើនមិនសូវបានទទួលបានការអប់រំច្រើន ហេតុដូច្នេះហើយ មិនមានជំនាញគ្រប់គ្រងគ្រប់គ្រាន់នោះទេ។"

ប្រសិនបើការពិភាក្សាខាងលើជាការឆ្លុះបញ្ចាំងអំពីទស្សនៈទូលំទូលាយក្នុងចំណោមព្រះសង្ឃនោះ វាអាចជាហេតុផលដែលថាមាន "ឱកាសផ្លាស់ប្តូរ" សម្រាប់យាយជីក្នុងការទទួលយកការងារផ្សេងៗទៀតនៅក្នុងទីវត្តអារាមប្រសិនបើពួកគាត់ចង់ ហើយថាការផ្លាស់ប្តូរនេះមិនបានប្រឆាំងចំពោះការបង្រៀននៅក្នុងព្រះពុទ្ធសាសនានោះទេ។ ដូចព្រះសង្ឃមួយអង្គទៀតមានដីកាថា"ការងារដែលយាយជីនិងតាជីធ្វើគឺយោងទៅតាមការប្រាថ្នារបស់ខ្លួន។ ព្រះពុទ្ធសាសនាមិនបានប្រាប់ពួកគាត់ឱ្យលាងចាន ឬសម្អាតទីធ្លាវត្តអារាមនោះទេ។"

ព្រះសង្ឃមួយអង្គទៀតមានដីកាស្នើថាព្រះអង្គស្វាគមន៍ស្ត្រីទទួលការបំបួសជាសង្ឃជាថ្មីម្តងទៀតក្នុងពេលអនាគត៖

> "ស្ត្រីក៏អាចក្លាយជាព្រះសង្ឃដែរប៉ុន្តែវាមិនទាន់កើតឡើងក្នុងពេលបច្ចុប្បន្ននេះនៅឡើយទេដោយសារតែមានក្តីបារម្ភអំពីលទ្ធភាពនៃការរំលោភបំពានទៅលើក្រមសីលធម៌រវាងយេនឌ័រផ្សេងៗគ្នា។ អាត្មាគិតថាគួរតែអនុញ្ញាតឲ្យស្ត្រីធ្វើជាព្រះសង្ឃដែរ ប្រសិនបើពួកគេចង់ធ្វើ។"

ជាការដែលគួរឱ្យកត់សម្គាល់ថាអ្នកតបសម្ភាសជាព្រះសង្ឃជាច្រើនបានបង្ហាញអំពីជំហររឹងមាំទៅលើបញ្ហានានាដែលទាក់ទងជាមួយនិងសមភាពយេនឌ័រ។ ជាក់ស្តែងសូមពិចារណាទៅលើការឆ្លើយតបខាងក្រោមពីព្រះសង្ឃមួយអង្គដែលអះអាងថា ការរារាំងមានតែនៅក្នុងរចនាសម្ព័ន្ធនៃនីតិវិធីបំបួសតែប៉ុណ្ណោះ ព្រះពុទ្ធសាសនាមិនដែលបានចាត់ទុកថាស្ត្រីមិនសក្តិសមនឹងទទួលបានការបំបួសនោះឡើយ៖

> "ការបែងចែករវាងបុរសនិងស្ត្រីនៅក្នុងវត្តគឺថាបុរសដឹកនាំពិធីសាសនាខណៈដែលស្ត្រីមិនដឹកនាំទេ។ ខ្ញុំគិតថារឿងនេះអយុត្តិធម៌ណាស់ហើយក៏ជាការឆ្លុះបញ្ចាំងអំពីការរើសអើងដែរ។ ការបែងចែកនេះគឺដោយសារតែទំនៀមទម្លាប់និងបទដ្ឋានទៅវិញទេ។
>
> ស្ត្រីក៏អាចក្លាយទៅជាព្រះសង្ឃបានដែរប៉ុន្តែវាមានហានិភ័យដែលអាចបណ្តាលឱ្យមានចលាចលនៅក្នុងព្រះសាសនាដោយសារតែវាពិបាកក្នុងការបណ្តុះនូវភាពស្ងប់ស្ងាត់នៅពេលដែលបុរសនិងស្ត្រីនៅជិតគ្នា។ ដូចគ្នានេះដែរក្នុងគោលបំណងដើម្បីឱ្យស្ត្រីក្លាយទៅជាព្រះសង្ឃស្ត្រីត្រូវតែបំបួសដោយភិក្ខុសង្ឃនិងភិក្ខុនីជាន់ខ្ពស់ដែរ។"

ជាចុងក្រោយអ្នកតបសម្ភាសជាព្រះសង្ឃមួយអង្គមានដីកាថាស្ត្រីហាក់មិនចង់បួសជាព្រះសង្ឃទេ៖ "ស្ត្រីក៏អាចក្លាយជាព្រះសង្ឃដែរ វាគ្រាន់តែថាមិនមានស្ត្រីចង់បួសជាព្រះសង្ឃ។ រឿងដែលគួរឱ្យចាប់អារម្មណ៍គឺមានព្រះសង្ឃមួយចំនួនបានផ្តល់យោបល់ថា នៅ កម្ពុជាមានវត្តមានព្រះសង្ឃស្រីរួចហើយ ចំណែកអ្នកខ្លះទៀតផ្តល់យោបល់ថានៅមិនទាន់មានវត្តមានព្រះសង្ឃស្រីនៅឡើយទេ ប៉ុន្តែអាចមាននៅក្នុងពេលអនាគតខាងមុខ ។ គោលបំណងនៃការស្រាវជ្រាវនេះមិនមែនដើម្បីរាយការណ៍ថាអ្វីដែល"ត្រូវ"នោះទេ ប៉ុន្តែយើងចង់រាយការណ៍ថាតើអ្នកបដិបត្តិសាសនាយល់ឃើញថាករណីនេះត្រូវកើតឡើងយ៉ាងដូចម្តេចហើយដូចដែលផ្នែកខាងលើបានបង្ហាញយើងអាចបង្កើតបាននូវរបកគំហើញសំខាន់ៗចំនួនពីរ។

**របកគំហើញទីមួយគឺថាគ្រហស្ថហាក់បីដូចជាជឿថាតាជីនិងយាយជីមានតួនាទីជាក់លាក់កំណត់រួចហើយ ខណៈដែលព្រះសង្ឃយល់ថាការងាររបស់ពួកគេមានលក្ខណៈអាចប្រែប្រួលបាន។** ព្រះសង្ឃក៏បានរាយការណ៍ថាឧបសគ្គណាដែលរារាំងយាយជីមិនឱ្យដើរតួនាទីសំខាន់ៗជាងនេះទៀតនោះគឺជាហេតុផលវប្បធម៌ជាជាងហេតុផលសាសនា។

**របកគំហើញទីពីរគឺថាទិន្នន័យហាក់បីដូចជាមិនបានឆ្លុះបញ្ចាំងអំពីការរុញច្រានមនោគមវិជ្ជាពីគ្រហស្ថឬព្រះសង្ឃចំពោះគំនិតពីស្ត្រីធ្វើជាព្រះសង្ឃនោះទេ។** ការពន្យល់ថាស្ត្រីមិនអាចបំបួសបាននោះគឺស្ថិតនៅលើបញ្ហាបច្ចេកទេស (គ្មានភិក្ខុនីដើម្បីបំបួសព្រះសង្ឃស្រីជំនាន់ក្រោយ) និងការអនុវត្តជាក់ស្តែង (ស្ត្រីនិងព្រះសង្ឃមិនអាចស្នាក់នៅក្នុងអាស្រមវត្តជាមួយគ្នាបានដោយសារហេតុផលក្នុងការរក្សានូវភាពបរិសុទ្ធនៃចិត្តនិងការមិនរួមភេទ)។ ប្រការនេះខុសពីសាសនាកាតូលិកដែលមានការកំហិតដោយច្បាប់របស់ព្រះអំពីភាពមិនសមស្របផ្នែកស្មារតីរបស់ស្ត្រីក្នុងការធ្វើជាសង្ឃកាតូលិកនោះ អ្នកឆ្លើយតបនៅក្នុងការសិក្សានេះមិនបានសំដៅទៅលើគំនិតដែលថា ស្ត្រីគ្មានភាពសមស្របផ្នែកស្មារតីជាប់មកជាមួយដើម្បីអាចបំបួសនៅក្នុងព្រះពុទ្ធសាសនានោះទេ។

គួរមានការស្រាវជ្រាវបន្ថែមដើម្បីរកឱ្យឃើញថាតើនេះគឺជាទស្សនៈដែលរីកសាយភាយទូលំទូលាយក្នុងចំណោមព្រះសង្ឃនិងគ្រហស្ថនៅក្នុងប្រទេសកម្ពុជាឬយ៉ាងណា? និង តើអ្វីខ្លះដែលជាឱកាសសម្រាប់ការសន្ទនាប្រកបដោយការគោរពអំពីលទ្ធភាពដែលស្ត្រីអាចក្លាយជាព្រះសង្ឃបានឬយ៉ាងហោចណាស់អំពីការគាំទ្រដល់យាយជីឬដូនជីដើម្បីស្វែងរកវិធីឱ្យទទួលបាននូវតួនាទីសំខាន់ៗនៅក្នុងវត្តប្រសិនបើពួកគាត់ប្រាថ្នាចង់បាននោះ។ នេះមិនមែនជាការបន្ថយនូវការងារដែលមានសារៈសំខាន់និងចំបាច់ដែលយាយជីកំពុងធ្វើនាពេលបច្ចុប្បន្ននោះទេ ប៉ុន្តែវាជាការស្នើថាការសន្ទនាបែបនេះអាចបង្កើននូវភាពជាទីភ្នាក់ងាររបស់យាយជីនិងតាជីដើម្បីធ្វើការងារឱ្យហួសពីការងារដែលត្រូវបានបែងចែកឱ្យធ្វើតាមយេនឌ័រនៅក្នុងពេលបច្ចុប្បន្ននេះ។

## អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយម

អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយមទាំងអស់នៅក្នុងការស្រាវជ្រាវនេះបានចង្អុលបង្ហាញគំនិតមួយចំនួនអំពីភាពមិនស្រណុកក្នុងចិត្ត និងការមិនយល់ស្របជាមួយនិងការបែងចែកការងារយេនឌ័រនាពេលបច្ចុប្បន្ននៅក្នុងស្ថាប័នព្រះពុទ្ធសាសនា។ អ្នកតបសម្ភាសម្នាក់បានពន្យល់ថាការបំបួសព្រះសង្ឃស្ត្រីគឺជាបញ្ហាមួយដែលគាត់ផ្ទាល់ខ្លួនមានការពិបាកទទួលយកទោះបីជាគាត់ជាអ្នកបដិបត្តិតាមជំនឿពុទ្ធសាសនាក៏ដោយ៖

> … អវត្តមាននៃព្រះសង្ឃស្ត្រីគឺជាបញ្ហាមួយសម្រាប់ខ្ញុំ។ សម្រាប់ខ្ញុំផ្ទាល់ខ្ញុំចោទសួរអំពីការអះអាងដែលថាភិក្ខុនីបានបាត់បង់ខ្សែស្រឡាយដើមនោះ។ ខ្ញុំគិតថាព្រះពុទ្ធមានសេចក្តីករុណានិងមានសេចក្តីសណ្តោសប្រណីច្រើនខ្លាំងណាស់។ ប្រសិនបើព្រះពុទ្ធនៅមានព្រះជន្មនាពេលបច្ចុប្បន្ននេះព្រះអង្គប្រាកដជាអនុញ្ញាតឱ្យស្ត្រីក្លាយទៅជាភិក្ខុនីហើយ។

អ្នកតបសម្ភាសម្នាក់ទៀតបានប្រាប់ថានាងបានខិតខំប្រឹងប្រែងឱ្យមានការចូលរួមពាក់ព័ន្ធពីសីលវន្តឱ្យបានស្មើភាពគ្នាដូចព្រះសង្ឃដែរ៖ “ខ្ញុំបានចាប់ផ្តើមចោទសួរថាហេតុអ្វីបានជាសីលវន្តត្រូវហូបអាហារក្រោយព្រះសង្ឃហើយត្រូវលាងចាន។ បច្ចុប្បន្ននេះនៅផ្ទះរបស់ខ្ញុំនៅពេលដែលខ្ញុំមានពិធីអ្វីមួយខ្ញុំអញ្ជើញដូនជីហើយធ្វើដូចដែលខ្ញុំអនុវត្តចំពោះព្រះសង្ឃដែរ។”



# ៥ អំពើហិង្សា ផ្អែកលើយេនឌ័រ

## ការឈ្វេងយល់អំពីអំពើហិង្សា ផ្អែកលើយេនឌ័រ ក្នុងចំណោមអ្នក កាន់ពុទ្ធសាសនានៅកម្ពុជា

> ប្រសិនបើយើងអាចចងចាំថាចំណុចខ្លឹមនៃពុទ្ធសាសនា... គឺជាគំនិតដ៏ឧត្តមអំពីសេចក្តីស្រលាញ់និងសេចក្តីករុណា... នោះគឺជាគ្រាប់ពូជដែលអាចបណ្តុះដើម្បីព្យាបាលឫសនៃ [អំពើហិង្សាផ្អែកលើយេនឌ័រ] និងទប់ស្កាត់វដ្តនៃអំពើហឹង្សាកុំឱ្យបន្តកើតឡើង។
>
> KANUKOLLU & EPSTEIN-NGO (២០០៥).

របាយការណ៍នេះ បានពិនិត្យមើលទៅលើទស្សនៈយល់ឃើញទូលំទូលាយអំពីសមភាពយេនឌ័រនៅក្នុងព្រះពុទ្ធសាសនា (ផ្នែកទី៣) និងតួនាទីរបស់ស្ត្រីក្នុងស្ថាប័នព្រះពុទ្ធសាសនាកម្ពុជា (ផ្នែកទី៤)។ ឥឡូវនេះយើងបែរមកមើលការយល់ឃើញរបស់ប្រជាជនកម្ពុជាចំពោះអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងបរិបទព្រះពុទ្ធសាសនាតាមរយៈការដែលព្រះពុទ្ធសាសនាគឺជាប្រពៃណីសាសនាមួយដែលត្រូវបានគេស្គាល់ថាមានគោលការណ៍រឹងមាំផ្អែកអហិង្សា។

## ៥.១ អំពើហិង្សាផ្អែកលើយេនឌ័រ៖ ទស្សនៈចេញពីឯកសារស្រាវជ្រាវ

Kanukollu និង Epstein-Ngo បានពន្យល់ថាមានការស្រាវជ្រាវតិចតួចណាស់ទៅលើប្រធានបទនៃការអនុវត្តគុណតម្លៃព្រះពុទ្ធសាសនា ឬ ការបង្រៀនរបស់ពុទ្ធសាសនាដើម្បីបង្កា ឬ ទប់ស្កាត់រារាំងវដ្តនៃអំពើហិង្សាផ្អែកលើយេនឌ័រ[៤៣]។ មានគម្លាតមួយក្នុងឯកសារស្រាវជ្រាវដែលមានស្រាប់ចំពោះប្រធានបទស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងសហគមន៍ពុទ្ធសាសនា។

ឯកសារស្រាវជ្រាវដែលមានស្រាប់បានពិភាក្សាអំពីអំពើហិង្សាផ្អែកលើយេនឌ័រនិងព្រះពុទ្ធសាសនាតាមរបៀបមួយចំនួននៅក្នុងការសិក្សារបស់ Kanukollu និង Epstein-Ngo ពួកគេបានសង្កេតឃើញថាអំពើហិង្សាផ្អែកលើយេនឌ័របានកើតឡើងនៅក្នុងសហគមន៍ពុទ្ធសាសនា “ទោះបីជាគោលការណ៍ជំនឿដ៏សំខាន់ទាក់ទងជាមួយនឹងសេចក្តីស្រលាញ់និងក្តីករុណាត្រូវបានបង្រៀននៅក្នុងព្រះពុទ្ធសាសនាក៏ដោយ” ក៏ពួកគេបានលើកទឡ្ហីករណ៍ថាគ្មានការសិក្សាស្រាវជ្រាវគ្រប់គ្រាន់អំពីរបៀបដែលព្រះពុទ្ធសាសនាបានផ្តល់ការគាំទ្រជនរងគ្រោះពាក់ព័ន្ធផ្អែកស្មារតីសាសនានោះទេ[៤៤]។

សំណើរមួយនៅក្នុងការសិក្សារបស់ពួកគេគឺការពិនិត្យមើលទៅលើអដ្ឋង្គិកមគ្គដែលជាគោលការណ៍ដ៏សំខាន់មួយនៃការអនុវត្តតាមបែបព្រពុទ្ធសាសនាពាសពេញប្រពៃណីទាំងអស់[៤៥] និងគោលការណ៍ជាមូលដ្ឋានផ្សេងៗទៀតនៅក្នុងពុទ្ធសាសនាដែលអាចប្រើដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រនៅកម្រិតបុគ្គលនិងកម្រិតសហគមន៍បាន។

[៤៣] Kanukollu and Epstein-Ngo (n 8) ៣៥៣.
[៤៤] Kanukollu and Epstein-Ngo (n 8) ៣៥៣.
[៤៥] Kanukollu and Epstein-Ngo (n 8) ៣៥៣.

> ការធ្វើការជាមួយនឹងអ្នកអភិរក្សវប្បធម៌និងអ្នកដឹកនាំសាសនានៅមូលដ្ឋានមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យមានការរីកចម្រើនដល់យុទ្ធសាស្ត្រដែលមានការយល់ដឹងអំពីវប្បធម៌ក្នុងការទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ។
>
> EISENBRUCH, ២០១៨

> អំពើហិង្សាផ្អែកលើយេនឌ័រមិនស្របជាមួយនឹងការបង្រៀនរបស់ព្រះពុទ្ធដែលគាំទ្រដោយសម្មាទិដ្ឋិ នៃអដ្ឋង្គិកមគ្គទេ... ប្រសិនបើយើងអាចចងចាំថាចំណុចខ្លឹមនៃព្រះពុទ្ធសាសនា... គឺជាគំនិតដ៏ឧត្តមអំពីសេចក្តីស្រលាញ់និងសេចក្តីករុណា... នោះគឺជាគ្រាប់ពូជដែលអាចបណ្តុះដើម្បីព្យាបាលរបួសនៃអំពើហិង្សាផ្អែកលើយេនឌ័រនិងទប់ស្កាត់វដ្តនៃអំពើហិង្សាកុំឱ្យបន្តកើតឡើង *[៤៥]*។

ការសិក្សាឆ្នាំ២០០៨របស់ Eisenbruch បានសួរសំណួរដ៏ពិបាកមួយថា “តើពុទ្ធសាសនាកម្ពុជាបានរួមចំណែកឲ្យមាន... វិសមភាពយេនឌ័រនិងអំពើហិង្សាផ្អែកលើយេនឌ័រដែរឬទេ?”[៤៦]។ Eisenbruch បានរកឃើញថាសាសនាអាចដើរតួនាទីជាកាំបិតមុខពីរនៅក្នុងការប្រយុទ្ធប្រឆាំងនិងអំពើហិង្សាផ្អែកលើយេនឌ័រ៖ ខណៈដែលស្ថាប័នសាសនាអាចជាសម្ព័ន្ធមិត្តដ៏មានសារៈសំខាន់ចាំបាច់ក្នុងការផ្លាស់ប្តូរបទដ្ឋានជុំវិញអំពើហិង្សានោះ គាត់ក៏បានលើកទឡ្ហីករណ៍ថា វាក៏អាចមានការទទួលខុសត្រូវស្មើគ្នាក្នុងការការពារ ឬ ក្នុងការផ្តល់ហេតុផលអំពីការរំលោភបំពានទៅលើសិទ្ធិស្ត្រីដែរ។

ដូចដែលយើងបានវិភាគនៅក្នុងផ្នែកដំបូងៗហើយ ការសិក្សាក្នុងឆ្នាំ២០១១របស់ Kent ដែលមានចំណងជើងថា "ជ្រកក្រោមព្រះធម៌"បានបង្ហាញថាទីធ្លាវត្តអារាមពុទ្ធសាសនាផ្តល់នូវឱកាសមួយចំនួនសម្រាប់ស្ត្រីដែលរងការបំពានក្នុងការស្វែងរកទីពឹងនិងការសះជាឡើងវិញ[៤៧]។ Eisenbruch បានពន្យល់ទៀតថា៖

> “ប្រសិនបើស្ថាប័នព្រះពុទ្ធសាសនានៅកម្ពុជាត្រូវធ្វើអ្វីបន្ថែមទៀតដើម្បីផ្លាស់ប្តូរបទដ្ឋាននៃអំពើហិង្សានោះ វិធីដែលល្អបំផុតដើម្បីឲ្យកើតឡើងបានគឺតាមរយៈការឈ្វេងយល់អំពីចំណុចល្អៗដែលអាចធ្វើបាន **និងលើកទឹកចិត្តដល់ការធ្វើដូច្នេះជាជាងការរិះគន់ពុទ្ធសាសនាថាជាកម្លាំងអភិរក្សទៅលើវិសមភាពយេនឌ័រនោះ”[៤៨]។**

ដូច្នេះសម្រាប់ Eisenbruch ដើម្បីទទួលបានជោគជ័យក្នុងការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា អ្នកតស៊ូមតិត្រូវរៀបចំបង្កើតអន្តរាគមន៍នានាដែលធ្វើការជាមួយប្រពៃណីនិងវប្បធម៌ជាជាងគ្រាន់តែរំលេចឡើងនូវបញ្ហាទាំងអស់នេះថាជាបញ្ហា។ Eisenbruch បានធ្វើការសន្និដ្ឋានថា “ការធ្វើការជាមួយនឹងអ្នកអភិរក្សវប្បធម៌និងមេដឹកនាំសាសនាមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យរីកចម្រើនដល់យុទ្ធសាស្ត្រដែលមានការយល់ដឹងអំពីវប្បធម៌ក្នុងការទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ”[៤៩]។ គំនិតនេះអាចបញ្ជាក់ថាមានការជាប់ទាក់ទង និងមានប្រយោជន៍ទៅដល់អន្តរាគមន៍នានាទាក់ទងជាមួយនិងអំពើហិង្សាផ្អែកលើយេនឌ័រក្នុងពេលអនាគតដែលមានការចូលរួមពាក់ព័ន្ធសកម្មពីស្ថាប័នសាសនា។

[៤៦] M Eisenbruch, ‘អំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា៖ ចំពោះទ្រឹស្តីនៃការផ្លាសប្តូរដែលមានការឆ្លើយតបបែបវប្បធម៌’ (២០១៨) ៤២, វប្បធម៌, វេជ្ជសាស្ត្រ និងវិកលវិទ្យា ៣៥០។
[៤៧] Kent (n 23).
[៤៨] Eisenbruch (n 46).
[៤៩] Eisenbruch (n 46).




ភាគរយនៃអ្នកតបសម្ភាសជាគ្រហស្ថនិងជាបព្វជិតដែលបានរាយការណ៍ថា ការបង្រៀនរបស់ព្រះពុទ្ធសាសនាហាមឃាត់អំពើហិង្សាផ្អែកលើយេនឌ័រ

## ៥.២ អំពើហិង្សាផ្អែកលើយេនឌ័រ៖ ទស្សនៈយល់ឃើញពីអ្នកតបសម្ភាស

### អ្នកតបសម្ភាសជាគ្រហស្ថ៖

អ្នកតបសម្ភាសជាគ្រហស្ថជាច្រើនបានពន្យល់ថាសម្រាប់ពួកគេព្រះពុទ្ធសាសនាផ្តល់ដល់អ្នកបដិបត្តិពុទ្ធសាសនានូវបញ្ញត្តិតឹងរ៉ឹងមួយដែលហាមមិនឱ្យប្រព្រឹត្តអំពើហិង្សាផ្អែកលើយេនឌ័រ។ ជាក់ស្តែងអ្នកតបសម្ភាសម្នាក់បានរាយការណ៍ថា “ព្រះពុទ្ធសាសនាការពារស្ត្រីពីការរំលោភបំពានឬការធ្វើទុក្ខទោសណាមួយ។ ពីព្រោះថាប្រសិនបើអ្នកជាពុទ្ធសាសនិក សាសនានេះបង្រៀនយើងមិនឱ្យបង្កការឈឺចាប់ដល់អ្នកដទៃ។”

ពង្រីកទៅលើបញ្ញត្តិមួយនេះអ្នកតបសម្ភាសជាគ្រហស្ថមួយចំនួនបានស្នើឡើងថា ព្រះសង្ឃមានសមត្ថភាពនិងមានឥទ្ធិពលក្នុងការដើរតួយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ។ អ្នកតបសម្ភាសជាគ្រហស្ថស្រីម្នាក់បានស្នើឡើងថា “ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី យើងអាចអប់រំមនុស្សតាមរយៈកម្មវិធីសាសនានិងការបង្រៀនរបស់ព្រះសង្ឃបាន។”

ការពិភាក្សាជាក្រុមជាមួយគ្រហស្ថវ័យក្មេងផ្តល់នូវគំនិតស៊ីជម្រៅមានតម្លៃអំពីរបៀបមើលនិងពន្យល់អំពីអំពើហិង្សាផ្អែកលើយេនឌ័រតាមរយៈទស្សនៈរបស់ពុទ្ធសាសនាដោយប្រើប្រាស់បញ្ញត្តិសាសនានិងភាសារបស់សាសនាខណៈដែលពួកគេនៅតែប្រើប្រាស់អ្វីដែលអាចចាត់ទុកថាជាទស្សនៈវិស័យដែលផ្អែកទៅលើសិទ្ធិ៖

> ការបង្រៀនអំពីការគ្រប់គ្រងចិត្ត សិទ្ធិ និងសេរីភាព អាចជួយកាត់បន្ថយការយល់ខុសអំពីទស្សនៈនៃអំពើរបស់ជនណាម្នាក់និងលទ្ធផលដែលកើតចេញពីអំពើទាំងនោះ។
>
> ម៉្យាងវិញទៀត បុព្វហេតុនៃអំពើហិង្សាគឺដោយសារតែខ្វះការគ្រប់គ្រងទៅលើចិត្ត និងកង្វះសុចរិតភាព ភាពអត់ធ្មត់ ការគ្រប់គ្រងខ្លួន និងភាពសប្បុរស។”

ការពិភាក្សាខាងលើបង្ហាញថាភាពតានតឹងរវាងព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយមទៅលើបញ្ហាអំពើហិង្សាផ្អែកលើយេនឌ័រនៅកន្លែងណាដែលកើតមាននោះមិនសូវល្អនោះទេ ដែលគំនិតមួយចំនួនស្តីពីការទប់ស្កាត់អំពើហិង្សានេះមិនអាចមានសហអត្ថិភាពរួចរាល់នៅឡើយ។ ការវិភាគបែបស្ត្រីនិយមនិងការអន្តរាគមន៍បែបស្ត្រីនិយមប្រហែលជាអាចពង្រឹងបន្ថែមពីលើគំនិតដែលយល់ឃើញតាមបែបពុទ្ធសាសនាទាំងអស់នេះដោយបន្ថែមបញ្ញត្តិអំពីអំណាចនិងបិតាធិបតេយ្យនៅទីដែលអាចធ្វើបាននិងតាមការសមស្រប។

ជាចុងក្រោយអ្នកចូលរួមជាគ្រហស្ថបុរសម្នាក់បានពន្យល់ថាវិធីសាស្ត្រដែលបានចាត់ឡើងដើម្បីអប់រំកុមារអំពីអហិង្សាតាមរយៈភាសានិងការបង្រៀនរបស់ពុទ្ធសាសនាថា៖

> “ព្រះពុទ្ធសាសនាបង្រៀនមនុស្សឱ្យចេះស្រលាញ់គ្នាទៅវិញទៅមកនិងជៀសវាងការប្រើប្រាស់អំពើហិង្សា។ ខ្ញុំបានប្រើប្រាស់ការបង្រៀនពុទ្ធសាសនាដើម្បីអប់រំកូនរបស់ខ្ញុំ ជាក់ស្តែងគឺបង្រៀនឱ្យមានចិត្តសណ្តោសប្រណីនិងចេះដោះស្រាយបញ្ហាតាមវិធីអហិង្សាដូចជាការពិភាក្សាជាដើម។ នៅពេលដែលមានបញ្ហាកើតឡើង ខ្ញុំប្រើវិធីអហិង្សាតាមរយៈការពិភាក្សាដើម្បីដោះស្រាយបញ្ហា។”

ចំណុចនេះក៏បានបង្ហាញអំពីគោលការណ៍ប្រឆាំងអំពើហិង្សាដ៏មានអានុភាពមួយដែលជាប់មកជាមួយពុទ្ធសាសនាដែលប្រជាជនកម្ពុជាអាចនឹងទាញយកប្រយោជន៍ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងក្នុងសហគមន៍ដែរ។

> មេរៀនរបស់ព្រះពុទ្ធអាចជួយប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័របានប៉ុន្តែវិធីសាស្រ្តបង្រៀនគួរតែមានការផ្លាស់ប្តូរនិងធ្វើបច្ចុប្បន្នភាពដើម្បីផ្សព្វផ្សាយសារនេះឲ្យមានប្រសិទ្ធភាព។
>
> អ្នកតមសម្ភាសជាព្រះសង្ឃ

## អ្នកឆ្លើយតបជា"បព្វជិត"សាសនា

ទាក់ទងនិងការឆ្លើយតបផ្ទាល់របស់ព្រះសង្ឃ ព្រះសង្ឃជាច្រើនបានចង្អុលបង្ហាញថាព្រះសង្ឃមានការចាប់អារម្មណ៍ក្នុងការក្លាយទៅជាអ្នកដែលកាន់តែសកម្មទៅលើបញ្ហាទាក់ទងជាមួយនឹងការទប់ស្កាត់អំពើហិង្សានេះ។ ទស្សនៈដែលគួរឱ្យកត់សម្គាល់ខ្លាំងមួយនៅទីនេះគឺថាព្រះសង្ឃមួយអង្គបានឆ្លុះបញ្ចាំងថាព្រះពុទ្ធសាសនាតាមរយៈព្រះសង្ឃអាចដើរតួនាទីជាយានក្នុងការលើកកម្ពស់អហិង្សានៅក្នុងសហគមន៍ ប៉ុន្តែត្រូវមានការកែលម្អមួយចំនួន៖

> "ក្នុងអតីតកាលមានករណីជាច្រើនដែលបុរសប្រើអំពើហិង្សាទៅលើស្ត្រី ប៉ុន្តែព្រះសង្ឃមិនសូវសកម្មខ្លាំងក្នុងការអប់រំបុរសឱ្យប្តូរអាកប្បកិរិយាទេ។ នោះប្រហែលជាមូលហេតុដែលនាំឲ្យមានការយល់ច្រលំថាព្រះពុទ្ធសាសនាមិនគាំទ្រដល់សិទ្ធិស្ត្រី។
>
> មេរៀនរបស់ព្រះពុទ្ធអាចជួយប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័របាន ប៉ុន្តែវិធីសាស្រ្តបង្រៀនគួរតែមានការផ្លាស់ប្តូរនិងធ្វើបច្ចុប្បន្នភាពដើម្បីផ្សព្វផ្សាយសារនេះឲ្យកាន់តែមានប្រសិទ្ធិភាព។

របកគំហើញខាងលើនេះបង្ហាញថាមិនត្រឹមតែមានបញ្ញត្តិគ្រឹះក្នុងពុទ្ធសាសនាដែលអាចកៀរគរដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី និងបង្ហាញអំពីភាពខុសឆ្គងនៃគំនិតសង្គម/វប្បធម៌អំពីនិរទណ្ឌភាពនិងបុព្វសិទ្ធិអំណាចរបស់បុរសប៉ុណ្ណោះទេគឺវាថែមទាំងជាឆន្ទៈមួយចេញពីអ្នកបដិបត្តិមួយចំនួននៅក្នុងស្ថាប័នព្រះពុទ្ធសាសនាក្នុងការដើរតួនាទីយ៉ាងសំខាន់មួយដើម្បីទាមទារឱ្យបាននូវចំណុចទាំងនេះ។

## អ្នកតបសម្ភាសជាបុគ្គលស្រ្តីនិយម

អ្នកតបសម្ភាសជាបុគ្គលស្រ្តីនិយមមានការខ្វែងគំនិតគ្នាអំពីឥទ្ធិពលរបស់ពុទ្ធសាសនាទៅលើកម្រិតនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងប្រទេសកម្ពុជា។ អ្នកតបសម្ភាសម្នាក់បានលើកទឡ្ហីករណ៍ថាខណៈដែលការធ្វើឲ្យអំពើហិង្សាផ្អែកលើយេនឌ័រក្លាយជារឿងធម្មតាបានចាក់ឫសយ៉ាងជ្រៅទៅក្នុងសង្គមកម្ពុជាអស់រយៈពេលជាច្រើនសតវត្សមកហើយនោះវាមិនមែនជាឥទ្ធិពលរបស់សាសនាឬទាក់ទងនឹងសាសនានោះទេ៖

> ខ្ញុំគិតថាការធ្វើឱ្យអំពើហិង្សាក្លាយទៅជារឿងធម្មតាមិនមែនជាការឆ្លុះបញ្ចាំងអំពីពុទ្ធសាសនាទេ។ នេះគឺជាអ្វីដែលបានកើតឡើងនៅពេលដែលមានច្បាប់ស្រីដែលបាននាំយកមកនូវវិធានក្រឹត្យក្រមជាច្រើន ហើយវាបានជ្រាបចូលទៅក្នុងដួងចិត្តរបស់ប្រជាជនតាំងពីពេលនោះមក។ ប៉ុន្តែច្បាប់ស្រីមិនមែនចេញមកពីគ្រឹះណាមួយ នៃព្រះពុទ្ធសាសនាទេ។ វាគឺជាច្បាប់ដែលកើតឡើងដាច់ដោយឡែកតែឯង។ ច្បាប់ស្រីបង្កើតឡើងដើម្បីដាក់កំហិតទៅលើស្ត្រីនិងដើម្បីធ្វើយ៉ាងណាឱ្យស្ត្រីបំពេញតួនាទីរបស់ខ្លួនដូចជាបង្កើតកូនដាំស្លជាដើម។ ប៉ុន្តែចំណុចទាំងអស់នេះកើតឡើងក្រោយសម័យព្រះពុទ្ធ។ ខ្ញុំមិនគិតថាពុទ្ធសាសនិកពិតប្រាកដបង្រៀនបែបនេះទេ។

> ការពោលថា “វាជាកម្មផល” គឺគ្រាន់តែជាវិធីមួយក្នុងការធ្វើឱ្យជនរងគ្រោះមានអារម្មណ៍មិនសូវឈឺចាប់តែប៉ុណ្ណោះ។ ជាក់ស្តែងបុគ្គលដែលប្រើអំពើហិង្សាគឺកំពុងតែប្រើអាកប្បកិរិយាខុសឆ្គងហើយប្រឆាំងនឹងសីលប្រាំ។
>
> **អ្នកតបសម្ភាសជាយាយជី**

អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយមប្អូននាក់ក្នុងចំណោមប្រាំមួយនាក់ក៏បានលើកឡើងអំពីបញ្ហាទាក់ទងជាមួយនឹងគំនិតអំពីកម្មផលដែរ (គំនិតដែលថាបុណ្យដែលសន្សំបានតាមរយៈទង្វើរបស់នរណាម្នាក់គឺជាកត្តាកំណត់អំពីជោគវាសនារបស់ពួកគេនៅក្នុងពេលអនាគត) ដូចដែលប្រជាជនកម្ពុជាជាច្រើនយល់បែបនេះនៅពេលបច្ចុប្បន្ន។

ជាពិសេសក្តីបារម្ភទាំងនេះត្រូវបានលើកឡើងទាក់ទងជាមួយនឹងផលប៉ះពាល់ដែលជំនឿទៅលើកម្មផលបានកើតឡើងទៅលើការធ្វើឱ្យអំពើហិង្សាទៅលើយេនឌ័រក្លាយទៅជារឿងធម្មតាជាពិសេសនៅក្នុងផ្ទះ។ យោងទៅតាមអ្នកចូលរួមទាំងនេះ ជារឿយៗកម្មផលត្រូវបានលើកឡើងដោយអ្នកប្រតិបត្តិសាសនានិងពុទ្ធសាសនិកដែលជាគ្រហស្ថជាការពន្យល់ថាហេតុអ្វីបានជាស្ត្រីទទួលរងនូវអំពើរំលោភបំពានក្នុងគ្រួសារជាបន្តបន្ទាប់។ អ្នកតបសម្ភាសខាងក្រោមនេះ បានពន្យល់អំពីបញ្ហាទាក់ទងជាមួយនឹងកម្មផលថា៖

> មុនពេលដែលខ្ញុំបានដឹងអំពីស្ត្រីនិយម ខ្ញុំមានអារម្មណ៍ថាភាគច្រើននៃជីវិតរបស់ខ្ញុំគឺកើតឡើងដោយសារតែវាសនាហើយភាគច្រើនគឺផ្អែកទៅលើកម្មពៀរ។ ខ្ញុំគិតថាអ្វីៗសព្វបែបយ៉ាងផ្អែកទៅលើជីវិតរបស់ខ្ញុំកាលពីជាតិមុន។ ដូច្នេះហើយប្រសិនបើអ្នកធ្វើអ្វីមួយខុសនៅជាតិមុននោះវាជាមូលហេតុដែលមានរឿងមិនល្អកើតមកលើអ្នកនៅពេលបច្ចុប្បន្ននេះ។
>
> គ្រួសាររបស់ខ្ញុំនៅតែជឿទៅលើរឿងនេះ។ ប្អូនស្រីខ្ញុំម្នាក់ស្ថិតនៅក្នុងស្ថានភាពនៃអំពើហិង្សាក្នុងគ្រួសារ។ នៅពេលដែលពួកគេលែងលះគ្នាមនុស្សមួយចំនួននៅក្នុងសហគមន៍យល់ឃើញថា នេះគឺជារឿងមិនល្អសម្រាប់គ្រួសាររបស់យើង ហើយក៏នៅតែមានការប្រមាថមាក់ងាយពីសង្គមជាច្រើនអំពីបញ្ហាទាំងអស់នេះ។
>
> នៅពេលដែលមនុស្សឃើញអំពើហិង្សាក្នុងគ្រួសារគេគ្រាន់តែនិយាយថា “នេះគឺជាកម្មពៀររបស់អ្នក!” ហើយពួកគេធ្វើឱ្យប្អូនស្រីរបស់ខ្ញុំជឿថានេះគឺជាកម្មពៀររបស់នាង។ ខ្ញុំមានអារម្មណ៍ចង់និយាយថា “ទេ! ជំនឿនេះត្រូវតែផ្លាស់ប្តូរ។”

ទាក់ទងនឹងបញ្ហាកម្មផលនេះអ្នកចូលរួមជាបុគ្គលស្ត្រីនិយមម្នាក់ផ្សេងទៀតបានស្នើឡើងដូចខាងក្រោម ហើយប្រហែលជាការគាំទ្របន្ថែមដល់អភិក្រមដែលបានរៀបរាប់ពីមុនរបស់ Eisenbruch ទាក់ទងជាមួយនិងការប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រខណៈដែលធ្វើការជាមួយនិងប្រពៃណីនិងសាសនាថា៖

> “យើងគួរតែលាតត្រដាងនិងបង្ហាញអំពីភាពខុសឆ្គងនៃបញ្ញត្តិស្ដីពីកម្មផលនេះដល់សាធារណៈជន៖ យើងគួរតែមានការចូលរួមពីព្រះសង្ឃក្នុងនាមជាអ្នកនាំសារដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីរឿងរ៉ាវមិនពិតមួយចំនួន។ ឧទាហរណ៍ចូលរួមផ្ដល់ការពន្យល់ថា អំពើហិង្សាក្នុងគ្រួសារមិនមែនជាលទ្ធផលដែលកើតចេញមកអំពីកម្មពៀរមិនល្អរបស់យើងនោះទេ។”

# ៦ សិទ្ធិផ្លូវភេទនិង សុខភាពបន្តពូជ

## ការយល់ឃើញអំពីការរំលូតកូន ការពន្យារកំណើត និងការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ ក្នុងចំណោមអ្នកកាន់ពុទ្ធសាសនានៅកម្ពុជា



## ៦.១ សិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជ ទស្សនៈចេញមកពីឯកសារស្រាវជ្រាវ

**ការរំលូតកូន៖** មានគម្លាតដែលគួរឱ្យកត់សម្គាល់មួយនៅក្នុងការស្រាវជ្រាវស្តីពីព្រះពុទ្ធសាសនាថេរវាទកម្ពុជាបច្ចុប្បន្ន និងការបកស្រាយទាក់ទងទៅនឹងបញ្ហាសិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជ។ ជាពិសេសដូចដែល Keown បានសង្កេតនៅក្នុងឆ្នាំ២០១៧ ដោយប្រៀបធៀបទៅនឹងបញ្ចឹមប្រទេសថាមានការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវបែបនេះតិចតួចណាស់ស្តីពីការរំលូតកូនចេញពីទស្សនៈពុទ្ធសាសនា[៥០]។

អ្វីដែលយើងអាចនិយាយបានគឺថាព្រះពុទ្ធសាសនិកជាគ្រហស្ថនៅកម្ពុជា ដូចអ្នកកាន់ព្រះពុទ្ធសាសនាថេរវាទទាំងអស់ដែរត្រូវបានលើកទឹកចិត្តឱ្យរស់នៅក្នុងជីវិតមួយស្របតាម **សីល៥** ដែលមានដូចខាងក្រោម៖

១. វៀរចាកការសម្លាប់សត្វ/ការបណ្តុះចិត្តឲ្យមានមេត្តាធម៌
២. វៀរចាកការយករបស់អ្នកដទៃ/ការបណ្តុះចិត្តឲ្យមានសេចក្តីសប្បុរស
៣. វៀរចាកការប្រព្រឹត្តខុសក្នុងកាម/ការបណ្តុះចិត្តអំពីភាពស្កប់ស្កល់ក្នុងចិត្ត
៤. វៀរចាកកិរិយាពោលនូវពាក្យកុហក/ការបណ្តុះចិត្តឲ្យពោលពាក្យពិត
៥. វៀរចាកគ្រឿងស្រវឹង/ការបណ្តុះចិត្តឲ្យសតិ [៥១]

បើយោងតាម Higgins សីលទាំងប្រាំនេះ "មានទម្រង់ជាការអនុវត្តផ្ទាល់ខ្លួនដោយស្ម័គ្រចិត្ត។" ខុសពីបញ្ញត្តិនៅក្នុងសាសនាគ្រឹស្តបញ្ញត្តិទាំងនេះបង្ហាញពីគោលការណ៍ជាមូលដ្ឋានដែលផ្ទុយពីវិធានផ្លូវច្បាប់ ដែលសកម្មភាពនីមួយៗ ត្រូវស្ថិតនៅក្នុងរង្វង់ច្បាប់ឬក្រៅរង្វង់ច្បាប់នោះ[៥២]។ ព្រះពុទ្ធសាសនាផ្តល់នូវគោលការណ៍ណែនាំជាទូទៅ ប៉ុន្តែក៏ទាមទារឱ្យអ្នកជឿធ្វើការវិនិច្ឆ័យបែបសីលធម៌សមស្របនៅក្នុងស្ថានភាពសំខាន់ផ្នែកសីលធម៌នីមួយៗដែរ។

គំនិតដែលថាការវិនិច្ឆ័យផ្នែកសីលធម៌មិនមែនជាសំណួរដែលត្រូវអនុវត្តវិធានណាមួយដោយងងឹតងងុលនោះទេគឺជាគំនិតដ៏មានសារៈសំខាន់ណាស់នៅពេលពិចារណាថាតើទង្វើមួយចំនួននោះ (តាមរយៈការប្រើប្រាស់ថ្នាំពន្យារកំណើតក្រោយពេលរួមភេទឬការរំលូតកូន) ត្រូវទទួលបានការអត់ឱនកម្រិតណាមួយឬទេ ឧទាហរណ៍ នៅក្នុងបរិបទណាមួយ ឬដោយចេតនារបស់នរណាម្នាក់។

ជាឧទាហរណ៍ Keown បានកត់សម្គាល់ថាសីលទី១ ក្នុងចំណោមសីលទាំង៥ដែលបដិបត្តិដោយបព្វជិតហាមឃាត់ការសម្លាប់ជីវិតសត្វ ហេតុដូច្នេះហើយការរំលូតកូនជាទូទៅត្រូវបានចាត់ទុកថាត្រូវគ្នានឹងការហាមឃាត់មួយនេះ ដូច្នេះត្រូវចាត់ទុកថាជាទង្វើខុសសីលធម៌។ ប៉ុន្តែ "ការរំលូតកូនមានយ៉ាងច្រើនក្នុងមួយឆ្នាំៗទាំងស្របច្បាប់និងមិនស្របច្បាប់ត្រូវបានអនុវត្តដោយអ្នកកាន់ពុទ្ធសាសនាពាសពេញទ្វីបអាស៊ី"[៥៣]។

[៥០] Damien Keown, 'ពុទ្ធសាសនា និង ការរំលូតកូន' (10.1093/OBO/9780195393521-0198, ២៩ វិច្ឆិកា ២០១៧) <https://bit.ly/3nsLFMc.
[៥១] Winton Higgins, 'អភិសមាចារផ្លូវភេទ តាមបែបពុទ្ធសាសនា', អត្ថបទក្នុងទស្សនាវដ្តី *BuddhaNet* (អត្ថបទ, n.d) <http://www.buddhanet.net/winton_s.htm>.
[៥២] Higgins (n ៥១).
[៥៣] Keown (n ៥០).

ដោយសារតែកង្វះខាតការស្រាវជ្រាវជាក់លាក់អំពីប្រទេសកម្ពុជា យើងត្រឡប់ទៅមើលឯកសារអំពីអភិក្រមពុទ្ធសាសនាថេរវាទថៃរបស់សុវណ្ណបុប្ផាទាក់ទងជាមួយនិងបញ្ហាសិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជ។ ខណៈពេលដែលវាហាក់ដូចជាអាចអនុវត្តបានទូលំទូលាយនៅក្នុងបរិបទប្រទេសកម្ពុជានោះ យើងសូមលើកទឹកចិត្តឱ្យមានការស្រាវជ្រាវក្នុងស្រុកបន្ថែមទៀតនៅក្នុងផ្នែកមួយនេះ។ យោងតាមសុវណ្ណបុប្ផា ក្នុងគោលបំណងដើម្បីរីករាយនៅក្នុងជីវិតសាមញ្ញមួយអ្នកកាន់ពុទ្ធសាសនាត្រូវតែជៀសវាងការសម្លាប់។ ក៏ប៉ុន្តែនៅពេលដែលស្តាប់ទៅហាក់បីដូចជា "ក្រមសីលធម៌បែបដាច់ខាតនិងហាក់បីដូចជាបញ្ចប់នូវរាល់ការពិភាក្សាទាក់ទងនឹងការសម្រេចចិត្តត្រឹមត្រូវក្នុងការរំលូតកូននោះ” គាត់បានពន្យល់ថាអ្វីដែលជាភាពដាច់ខាតពិតប្រាកដនោះគឺច្បាប់កម្មផល[៥៥]។

បើយោងទៅតាមការបង្រៀននេះការរំលូតកូននាំឲ្យមានកម្មពៀរ។ វានាំឲ្យកាត់បន្ថយអាយុរបស់អ្នកប្រព្រឹត្តនិងងាយឆ្លងជំងឺមួយចំនួនព្រមទាំងការប្រឈមមុខទៅនឹងសេចក្តីសោកសៅ និងភាពភ័យខ្លាចជាប្រចាំ។ នេះគឺដោយសារតែតាមប្រពៃណីព្រះពុទ្ធសាសនាបានបញ្ញត្តិថាគភ៌ ឬសូម្បីតែទារកក្នុងស្បូនគឺជា “សភាវៈមួយដែលចង់ទៅចាប់កំណើត” ដែលអាចមានលទ្ធភាពនៅក្នុងការបញ្ជូនថាមពលផលកម្មរបស់ខ្លួនបាន។ សុវណ្ណបុប្ផា ពន្យល់ថាយោងតាមច្បាប់កម្មផល **ចេតនាគឺជាគន្លឹះសំខាន់។**

ជាលទ្ធផលការរំលូតកូននៅពេលដែលមានការគំរាមកំហែងដល់ជីវិតម្តាយ អាចចាត់ទុកថាមិនសូវមានកម្មពៀរធ្ងន់ធ្ងរទេឲ្យតែទង្វើនេះមិនផ្អែកទៅលើចេតនាអាក្រក់ដូចជាសេចក្តីលោភលន់ ការស្អប់ កំហឹង ឬ ការភាន់គំនិត។ ការរំលូតកូនដោយចេតនាល្អអាចចាត់ទុកជាសេចក្តីបាបដែលអាចអត់ឱនឲ្យបានដែលជាសេចក្តីបាបលុបលើដោយការចម្រើនរបស់កុសលកម្មចេញពីអំពើល្អដទៃទៀត។ សុវណ្ណបុប្ផា ផ្តល់ឧទាហរណ៍អំពីស្ត្រីម្នាក់ដែលត្រូវគេរំលោភសេពសន្ថវៈ ឬដែលការមានគភ៌នោះមិនអាចបន្តមានជីវិតបាននោះនឹងប្រឈមកម្មពៀរអវិជ្ជមានតិចជាងស្ត្រីដែលរំលូតកូនដោយសារតែ “ការបណ្តោយខ្លួន” នោះ។ បន្ថែមលើនេះទៀតបុគ្គលដែលស្វែងរកការរំលូតកូនដោយសារតែសេដ្ឋកិច្ចលំបាក ឬការមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់ការមានកូននឹងប្រឈមទណ្ឌកម្មពីកម្មផលនេះតិចជាងបុគ្គលដែលមានអារម្មណ៍ស្អប់ ឬខឹងចំពោះគភ៌នោះ[៥៦]។

ដូច្នេះយើងអាចឃើញថានៅក្នុងការស្រាវជ្រាវដែលអាចរកបាននោះ អ្នកប្រាជ្ញមួយចំនួនលើកទឡ្ហីករណ៍ថាថ្វីត្បិតតែមានទស្សនៈអវិជ្ជមានខ្លាំងតាមផ្លូវសីលធម៌ចំពោះការរំលូតកូនក៏ដោយក៏នៅមានវិសាលភាពមួយចំនួននៅក្នុងព្រះពុទ្ធសាសនា សម្រាប់ការរំលូតកូន “មិនសូវអាក្រក់” ដែរ។ គំនិតនេះទន្ទឹមនឹងគំនិត “ការរំលូតកូនដោយសារការបណ្តោយខ្លួន” នៅតែជាការប៉ះទង្គិចជាមួយគោលការណ៍ស្ត្រីនិយមទាក់ទងនឹងស្វ័យភាពពេញលេញលើរាងកាយនិងជម្រើសក្នុងការបន្តពូជ។ ក៏ប៉ុន្តែវាជាចំណុចចាប់ផ្តើមដ៏មានប្រយោជន៍មួយក្នុងការពិនិត្យស្វែងរកការឆ្លើយតបពីទិន្នន័យស្រាវជ្រាវពាក់ព័ន្ធនឹងការរំលូតកូននៅខាងក្រោមក្នុងផ្នែកនេះ។

[៥៤] Parichart Sumanbubbha, ‘សិទ្ធិធ្វើផែនការគ្រួសារ, ការពន្យារកំណើត និងការរំលូតកូន ក្នុងពុទ្ធសាសនាថៃ’ នៅក្នុង, Daniel C Maguire (ed), សិទ្ធិក្នុងសាសនា៖ ករណីការពន្យារកំណើតនិងការរំលូតកូន ក្នុងសាសនាសាកល (Oxford Scholarship Online, 2003) <https://bit.ly/3peixJ9>.
[៥៥] Suwanbubbha (n 54).
[៥៦] Suwanbubbha (n 54).

> ... ការប្រព្រឹត្តល្អក្នុងកាម [ក្នុងពុទ្ធសាសនា] គឺផ្អែកទៅលើមេត្តាធម៌ សប្បុរសធម៌ ភាពស្មោះត្រង់ និងសេចក្តីជ្រះថ្លាក្នុងចិត្ត និងក្នុងអារម្មណ៍គឺជាទង្វើដែលទទួលបានលទ្ធផលល្អ។
>
> HIGGINS, ២០១០

**ការពន្យារកំណើត៖** សុវណ្ណបុប្ផាបានលើកទឡ្ហីករណ៍ថាតាមពិតទៅព្រះពុទ្ធសាសនាលើកទឹកចិត្តដល់ស្រ្តី "ក្នុងការអនុវត្តសិទ្ធិរៀបចំផែនការគ្រួសារនិងការពន្យាកំណើត"[៥៧]។ សិទ្ធិបន្តពូជរបស់ស្រ្តីណាម្នាក់ទាក់ទងនឹងការធ្វើផែនការគ្រួសារនិងការប្រើប្រាស់ការពន្យារកំណើត មានការស្វាគមន៍នៅក្នុងព្រះពុទ្ធសាសនា ទោះបីជាវិធីសាស្រ្តមួយចំនួនត្រូវបានគេទទួលស្គាល់ឱ្យប្រើជាងវិធីសាស្រ្តមួយចំនួនផ្សេងទៀតក៏ដោយ។ ដូចដែលយើងបានពិភាក្សាពីដើមមកនេះគឺដោយសារតែព្រះពុទ្ធសាសនាបានប្រកាន់គំនិតថាជីវិតបានចាប់ផ្តើមដំបូងតាំងពីពេលបង្កកំណើតមកម្ល៉េះ។

នេះគឺជាមូលហេតុដែល "វិធីសាស្រ្តពន្យារកំណើតមួយចំនួនដូចជាការដាក់កងក្នុងស្បូនដែលជាការសម្លាប់មេជីវិត និងរារាំងការវិវត្តន៍ជាវិធីសាស្រ្តមិនអាចទទួលយកបាន[៥៨]។ ក៏ប៉ុន្តែនៅពេលដែលជីវិត "កំពុងរង់ចាំការចាប់កំណើត" មិនត្រូវបានបញ្ចប់ដូចជាការប្រើប្រាស់ស្រោមអនាម័យ ឬថ្នាំពន្យារកំណើតនោះ គេមិនឃើញថាមានទង្វើអសីលធម៌ណាមួយកើតឡើងទេឲ្យតែមិនមានទង្វើផ្លូវភេទមិនគប្បី។

**ការប្រព្រឹត្ត (ខុស) ក្នុងកាម៖** ទាក់ទងនឹងការបន្តពូជ សុវណ្ណបុប្ផា ពន្យល់ថាចំណង់តណ្ហានិងរឿងរ៉ាវផ្លូវភេទក៏ទទួលបានការគោរពនៅក្នុងព្រះពុទ្ធសាសនាដែរ។ គាត់មិនបានដាក់ការសង្ស័យឬចោទសួរទៅលើនិន្នាការផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រទេ ហើយយើងត្រូវការមានការស្រាវជ្រាវបន្ថែមទៀតទៅលើការទទួលយកអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងពុទ្ធសាសនាថេរវាទក្នុងតំបន់អាស៊ីអាគ្នេយ៍ (របកគំហើញតាមទិន្នន័យប្រមូលបានដែលបានបង្ហាញពីមុននៅក្នុងរបាយការណ៍នេះ បង្ហាញថាមានយោបល់ផ្សេងៗគ្នាក្នុងចំណោមគ្រហស្ថនិង "បព្វជិត" នៅក្នុងផ្នែកនេះ ប៉ុន្តែការដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ទស្សនៈភាគច្រើនទាក់ទងនឹងការទទួលយកនិងការសន្តោសប្រណី)។ Higgins បានសង្ខេបអំពីសីលទីបីអំពីការវៀរចាកការប្រព្រឹត្តខុសក្នុងកាមថា៖

> សីលប្រាំបង្កើតបានជាបណ្តុំមួយដែលមានការបញ្ចូលគ្នាដែលសីលនីមួយៗគាំទ្រទៅលើសីលផ្សេងទៀត។ ដើម្បីដឹងថា "ការប្រព្រឹត្តខុសក្នុងកាម" មានន័យដូចម្តេចយើងត្រូវមើលទៅលើសីលផ្សេងទៀត។ តាមស្មារតីនៃសីលនេះ "ការប្រព្រឹត្តខុសក្នុងកាម" មានន័យថាការប្រព្រឹត្តអំពើផ្លូវភេទណាមួយដែលទាក់ទងនឹងអំពើហិង្សាការបញ្ឆោត ឬការបោកប្រាស់គឺទង្វើដែលនាំឲ្យមានការឈឺចាប់និងបញ្ហា។ ផ្ទុយមកវិញការប្រព្រឹត្តល្អក្នុងកាមផ្អែកទៅលើមេត្តាធម៌ សប្បុរសធម៌ ភាពស្មោះត្រង់ និងសេចក្តីជ្រះថ្លាក្នុងចិត្តនិងក្នុងអារម្មណ៍ គឺទង្វើដែលទទួលបានលទ្ធផលល្អ[៦០]។

ផ្នែកដែលអវត្តមានពីការសង្ខេបខាងលើនេះ គឺកម្រិតនៃភាពអនុញ្ញាតបានចំពោះការរួមភេទមុនរៀបការនិងក្រៅចំណងអាពាហ៍ពិពាហ៍ ដែលមានការជាប់ទាក់ទងខ្លាំងនៅក្នុងប្រទេសដូចជាកម្ពុជា ដែលបទដ្ឋានទាំងនេះ នៅតែមានឥទ្ធិពល។ ជាថ្មីម្តងទៀត យើងត្រូវការមានការស្រាវជ្រាវបន្ថែមទៀតទៅលើចំណុចនេះ។

៥៧7] Suwanbubbha (n ៥៤).
[៥៨] BBC, 'ពុទ្ធសាសនានិងការពន្យារកំណើត', BBC (អនឡាញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩) <https://bbc.in/34hUX67>.
[៥៩] Suwanbubbha (n ៥៤).

# ៦.២ សិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជ៖ ទស្សនៈចេញពីអ្នកតបសម្ភាស

បន្ទាប់ពីបានពិនិត្យពិច័យទៅលើការស្រាវជ្រាវដ៏តិចតួចដែលបានប្រាប់យើងអំពីពុទ្ធសាសនានិងសិទ្ធិផ្លូវភេទនិងបន្តពូជក្នុងបរិបទអាស៊ីអាគ្នេយ៍រួចមក យើងបន្តទៅពិនិត្យលើរបកគំហើញដែលចេញមកពីទិន្នន័យប្រមូលបានជាផ្នែកមួយនៃការស្រាវជ្រាវនេះ។ គួរកត់សម្គាល់ជាថ្មីម្តងទៀតថាអ្វីដែលយើងចង់ឈ្វេងយល់មិនមែនថាទង្វើមួយណាដែលចាត់ទុកថា "ត្រូវ" ឬ "ខុស" តាមន័យបច្ចេកទេសទេ ឧទាហរណ៍ដូចជាអត្ថបទគម្ពីរឡើយ ប៉ុន្តែផ្ទុយទៅវិញយើងចង់ឈ្វេងយល់ថា៖ តើអ្នកកាន់ពុទ្ធសាសនានៅកម្ពុជាយល់ឃើញយ៉ាងដូចម្តេចក្នុងការចាត់ថាត្រូវ និង ខុស ក្នុងប្រពៃណីសាសនានោះ?

## ការរំលូតកូន៖

ដូចនៅក្នុងផ្នែកមុនៗដែរការឆ្លើយតបដោយអ្នកចូលរួមបានផ្តល់យោបល់និងជំហរផ្សេងៗទៅលើបញ្ហាទាំងនេះ។ ក៏ប៉ុន្តែចំណុចដែលមានការព្រមព្រៀងគ្នាស្ទើរទាំងស្រុងនោះ គឺទៅលើសំណួរអំពីការរំលូតកូន។ អ្នកចូលរួមនីមួយៗដែលត្រូវបានសម្ភាសឬស្ទង់មតិ និងបានឆ្លើយសំណួរទៅលើប្រធានបទនេះ (ក្រៅពីអ្នកតបសម្ភាសជាអ្នកស្រ្តីនិយមចំនួនពីរនាក់) ផ្តល់ការយល់ឃើញថាព្រះពុទ្ធសាសនា ចាត់ទុកការរំលូតកូនជាការប្រព្រឹត្តខុសសីលធម៌។ អ្នកតបសម្ភាសជាគ្រហស្ថម្នាក់បានសង្ខេបថា៖ "ព្រះពុទ្ធសាសនាហាមឃាត់ការរំលូតកូនដោយសារតែការបង្រៀនអំពីការវៀរចាកការសម្លាប់ជីវិត។"

អ្នកតបសម្ភាសជាគ្រហស្ថម្នាក់ទៀតបានឆ្លុះបញ្ចាំងថាគំនិតដែលបានពន្យល់ដោយសុវណ្ណបុប្ផា៖ កម្រិតដែលការរំលូតកូនត្រូវទទួលកម្មពៀរនេះអាចជះផលកម្មដោយសារតែសភាពនៃចេតនារបស់បុគ្គលដែលប្រព្រឹត្តនោះ៖ "ប្រសិនបើពួកគេធ្វេសប្រហែសឬមានចេតនាធ្វើឲ្យរលូតកូននោះវាជាទង្វើប្រឆាំងនឹងការបង្រៀនអំពីការមិនសម្លាប់ជីវិតនិងសិទ្ធិរស់រានមានជីវិតរបស់កុមារ។" អ្នកតបសម្ភាសដដែលបានលើកឡើងអំពីករណីលើកលែងនៅពេលដែលជីវិតរបស់ម្តាយទារកនោះកំពុងមានហានិភ័យដោយសារតែការមានគភ៌នោះ៖ "នៅក្នុងករណីដែលជាជម្រើសដើម្បីសង្គ្រោះជីវិតរបស់ម្តាយ ខ្ញុំគិតថាព្រះពុទ្ធសាសនាមិនបាននិងមិនអាចហាមឃាត់ទេ។ វាជាជម្រើសរបស់បុគ្គល។

ព្រះសង្ឃមួយអង្គងចំណោម១២អង្គមានដីកាថាព្រះពុទ្ធសាសនា ជាទូទៅមិនអនុញ្ញាតឲ្យមានការរំលូតកូនទេ។ ព្រះសង្ឃមួយអង្គបានពន្យល់តាមហេតុផលដូចខាងក្រោម៖

> "ព្រះពុទ្ធសាសនាហាមឃាត់ការរំលូតកូន ពីព្រោះវាមានន័យថាជាការសម្លាប់ជីវិត។ ប្រសិនបើអ្នកណាម្នាក់រំលូតកូន [ទារកក្នុងផ្ទៃ/គភ៌នោះ] នឹងកើតទៅជាប្រេត។ ប៉ុន្តែពុទ្ធសាសនាមិនហាមឃាត់ការពន្យារកំណើតទេពីព្រោះមិនទាន់មានការកើតជាជីវិតនៅឡើយ។"

របកគំហើញគួរឲ្យចាប់អារម្មណ៍ដែលបានលើកឡើងដោយអ្នកតបសម្ភាសជាគ្រហស្ថនិងបព្វជិតជាច្រើនគឺថាកម្មពៀរមិនត្រឹមតែកើតមានដល់ស្ត្រីមានផ្ទៃពោះទេ វាថែមទាំងកើតមានដល់គ្រូពេទ្យនិងអ្នកអនុវត្តដែលមានការជាប់ទាក់ទងផ្សេងទៀតដល់ប្ដីដែរ ប្រសិនបើគាត់យល់ព្រមឬជំរុញឲ្យមានការរំលូតកូន និងកើតមានដល់សូម្បីតែអ្នកផ្សេងទៀតដែលគាំទ្រទង្វើនេះ។ យាយជីម្នាក់ពន្យល់គំនិតនេះដោយលម្អិតថា៖

> ... បុគ្គលដែលគាំទ្រស្ត្រីឲ្យរំលូតកូនមិនមែនជាអ្នកកាន់ពុទ្ធសាសនាដែលល្អទេពីព្រោះពួកគេកំពុងចូលរួមចំណែកក្នុងការសម្លាប់ជីវិត ឬ គាំទ្រអ្នកសម្លាប់។

ព្រះសង្ឃមួយអង្គគាំទ្រដល់គំនិតអំពីកម្មផលនេះនិងអំពីលទ្ធភាពនៃការដាក់ទណ្ឌកម្មរួមដោយផ្អែកទៅលើសកម្មភាពរួមចំណែកដោយបុគ្គលផ្សេងៗគ្នានេះថា៖

> ការរំលូតកូនជាអំពើបាបដោយសារតែការសម្លាប់ជីវិត។ ព្រះសង្ឃនឹងមិនដាក់ទណ្ឌកម្មទៅលើស្ត្រីនិងគ្រួសាររបស់ស្ត្រីទេ ប៉ុន្តែពួកគេនឹងទទួលកម្មពៀរដែលខ្លួនបានសាង។ មិនមាននរណាម្នាក់ដឹងថាកម្មពៀរបែបណាដែលពួកគេនឹងទទួលនោះទេ ពីព្រោះវាអាស្រ័យទៅលើចេតនានៃបុគ្គលនោះ។ ប្រសិនបើប្ដីជាអ្នកបង្ខំឲ្យស្ត្រីសម្លាប់កូន ប្ដីនោះនឹងទទួលកម្មពៀរធ្ងន់ធ្ងរជាងគេ។ ប្រសិនបើស្ត្រីនោះ មានចេតនាសម្លាប់កូន នោះនាងនឹងមានបាប។

អ្នកអានមកពីបរិបទបស្ចិមប្រទេសអាចនឹងចាប់អារម្មណ៍នឹងគំនិតនេះដោយសារតែភាពអាម៉ាសនិងការមាក់ងាយសង្គមទាក់ទងនឹងការរំលូតកូនជារឿយៗមានតិចតួចទៅលើបុរសជាដៃគូនៅក្នុងបរិបទបស្ចិមប្រទេស។ ក៏ប៉ុន្តែរបកគំហើញក្នុងការស្រាវជ្រាវនេះហាក់ដូចជាឆ្លុះបញ្ចាំងថានៅក្នុងបរិបទប្រទេសកម្ពុជាដូចព្រះសង្ឃមួយអង្គមានដីកាថា “ប្រសិនបើការសម្រេចរំលូតកូនជាការសម្រេចចិត្តរួមគ្នារវាងប្ដីនិងប្រពន្ធនោះ **ទាំងពីរនាក់នឹងទទួលកម្មពៀរអាក្រក់ស្មើគ្នា។”**

អ្នកតបសម្ភាសជាអ្នកស្ត្រីនិយមម្នាក់ឆ្លុះបញ្ចាំងថាជំនឿដែលថាការរំលូតកូននាំមកនូវទណ្ឌកម្មកម្មពៀរ និងមានភាពរីកសាយភាយនោះថាការអនុវត្តបែបនេះកើតមានយ៉ាងសាមញ្ញថា៖ “តាមទស្សនៈយល់ឃើញអំពីការអនុវត្តជាក់ស្តែងជាពិសេសបុគ្គលដែលខ្ញុំស្គាល់ផ្ទាល់នោះ ការរំលូតកូនមិនមែនជាបញ្ហាអ្វីទេ។ ប៉ុន្តែពួកគេនៅតែជឿថាជាការសម្លាប់ជីវិត។ ហើយនៅពេលដែលជួបរឿងអវិជ្ជមាននោះជាកម្មពៀររបស់អ្នក។”

ចុងក្រោយអ្នកតបសម្ភាសជាអ្នកស្ត្រីនិយមម្នាក់បានឆ្លុះបញ្ចាំងអំពីការយល់ឃើញមួយដែលថាប្រហែលជាពុទ្ធសាសនាមិនជំទាស់នឹងការរំលូតកូនទេ ប៉ុន្តែផ្ទុយទៅវិញគឺបទដ្ឋានវប្បធម៌ទេដែលបានចូលទៅក្នុងការអនុវត្តរបស់សាសនាដែលគេយល់ច្រឡំថាជាទស្សនៈរបស់ព្រះពុទ្ធសាសនា៖ “ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនយល់ស្របថា ការហាមឃាត់ទាំងស្រុងទៅលើការរំលូតកូននេះ កើតចេញពីប្រពៃណីព្រះពុទ្ធសាសនាពិតប្រាកដនោះទេ។ វាអាចចេញមកពីវិធាននានាដែលបង្កើតឡើងតាមក្រោយទៅវិញទេ។”

> មិនមានការរឹតត្បិតទៅលើការពន្យារកំណើតនៅក្នុងពុទ្ធសាសនាទេ... ព្រះសង្ឃអាចជួយដល់ស្ត្រី តាមរយៈការជូនព័ត៌មានដល់ដៃគូវ័យក្មេង អំពីការធ្វើផែនការគ្រួសារ។
>
> អ្នកតបសម្ភាសជាព្រះសង្ឃ

## ការពន្យារកំណើត៖

ការយល់ឃើញថាតើមានការអនុញ្ញាតិឲ្យមានការពន្យារកំណើតឬអត់នោះមានលក្ខណៈលាយឡំចូលគ្នាជាងអំពីការរំលូតកូនបន្តិច ប៉ុន្តែជាទូទៅហាក់ដូចជាងាកទៅរកភាពវិជ្ជមាន។ ការដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថាអ្នកតបសម្ភាសជាគ្រហស្ថមួយចំនួនធ្វើការពិភាក្សាអំពីការពន្យារកំណើតនេះដោយប្រើប្រាស់ភាសាដែលផ្អែកទៅលើសិទ្ធិមនុស្សយ៉ាងច្បាស់៖

> "ព្រះពុទ្ធសាសនាមិនហាមឃាត់ការពន្យារកំណើតទេ។ វាជាបញ្ហាសង្គមនិងសេដ្ឋកិច្ចដែលគួរឲ្យមានការអនុញ្ញាតិពីព្រោះវាពាក់ព័ន្ធទៅនឹងសិទ្ធិសុខភាពរបស់បុគ្គល និងសេរីភាពរបស់ពួកគេ"។

ចំណុចសំខាន់ក្នុងពេលឆ្លើយតបអំពីកម្រិតនៃភាពអាចអនុញ្ញាតិបានសម្រាប់ការពន្យារកំណើតនៅក្នុងព្រះពុទ្ធសាសនាព្រះសង្ឃមួយអង្គមិនត្រឹមតែផ្តល់ដំបូន្មានថា "មិនមានការរឹតត្បិតលើការពន្យារកំណើតនៅក្នុងពុទ្ធសាសនានោះទេ" ប៉ុន្តែថែមទាំងស្នើឡើងថា "ព្រះសង្ឃអាចជួយដល់ស្ត្រីតាមរយៈការផ្តល់ព័ត៌មានអំពីការធ្វើផែនការគ្រួសារទៀតផង។" ព្រះសង្ឃជាន់ខ្ពស់មួយអង្គគាំទ្រដល់គំនិតនេះដោយមានដីកាឆ្លើយតបថា៖

> "មនុស្សគ្រប់រូបគួរចូលរួមក្នុងការផ្សព្វផ្សាយអំពីវិធីប្រើប្រាស់ការពន្យារកំណើតដែលមានសុវត្ថិភាពនិងប្រសិទ្ធភាពដែលជាការល្អប្រសើរជាងការលើកកម្ពស់ការរំលូតកូន។ ការពារប្រសើរជាងព្យាបាល។"

អ្នកតបសម្ភាសជាគ្រហស្ថវ័យចំណាស់ម្នាក់ បន្ថែម ការព្រមានដែលថា ការពន្យារកំណើត ត្រូវបានហាមឃាត់នៅពេលមានការពាក់ព័ន្ធក្នុងស្ថានភាពនៃការប្រព្រឹត្តមិនល្អក្នុងកាមសំដៅទៅដល់ "នៅពេលធ្វើអំពើអាក្រក់។" គំនិតអំពី "ការប្រព្រឹត្តមិនល្អក្នុងកាម" នៅក្នុងពុទ្ធសាសនាហាក់ដូចជាបានត្រៀមខ្លួនក្នុងការទទួលការបកស្រាយតាមបែបទំនើបជាងគំនិតអំពីការរំលូតកូន ហេតុដូច្នេះវាប្រហែលជាច្រកចូលមួយដែលអ្នកតស៊ូមតិអំពីសមភាពយេនឌ័រអាចរកឃើញថាមានភាពស្រេចបាច់ប្រសើរ នៅក្នុងផ្នែកនេះ។ ឧទាហរណ៍អ្នកចូលរួមជាគ្រហស្ថម្នាក់បានលើកឡើងថា "ពុទ្ធសាសានាមិនអនុញ្ញាតឲ្យមានការបៀតបៀនផ្លូវភេទ ឬបង្កការឈឺចាប់ផ្លូវភេទទៅលើអ្នកដទៃទេ ហើយខ្ញុំគាំទ្រចំណុចនេះ។"




## ការរួមភេទមុនការរៀបអាពាហ៍ពិពាហ៍និងក្រៅចំណងអាពាហ៍ពិពាហ៍

គំនិតអំពីការប្រព្រឹត្តមិនត្រូវក្នុងកាមសម្រាប់អ្នកតបសម្ភាសមួយចំនួនលាតសន្ធឹងដល់ការរួមភេទមុនអាពាហ៍ពិពាហ៍និងក្រៅចំណងអាពាហ៍ពិពាហ៍។ ការឆ្លើយតបទៅលើប្រធានបទនេះមានភាពខុសគ្នាច្រើន។ អ្នកខ្លះអះអាងថាពុទ្ធសាសនាហាមឃាត់ច្បាស់នូវការប្រព្រឹត្តបែបនេះចំណែកអ្នកផ្សេងទៀតអះអាងថាមានការអនុញ្ញាតប៉ុន្តែមិនត្រូវបានលើកទឹកចិត្តទេនិងអ្នកផ្សេងជាច្រើនទៀតមានអារម្មណ៍ថាវាស្ថិតនៅចំណុចកណ្តាលដូចមានការឆ្លើយតបពីអ្នកតបសម្ភាសជាគ្រហស្ថម្នាក់ថា៖

> “ពុទ្ធសាសនាមិនបានហាមឃាត់ច្បាស់អំពីការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍នោះទេ គឺវាជាបញ្ហាសម្រាប់បុគ្គល។ ប៉ុន្តែនៅពេលដែលយើងលាយបញ្ចូលគ្នារវាងបទដ្ឋានសង្គមជាមួយនិងពុទ្ធសាសនា នោះយើងឃើញថាការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ជាទង្វើអាក្រក់។”

អ្នកតបសម្ភាសជាគ្រហស្ថម្នាក់ ឆ្លុះបញ្ចាំងអំពីទ្វេស្តង់ដាររវាងបុរសនិងស្រ្តីដែលរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ថា៖ “បុរសភាគច្រើន រួមភេទជាមួយមនុស្សស្រី មុនពេលរៀបការ។ សម្រាប់បុរស មិនមានបញ្ហាអ្វីទេ ប៉ុន្តែ ប្រសិនបើស្រ្តីធ្វើដូចនេះវិញ មនុស្សម្នាបែរជានឹងនិយាយអវិជ្ជមានអំពីពួកគេទៅវិញ។” ប៉ុន្តែ អ្នកតបសម្ភាសជាអ្នកស្រ្តនិយមបានអះអាងថា វប្បធម៌ព្រហ្មចារីយ៍ស្ថិតនៅក្រៅការបង្រៀនរបស់ពុទ្ធសាសនា៖ “ខ្ញុំគិតថាវប្បធម៌ព្រហ្មចារីយ៍ មិនមែនជាបញ្ហារបស់ពុទ្ធសាសនាឡើយ។ ប្រាកដណាស់ថាមិនមែន។ វាគឺជាផ្នែកមួយនៃវិធាននិងប្រពៃណីដែលកើតមកនៅពេលក្រោយនោះទេ”។

ចុងក្រោយអ្នកតបសម្ភាសជាគ្រហស្ថមួយចំនួនស្នើឡើងថាការរួមភេទមុនរៀបការរវាងដៃគូជាប្រចាំត្រូវបានអនុញ្ញាត ប៉ុន្តែការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ដែលពាក់ព័ន្ធនឹងអ្នករៀបការរួចហើយ ត្រូវហាមឃាត់ជាដាច់ខាតដោយសារតែគេចាត់ទុកវាជាទង្វើផិតក្បត់អសីលធម៌ដែលឆ្លុះបញ្ចាំងអំពីចេតនាដែលអាចបង្កឲ្យមានការឈឺចាប់។ យាយជីក៏បានធ្វើការបែងចែកយ៉ាងរឹងមាំនៅក្នុងការពិភាក្សាជាក្រុមដែរថា៖

> ប្រសិនបើបុគ្គលម្នាក់នៅលីវពួកគេមានសេរីភាព។ ប៉ុន្តែប្រសិនបើបុរសមានគ្រួសារហើយក្បត់ប្រពន្ធបុរសនេះជាអ្នកខុសដោយផ្អែកតាមការបង្រៀនរបស់សាសនា។ បុរសទាំងនោះនឹងត្រូវទទួលរងទណ្ឌកម្មពីធម្មជាតិ តាមគោលការណ៍បុណ្យ-បាប និងតាមកម្មផល។

ដូច្នេះតាមរយៈទិន្នន័យនេះមានសំណើរមួយបានលេចឡើងថាការរួមភេទរវាងដៃគូមិនទាន់រៀបការ ត្រូវបានយល់ឃើញថា មានឆ្លុះបញ្ចាំងនៅក្នុងពុទ្ធសាសនាមានភាពធ្ងន់ធ្ងរតិចជាងអ្នកដែលបានរៀបការហើយទៅរួមភេទជាមួយអ្នកដទៃ។ ចំណុចនេះអាចមានជាប់ទាក់ទងនឹងអ្នកតស៊ូមតិផ្នែកសមភាពយេនឌ័រនៅក្នុងការងារលើកកម្ពស់ស្វ័យភាពផ្លូវភេទរបស់ស្ត្រី។ ក៏ប៉ុន្តែយើងត្រូវការការស្រាវជ្រាវបន្ថែមទៀត ដែលមានសំណាកធំជាងនេះដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើទំនោរច្បាស់មួយនេះមានភាពតំណាងឲ្យប្រជាជនទូទៅឬទេ។



# ៧ ការឆ្លុះបញ្ចាំងនិងអនុសាសន៍

## វិធីឆ្ពោះទៅបង្កើនកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងបុគ្គលស្ត្រីនិយមនិងពុទ្ធសាសនិកនៅកម្ពុជា

ប្រសិនបើយើងអាចចងចាំថា ខ្លឹមនៃព្រះពុទ្ធសាសនា... គឺជាភាពឥតខ្ចោះនៃសេចក្តីស្រលាញ់និងសេចក្តីករុណានោះ ... នោះហើយគឺជាគ្រាប់ពូជដែលអាចបណ្តុះដើម្បីព្យាបាលឫសនៃអំពើហិង្សាផ្អែកលើយេនឌ័រ និងទប់ស្កាត់វដ្តនៃអំពើហិង្សាមិនឱ្យកើតឡើងបន្តបាន។

KANUKOLLU & EPSTEIN-NGO ( ២០១៥).

Tsomo បានលើកទឡ្ហីករណ៍ថាជំនួសឲ្យការដាក់ការរិះគន់ទៅលើសាសនានិងស្ថាប័នសាសនានោះប្រហែលជាមានវិធីដែលមានប្រសិទ្ធភាពជាងនេះសម្រាប់អ្នកតស៊ូមតិផ្អែកយេនឌ័រគឺត្រូវសួរសំណួរប្រកបដោយសេចក្តីគោរព ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីទស្សនៈផ្សេងៗគ្នា និងដើម្បីបើកផ្លូវថ្មីៗខាងព្រះពុទ្ធសាសនាប្រកបដោយភាពប៉ិនប្រសប់ជាជាងការលើកឡើងនូវការគំរាមកំហែងប្រភេទណាមួយនោះ។ គាត់ស្នើឡើងថា៖

> "ដៃគូសន្ទនាភាគច្រើនមានការឆាប់រហ័សពេកក្នុងការទទួលស្គាល់ថា ប្រសិនបើការអនុវត្តរបស់ព្រះពុទ្ធសាសនាមានផលប្រយោជន៍សម្រាប់បុរសមែននោះ វាត្រូវតែផ្តល់ផលប្រយោជន៍ស្មើគ្នាសម្រាប់ស្ត្រីដែរ។ ហើយប្រសិនបើការបដិបត្តិពុទ្ធសាសនាមានផលប្រយោជន៍ណាមួយនោះស្ត្រីក៏សក្តិសមនឹងទទួលបានផលប្រយោជន៍ស្មើគ្នានោះដែរ។"[៦០]

ចំណុចនេះគាំទ្រគំនិតដែលបានពិភាក្សាខាងដើមក្នុងការស្រាវជ្រាវនេះដែលបានលើកឡើងដោយ Eisenbruch ថាដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រឱ្យបានជោគជ័យនៅក្នុងប្រទេសកម្ពុជា អ្នកតស៊ូមតិត្រូវតែរៀបចំបង្កើតអន្តរាគមន៍នានាដែលធ្វើការជាមួយនឹងប្រពៃណីនិងវប្បធម៌ ជាជាងគ្រាន់តែលេចឡើងនូវបញ្ហា។ សេចក្តីសន្និដ្ឋានជាចុងក្រោយរបស់ Eisenbruch គឺថា "ការធ្វើការជាមួយនឹងអ្នកអភិរក្សវប្បធម៌និងថ្នាក់ដឹកនាំសាសនានៅតាមមូលដ្ឋានមានសារៈសំខាន់ចាំបាច់ ដើម្បីធ្វើឱ្យមានការរីកចម្រើនដល់យុទ្ធសាស្ត្រដែលមានព័ត៌មានវប្បធម៌ដើម្បីទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ"[៦១] ។

នៅចុងបញ្ចប់នៃការសម្ភាសនិងការពិភាក្សាក្រុមនីមួយៗអ្នកចូលរួមត្រូវបានសួរឱ្យឆ្លុះបញ្ចាំងអំពីរបៀបដែលអ្នកស្ត្រីនិយមនិងអ្នកបដិបត្តិសាសនានៅក្នុងប្រទេសកម្ពុជាអាចធ្វើការជាមួយគ្នាឱ្យបានប្រសើរនិងកាន់តែជិតស្និទ្ធជាមួយគ្នាដើម្បីផ្តល់ផលប្រយោជន៍ដល់សង្គម។ ការឆ្លើយតបមានលក្ខណៈវិជ្ជមាននិងមានលក្ខណៈស្ថាបនាខ្លាំងមែនទែនដោយមានអ្នកចូលរួមជាច្រើនបង្ហាញអំពីភាពបើកចំហក្នុងការចូលរួមពាក់ព័ន្ធដោយផ្ទាល់នៅក្នុងគម្រោងគំនិតផ្តួចផ្តើមណាមួយនោះ។ សេចក្តីសង្ខេបនៃការឆ្លើយតបដែលក្តោបបាននូវគំនិតមួយចំនួនត្រូវបានរៀបរាប់ដូចខាងក្រោមនេះ

1. លើកទឹកចិត្តឱ្យមានការដាក់បញ្ចូលការអនុវត្តនិងបញ្ញត្តិពុទ្ធសាសនាដែលមានសភាពវិជ្ជមាន ទៅក្នុងទំលាប់ប្រចាំថ្ងៃរបស់អ្នកតស៊ូមតិយេនឌ័រ

> គំនិតព្រះពុទ្ធសាសនាមួយចំនួនអំពីការធ្វើចិត្តស្ងប់ ការប្រើប្រាស់សតិ និងការតម្កល់ចិត្តក្នុងគ្រាបច្ចុប្បន្ន... ខ្ញុំមានអារម្មណ៍ថាទាំងនេះគឺជាប្រភេទនៃកិច្ចមួយចំនួនដែលក្នុងនាមជាបុគ្គលស្ត្រីនិយម
> ខ្ញុំពិតជាអាចក្រសោបយកបាន។ ពីព្រោះវាបានជួយខ្ញុំឱ្យមានភាពពិតប្រាកដចំពោះខ្លួនឯង។ ការអនុវត្តពុទ្ធសាសនាដែលជាប់ទាក់ទងអាចជួយយើងឱ្យរស់នៅក្នុងជីវិតមួយកាន់តែប្រសើរ។
>
> - អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយម។

[៦០] Tsomo (n 12).
[៦១] Eisenbruch (n 46).

> ប្រសិនបើព្រះសង្ឃចូលរួមនិងសម្តែងអំពីបញ្ញត្តិស្ត្រីនិយមនិងពុទ្ធសាសនា តើនឹងមានរឿងអ្វីកើតឡើង? វានឹងក្លាយជារឿងមួយដែលមានអានុភាពខ្លាំងមែនទែនហើយវាអាចនឹងមានសក្តានុពលធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើន។
>
> **អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយម។**

## 2. ឱកាសក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមកតាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងព្រះសង្ឃនិងអ្នកតស៊ូមតិយេនឌ័រ

មានកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងព្រះសង្ឃនិងអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែយើងមិនបានធ្វើការច្រើនទៅលើបញ្ហាស្ត្រីទេ ដោយសារតែជារឿយៗព្រះសង្ឃមិនសូវមានឱកាសក្នុងការទទួលបានការអប់រំពីបញ្ហាទាំងអស់នេះទេ។ ខ្ញុំគិតថាគួរតែមានការលើកកម្ពស់ការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធជាមួយនឹងអំពើហិង្សាក្នុងគ្រួសារដើម្បីឱ្យមនុស្សលែងមានការស្អប់គ្នាទៅវិញទៅមក។ - អ្នកឆ្លើយតបជាព្រះសង្ឃ។

ខ្ញុំគិតថាយើងអាចទៅជួបព្រះសង្ឃមួយចំនួនដែលមានកេរ្តិ៍ឈ្មោះដែលមានការទទួលស្គាល់ថាមានគំនិតរីកចម្រើនចំពោះបញ្ហានេះ។ ហើយយើងអាចរៀនសូត្រពីព្រះសង្ឃទាំងនេះអំពីគោលការណ៍ពុទ្ធសាសនាពិតប្រាកដហើយប្រហែលជាយើងអាចពិភាក្សាអំពីវិធីធ្វើឱ្យមានការចូលរួមជាមួយគ្នា។ ប្រហែលជាព្រះសង្ឃទាំងនេះអាចគាំទ្រយើងហើយដើរតួជាជើងឯក។ ព្រះអង្គអាចនឹងមានដីកាអំពីរឿងនេះហើយព្យាយាមធ្វើការពន្យល់លម្អិតអំពីឧបសគ្គ ឬ ឫសគល់នៃបញ្ហាដែលស្ត្រីប្រឈម។
- អ្នកតបសម្ភាសជាបុគ្គលស្ត្រីនិយម។

## 3. បុគ្គលស្ត្រីនិយមអាចពិភាក្សាដោយក្តីគោរពអំពីបញ្ញត្តិសំខាន់ៗដែលពង្រឹងវិសមភាពយេនឌ័រ

មានពេលមួយយើងពិភាក្សាអំពីច្បាប់ស្រីក្នុងកម្មវិធីតាមវិទ្យុ។ ប៉ុន្តែយើងមិននិយាយថា "រឿងនេះអាក្រក់ អ្នកមិនគួរអនុវត្តទេ"។ យើងបានលើកយកបញ្ហានេះមកពិភាក្សា។ ឧទាហរណ៍គំនិតដែលថា "កុំនាំភ្លើងក្នុងចេញទៅក្រៅ"។ យើងបានសួរអ្នកស្តាប់ "តើវាមានន័យយ៉ាងដូចម្តេចនៅក្នុងការអនុវត្តជាក់ស្តែង? តើអ្វីជាផលប៉ះពាល់ដែលគំនិតទាំងអស់នេះមានទៅលើស្ត្រី?" នៅពេលដែលអ្នកនាំយកនូវគំនិតអំពីប្រពៃណីនិងវប្បធម៌មកពិភាក្សាជាសាធារណៈនោះ អ្នកត្រូវតែមានការប្រុងប្រយ័ត្ន។ វាជាការល្អបំផុតក្នុងការស្នើសុំមតិយោបល់ទស្សនៈគំនិតហើយគ្រាន់តែសួរជាសំណួរចំហប៉ុណ្ណោះ។ ប្រហែលជាពួកគេមិនយល់ស្របជាមួយយើងនៅពេលនោះភ្លាមទេប៉ុន្តែយើងអាចដាំគ្រាប់ពូជនោះបាន។ - អ្នកឆ្លើយតបជាអ្នកស្ត្រីនិយម។

## 4. លើកទឹកចិត្តឱ្យអ្នកបដិបត្តិពុទ្ធសាសនាដែលបញ្ចូលគោលការណ៍សមភាពយេនឌ័រទៅក្នុងការងារផ្សព្វផ្សាយជាសាធារណៈ

ខ្ញុំពិតជាឃើញមានសក្តានុពលពីការអនុវត្តបែបវប្បធម៌ប្រពៃណីទាំងអស់នោះ ដោយរួមបញ្ចូលទាំងពុទ្ធសាសនាដែរនៅក្នុងការដែលអាចប្រើជាឧបករណ៍ដ៏មានអានុភាពនិងសម្រាប់ធ្វើឱ្យមានការផ្លាស់ប្តូរ។ ប្រសិនបើព្រះសង្ឃចូលរួមនិងសម្តែងអំពីបញ្ញត្តិស្ត្រីនិយមនិងពុទ្ធសាសនាតើនឹងមានរឿងអ្វីកើតឡើង? វានឹងក្លាយជារឿងមួយដែលអនុភាពខ្លាំងមែនទែនហើយវាអាចនឹងមានសក្តានុពលធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើន។ - អ្នកតបសម្ភាសជាស្ត្រីនិយម។

ព្រះសង្ឃគួររៀបចំវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាអំពើហិង្សាការរើសអើងយេនឌ័រនិងបញ្ហាសង្គមផ្សេងៗទៀត។
- អ្នកតបសម្ភាសជាព្រះសង្ឃ។

ព្រះសង្ឃគួរអប់រំនៅក្នុងសាលារៀននិងសហគមន៍អំពីការជៀសវាងការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារក្នុងគោលបំណងដើម្បីផ្លាស់ប្តូរការយល់ឃើញរបស់មនុស្ស។ - អ្នកតបសម្ភាសជាយាយជី។



# ៨ សេចក្តីសន្និដ្ឋាន និង សេចក្តីសង្ខេបរបកគំហើញ

> ថ្វីត្បិតតែចំណុចមួយចំនួនមានភាពតានតឹងនឹងគ្នាក៏ដោយក្តី... ក៏របកគំហើញនៃការស្រាវជ្រាវនេះបានចង្អុលបង្ហាញដល់យើងថាលទ្ធិស្ត្រីនិយមនិងព្រះពុទ្ធសាសនាក្នុងបរិបទកម្ពុជាមានភាពស្របគ្នាសម្រាប់ការបំពេញបន្ថែមឲ្យគ្នាជាគ្រឹះសំខាន់ច្រើន

## របកគំហើញសំខាន់ៗ៖

យើងធ្វើសេចក្តីសន្និដ្ឋានទៅលើរបាយការណ៍នេះ ដោយផ្តល់ការសង្ខេបរបកគំហើញនិងចំណុចសំខាន់ៗដែលការឆ្លើយតបបានចង្អុលបង្ហាញអំពីតម្រូវការសម្រាប់ការស្រាវជ្រាវបន្ថែម។ ក៏ប៉ុន្តែយើងអាចចាប់ផ្តើមដោយសង្កត់ធ្ងន់ថាថ្វីត្បិតតែមានចំណុចមួយចំនួនមានការតានតឹងនឹងគ្នាដូចជាអំពីកម្រិតនៃភាពអាចអនុញ្ញាតិបានក៏ដោយក្តី **ក៏របកគំហើញនៃការសិក្សាស្រាវជ្រាវនេះបានចង្អុលបង្ហាញដល់យើងថាស្ត្រីនិយមនិងពុទ្ធសាសនាក្នុងបរិបទប្រទេសកម្ពុជា ពិតជាមានភាពស្របគ្នាសម្រាប់ការបំពេញបន្ថែមឲ្យគ្នាជាគ្រឹះសំខាន់ៗច្រើន។**

ឧទាហរណ៍ **គំនិតជាគ្រឹះសំខាន់ដូចជាសមភាពយេនឌ័រ យុត្តិធម៌សង្គម ភាពបរិសុទ្ធនៃចេតនា និងការប្រព្រឹត្តិមិនបង្កការឈឺចាប់លើអ្នកដទៃដែលមានជាប់មកជាមួយស្រាប់អាចចាត់ទុកជាបញ្ញត្តិកាត់ទទឹងដែលមានភាពរួចជាស្រេចច្រើន រវាងប្រព័ន្ធទាំងពីរ។** ប្រការនេះផ្តល់លក្ខខណ្ឌល្អនៃស្ថានភាពដូចគ្នាដ៏ល្អមួយដែលអ្នកស្ត្រីនិយម អ្នកបដិបត្តិសាសនា និងជននៅចន្លោះនេះអាចរួមគ្នាដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់កិច្ចសហការគ្នាដែលអាចទៅរួច ដោយរួមបញ្ចូលទាំងឱកាសរៀនសូត្រ និងសូម្បីធ្វើការតស៊ូមតិរួមគ្នានិងគម្រោងផ្តួចផ្តើមសម្រាប់ការអប់រំសហគមន៍។

### របកគំហើញផ្សេងទៀតចេញពីការស្រាវជ្រាវនេះរួមមានដូចខាងក្រោម៖

1. ហាក់បីដូចជាមានការបើកចំហច្រើនពីបព្វជិតសាសនាក្នុងការសហការណ៍ជាមួយអ្នកតស៊ូមតិផ្នែកយេនឌ័រដើម្បីកាត់បន្ថយអំពើហិង្សានៅក្នុងសហគមន៍ និងដើម្បីបង្រៀនប្រជាជនអំពីគោលការណ៍សមភាពយេនឌ័រដែលពួកគេជឿថាមានស្រាប់ក្នុងការអប់រំបែបព្រះពុទ្ធសាសនា។

2. ខណៈពេលដែលពុទ្ធបរិស័ទ្ធជាគ្រហស្ថជាច្រើន ដូចជាតាជីនិងយាយជី មានតួនាទីកំណត់ជាក់លាក់នោះ ព្រះសង្ឃមានដីកាថាតួនាទីទាំងអស់នេះមិនបានកំណត់ជាក់លាក់នោះទេ ហើយថា**ឧបសគ្គដែលរារាំងយាយជីមិនឲ្យធ្វើការងារសំខាន់ៗនោះ គឺដោយសារតែកត្តាវប្បធម៌ ជាជាងការកំណត់ក្នុងសាសនា។** ចំណុចនេះជាការបង្ហាញនូវឱកាសក្នុងការលើកទឹកចិត្តដល់យាយជីឱ្យចាប់យកតួនាទីសំខាន់ៗបន្ថែមទៀតនៅក្នុងវត្តនិងសម្រាប់តាជីក្នុងការរួមចំណែកធ្វើការងារបោសសម្អាតនិងការងារចម្អិនអាហារ។

> អ្នកចូលរួមជាច្រើនមានអារម្មណ៍ថាវាអាចទៅរួចដែលបុគ្គលម្នាក់មិនត្រឹមតែជាអ្នកតស៊ូមតិដើម្បីសមភាពយេនឌ័រប៉ុណ្ណោះទេ ថែមទាំងជាអ្នកដែលបដិបត្តិតាមព្រះពុទ្ធសាសនាផងដែរ ពួកគេថែមទាំងមានអារម្មណ៍ថាព្រះពុទ្ធសាសនាផ្ទាល់បានលើកកម្ពស់សមភាពយេនឌ័រស្រាប់ហើយ។

3 អ្នកចូលរួមជាច្រើនមានអារម្មណ៍ថាបុគ្គលម្នាក់មានលទ្ធភាពមិនត្រឹមតែជាអ្នកជឿនិងតស៊ូមតិដើម្បីសមភាពយេនឌ័រ ខណៈកំពុងតែបដិបត្តិព្រះពុទ្ធសាសនានោះទេ ពួកគេថែមទាំងមានអារម្មណ៍ថា **ព្រះពុទ្ធសាសនាផ្ទាល់បានលើកកម្ពស់សមភាពយេនឌ័រស្រាប់ហើយ**។ អ្នកឆ្លើយតបច្រើនជាង ២/៣ (៦៨%) មានអារម្មណ៍ថាព្រះពុទ្ធសាសនាចាត់ទុកស្ត្រី និងបុរសមានភាពស្មើគ្នាពីកំណើត។

4 ទិន្នន័យមិនឆ្លុះបញ្ចាំងការជំទាស់ផ្នែកមនោគមវិជ្ជាពីពុទ្ធបរិស័ទ្ធ ឬព្រះសង្ឃចំពោះគំនិតដែលថា**ស្ត្រីអាចបំបួសជាព្រះសង្ឃនោះទេ**។ ការពន្យល់អំពីការមិនអាចបំបួសស្ត្រីបាននោះគឺស្ថិតនៅត្រង់បញ្ហាបច្ចេកទេស (ការខ្វះខាតភិក្ខុនី ដើម្បីបំបួសភិក្ខុនីជំនាន់ក្រោយ) ព្រមទាំងបញ្ហាជាក់ស្តែង (ភិក្ខុនី និងភិក្ខុ មិនអាចស្នាក់នៅជិតគ្នាបានដើម្បីរក្សាភាពបរិសុទ្ធនៃចិត្ត និងការតមមិនរួមភេទ)។ អ្នកតបសម្ភាសនៅក្នុងការសិក្សានេះមិនបានសំដៅដល់គំនិតដែលថាស្ត្រីគ្មានភាពសក្តិសមពីកំណើតដើម្បីទទួលបានការបំបួសនៅក្នុងពុទ្ធសាសនានោះទេ។

5 អ្នកតបសម្ភាសដែលជាបុគ្គលស្ត្រីនិយមទាំងអស់នៅក្នុងការស្រាវជ្រាវនេះបានបង្ហាញអំពីកម្រិតនៃភាពមិនស្រួលក្នុងចិត្ត ឬការមិនយល់ស្របមួយចំនួន ជាមួយនឹងការរឹតត្បិតយេនឌ័រក្នុងពេលបច្ចុប្បន្ននៅក្នុងស្ថាប័នសាសនា។ ក៏ប៉ុន្តែ បុគ្គលស្ត្រីនិយមដែលតបសម្ភាសភាគច្រើន (៥/៦) បានសម្តែងមតិថាពួកគេមានអារម្មណ៍ថាអាច**ប្រើពាក្យសម្គាល់ “អ្នកតស៊ូមតិផ្នែកយេនឌ័រ/ស្ត្រីនិយម” និង “ពុទ្ធសាសនិក” ក្នុងពេលជាមួយគ្នាតែមួយបាន**។

6 ទោះបីជា**ការរំលូតកូនត្រូវបានយល់ឃើញស្ទើរតែជាឯកច្ឆន្ទថាជាទង្វើដែលត្រូវបានហាមឃាត់នៅក្នុងពុទ្ធសាសនាក៏ដោយ**ក៏គំនិតអំពី “ការប្រព្រឹត្តមិនគប្បីផ្នែកផ្លូវភេទ” ហាក់បីដូចជាមានការប្រែប្រួលទៅតាមការបកស្រាយបែបជឿនលឿនមួយចំនួន។ ឧទាហរណ៍យោងតាមអ្នកចូលរួមជាគ្រហស្ថម្នាក់“ពុទ្ធសាសនាមិនអនុញ្ញាតឱ្យមានការបៀតបៀនផ្លូវភេទ ឬបង្ខការឈឺចាប់ផ្លូវភេទទៅលើអ្នកដទៃឡើយ”។ ចំណុចនេះចង្អុលបង្ហាញថា **អាចមានបព្វជិតសាសនា និងបុគ្គលស្ត្រីនិយមធ្វើការរួមគ្នាទាក់ទងនឹងរឿងរ៉ាវផ្លូវភេទ**។

7 ការយល់ឃើញអំពី**ការរួមភេទរវាងដៃគូដែលមិនទាន់រៀបការ** ហាក់មិនសូវរឹងត្អឹងដូចជារវាងដៃគូរដែលគ្មានភក្តីភាពចំពោះប្តីឬប្រពន្ធនោះទេ។ ចំណុចនេះអាចស្របជាមួយក្រុមអ្នកតស៊ូមតិសមភាពយេនឌ័រ នៅក្នុងការងារលើកកម្ពស់ស្វ័យភាពផ្លូវភេទរបស់ស្ត្រី។

8 ទិន្នន័យដែលប្រមូលបានពីក្នុងការស្រាវជ្រាវនេះមិនត្រឹមតែបង្ហាញថា **គ្មានការរឹតត្បិត** ទៅលើការពន្យារកំណើតនៅក្នុងពុទ្ធសាសនាកម្ពុជានោះទេក្នុងនោះក៏មានអ្នកតបសម្ភាសជាព្រះសង្ឃ២អង្គថែមទាំងបានស្នើឡើងថា **ព្រះសង្ឃអាចមានតួនាទីសកម្មនៅក្នុងការអប់រំសហគមន៍អំពីវិធីសាស្ត្ររៀបចំផែនការគ្រួសារទៀតផង**។

9

អ្នកតបសម្ភាសទាំងអស់**បានសម្តែងមតិគាំទ្រ ទៅលើការផ្សារភ្ជាប់ក្រុមអ្នកស្រលាញ់ភេទដូចគ្នាជាមួយនឹងព្រះពុទ្ធសាសនា**ទោះបីជាមួយចំនួនមានអារម្មណ៍ថាទង្វើផ្លូវភេទរវាងដៃគូប្រុសស្រលាញ់ប្រុសដូចគ្នាអាចជា “ទង្វើមិនគប្បីផ្នែកផ្លូវភេទ” តាមរយៈទស្សនៈពុទ្ធសាសនាក៏ដោយ។

១០ **អំពើហិង្សាលើស្ត្រីត្រូវបានមើលឃើញជាឯកច្ឆន្ទ**ក្នុងចំណោមអ្នកតបសម្ភាសទាំងអស់ថាជាការរំលោភបំពានទៅលើការបង្រៀនរបស់ពុទ្ធសាសនា។ ចំណុចនេះបង្ហាញនូវឱកាសដ៏មានសក្តានុពលមួយសម្រាប់អ្នកតស៊ូមតិផ្អែកយេនឌ័រក្នុងការដាក់បញ្ចូលទស្សនៈទាននៅក្នុងទស្សនៈអប់រំបែបព្រះពុទ្ធសាសនាដូចជាសិក្ខាបទផ្សេងៗដើម្បីអន្តរាគមន៍បញ្ចប់អំពើហិង្សាផ្អែកលើយែនឌ័រ។

## សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះពិនិត្យមើលទៅលើបញ្ហាគន្លឹះចំនួនពីរ៖

១ តើមានផ្នែកសំខាន់ៗអ្វីខ្លះដែលស្របគ្នានិងមានភាពតានតឹងរវាងព្រះពុទ្ធសាសនានិងលទ្ធិស្ត្រីនិយម ហើយតើចំណុចទាំងអស់នោះស្តែងឡើងដូចម្តេចនៅក្នុងបរិបទ សង្គមកម្ពុជា?

២ ចំពោះព្រះពុទ្ធសាសនាបែបស្ត្រីនិយមនិង/ឬស្ត្រីនិយមបែបពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា៖ តើអ្វីជាបញ្ហាប្រឈមនិងអ្វីជាឱកាសសំខាន់បំផុតសម្រាប់ការបង្កើនកិច្ចសហប្រតិបត្តិការ?

ការស្រាវជ្រាវនេះបានរកឃើញថាវិស័យជាច្រើននៃពុទ្ធសាសនាថេរវាទ ដែលអនុវត្តនៅកម្ពុជាមានភាពស្របគ្នាជាមួយនឹងគោលការណ៍ស្ត្រីនិយមច្បាស់ហើយ។ ឧទាហរណ៍គំនិតជាមូលដ្ឋានដែលជាប់មកជាមួយសាសនាដូចជា សមភាពយេនឌ័រ យុត្តិធម៌សង្គម ភាពបរិសុទ្ធនៃចេតនានិងទង្វើមិនបង្កការឈឺចាប់ចំពោះអ្នកដទៃនៅក្នុងព្រះពុទ្ធសាសនាអាចចាត់ទុកជាបញ្ញត្តិ កាត់ទទឹងរួចជាស្រេចសម្រាប់ប្រព័ន្ធទាំងពីរ។ ការស្រាវជ្រាវក៏បានរកឃើញថាវិស័យផ្សេងទៀតមានសក្តានុពលសម្រាប់ការបកស្រាយតាមបែបទំនើបនិងការអនុវត្តទៅលើបញ្ហាស្ត្រីនិយម ដូចជា “ការប្រព្រឹត្តិមិនត្រូវក្នុងកាម” សម្រាប់ការហាមឃាត់ការបៀតបៀនទីសាធារណៈជាដើម។

តាមការពង្រីកបន្ថែមមូលដ្ឋានគ្រឹះនេះគាំទ្រគំនិតទីពីរថ្វីត្បិតតែមានវិស័យមួយចំនួនមានភាពតានតឹងក៏ដោយ (ឧទាហរណ៍ ការរំលូតកូន) ក៏មានមូលដ្ឋានដូចគ្នាគ្រប់គ្រាន់សម្រាប់បុគ្គលស្ត្រីនិយមនិងពុទ្ធសាសនិក ឲ្យរួមគ្នាក្នុងការរៀបចំយុទ្ធសាស្ត្រសហការតាមដែលធ្វើទៅបាន។ ទាំងនេះរួមមានទាំងឱកាសរៀនសូត្រពីគ្នាទៅវិញទៅមកនិងអាចសូម្បីតែការធ្វើការតស៊ូមតិរួមគ្នានិងគំនិតផ្តួចផ្តើមអប់រំសហគមន៍។

សូម្បីតែបញ្ហាដូចជាការរំលូតកូនឬការរួមភេទមុនរៀបការ ក៏ឯកសារស្រាវជ្រាវមានស្រាប់និងទិន្នន័យដែលប្រមូលបាន ស្នើឡើងថាមានកម្រិតនៃវិសាលភាពនៃការបកស្រាយឡើងវិញតាមបែបទំនើបនៃក្រឹត្យក្រមនិងសិក្ខាបទនានា ដោយសារថាអ្វីដែលជាមូលដ្ឋានគ្រឹះពិតប្រាកដចំពោះការអនុវត្តពុទ្ធសាសនានោះ គឺលទ្ធិទ្រឹស្តីអំពី**ចេតនា** និង**មេត្តាធម៌**។ ក្នុងន័យនេះប្រហែលជាព្រះពុទ្ធសាសនានិងស្ត្រីនិយមនៅកម្ពុជាអាចត្រូវបានគេមើលឃើញថាមានវិធីជាច្រើនដែលជាការចាក់ “ទឹកចូលទៅក្នុងទឹក”។



# ឯកសារពិគ្រោះ


Adams, Nathaniel, ‘‘ចលនាដ៏ស្ងប់ស្ងៀមក្នុងប្រទេសកម្ពុជា៖ ស្ត្រីពុទ្ធសាសនិក ក្នុងការអភិវឌ្ឍន៍’, កិច្ចសន្ទនាដើម្បីការអភិវឌ្ឍសេចក្តីជំនឿពិភពលោក (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១១) <https://berkleycenter.georgetown.edu/posts/cambodia-s-quiet-movement-buddhist-women-in-development>

APWLD, ‘‘ការស្រាវជ្រាវប្រតិបត្តិចូលរួមបែបស្ត្រីនិយម (FPAR)’, APWLD < https://apwld.org/feminist-participatory-action-research-fpar/>

BBC, ‘ពុទ្ធសាសនា និង ការពន្យារកំណើត’, BBC (online, 23 November 2009) <https://www.bbc.co.uk/religion/religions/buddhism/buddhistethics/contraception.shtml#:~:text=Buddhism%20and%20contraception,-Buddhist%20attitudes%20to&text=The%20most%20common%20Buddhist%20view,and%20should%20not%20be%20used>

Brown, Judith S, ‘ទឹកអ្វី? ស្ត្រីនិយម, ពុទ្ធសាសនា Shambhala និងគោលការណ៍ស្ត្រីនិយម’ (2016) 3(1) The arrow: Buddhism & Feminism 22

Eisenbruch, Maurice, ‘អំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា៖ ចំពោះទ្រឹស្តីនៃការផ្លាស់ប្តូរដែលមានការឆ្លើយតបបែបវប្បធម៌’ (២០១៨) ៤២, វប្បធម៌, វេជ្ជសាស្ត្រ និងវិកលវិទ្យា ៣៥០។

Fulu, Emma et al, ហេតុអ្វីបានជាបុរសប្រើប្រាស់អំពើហិង្សាទៅលើស្ត្រី និងតើយើងអាចទប់ស្កាត់ដោយរបៀបណា? (Report, 978-974-680-360-1, ខែកញ្ញា ឆ្នាំ២០១៣) <https://www.undp.org/content/dam/rbap/docs/Research%20&%20Publications/womens_empowerment/RBAP-Gender-2013-P4P-VAW-Report.pdf>

Gayley, Holly, ‘តើយើងស្វែងរកស្ត្រីនិយមតាមបែបពុទ្ធសាសនា នៅកន្លែងណា?’, (ខែកញ្ញា ឆ្នាំ២០១៦) ៣(១) The Arrow៖ ពុទ្ធសាសនានិងស្ត្រីនិយម ១៤

Grace, Kelly and Sothy Eng, ‘មិនកន្លែងសម្រាប់ "ច្បាប់ស្រី" ក្នុងសាលារៀននៅកម្ពុជាទេ’, The Cambodia Daily (online, 09 June 2015) <https://english.cambodiadaily.com/news/%C2%ADthere-is-no-place-for-chbab-srey-in-cambodian-schools-85230/>

Higgins, Winton, ‘អភិសមាចារផ្លូវភេទ តាមបែបពុទ្ធសាសនា’, អត្ថបទក្នុងទស្សនាវដ្តី BuddhaNet (អត្ថបទ, n.d) <http://www.buddhanet.net/winton_s.htm>

Kanukollu, Shanta N and Quyen E Ngo, ‘‘អំពើហិង្សាលើស្ត្រីតាមរយៈទស្សនៈពុទ្ធសាសនា’ នៅក្នុង Andy J Johnson(ed), សាសនានិងអំពើហិង្សាបុរសទៅលើស្ត្រី (Springer Science Business Media New York, 2015) 343

Kent, Alexandra, ‘ជ្រកក្រោមព្រះធម៌៖ ឆ្លុះបញ្ចាំងទៅលើយេនឌ័រ សន្តិសុខ និងសាសនា ក្នុងប្រទេសកម្ពុជា’ (២០១១) ៤២(២) ព្រឹត្តិប័ត្រស្រាវជ្រាវអាស៊ីអាគ្នេយ៍ ១៩៣។

Keown, Damien, ‘ពុទ្ធសាសនា និង ការរំលូតកូន’ (10.1093/OBO/9780195393521-0198, 29 November 2017) <https://www.oxfordbibliographies.com/view/document/obo-9780195393521/obo-9780195393521-0198.xml>

Klunklin, Areewan and Jennifer Greenwood, ‘ពុទ្ធសាសនា, ឋានៈរបស់ស្ត្រីនិងការរីករាលដាលនៃជំងឺ/មេរោគអេដស៍ ក្នុងប្រទេសថៃ’ (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៦) ២៦(១) ការថែទាំសុខភាពសម្រាប់ស្ត្រីអន្តរជាតិ ៤៦។

គ្រី, ស៊ុយហៀង និងអ្នកផ្សេងទៀត, ‘រក្សាភាពសុខដុមរមានឬរារាំងយុត្តិធម៌?’ (របាយការណ៍, ខែតុលា ឆ្នាំ២០២០) <https://wpmcambodia.org/wp-content/uploads/2020/12/Preserving-Harmony-or-Preventing-Justice_EN_2020.pdf>

គន្ធា, មុំ ‘តារាស្រី រងការព្រមាន ដោយសារសម្លៀកបំពាក់សិចស៊ី’, ខ្មែរថែមស៍ (អនឡាញ, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨) <https://www.khmertimeskh.com/536090/actresses-warned-over-sexy-outfits/>

Lee, Susan H, ‘វិសមភាពមនោគមវិជ្ជា៖ វប្បធម៌ខ្មែរនិងការយល់ឃើញរបស់ស្ត្រីមេម៉ាយអំពីការរៀបការឡើងវិញ’ (ខែឧសភា ឆ្នាំ២០១៨) ១៩(៥) យេនឌ័រ, ភាពក្រីក្រ និងវិសមភាព៖ ការស្រាវជ្រាវស្វែងយល់ពីទស្សនៈដែលមានការផ្លាស់ប្តូរទាំងស្រុង នៃព្រឹត្តិបត្រស្រាវជ្រាវស្ត្រីអន្តរជាតិ ២៩

Leggerwood, Judy, ‘ការផ្លាស់ប្តូរការយល់ឃើញអំពីយេនឌ័ររបស់ជនជាតិខ្មែរ៖ ស្ត្រី, រឿងរ៉ាវ និងសណ្តាប់ធ្នាប់សង្គម’ (២០១១) ៤២(២) ជ្រកក្រោមព្រះធម៌៖ ការឆ្លុះបញ្ចាំងទៅលើយេនឌ័រ, សន្តិសុខ និងសាសនា ក្នុងប្រទេសកម្ពុជា នៃព្រឹត្តិបត្រស្រាវជ្រាវអាស៊ីអាគ្នេយ៍ ១៩៧

Millar, Paul, ‘សិទ្ធិស្ត្រី៖ ការបន់ស្រន់ឲ្យបានសមភាព’, Southeast Asia Globe (អនឡាញ, ថ្ងៃទី១០ មេសា ២០១៨) < https://southeastasiaglobe.com/praying-for-equality-cambodias-holy-women-battling-to-become-female-monks/>

Shotwell, Alexis, ‘ដូចចាក់ទឹកចូលក្នុងទឹក,” បើមានពុទ្ធសាសនា នោះនឹងមានស្ត្រីនិយម, ប៉ុន្តែ តើស្ត្រីនិយមប្រភេទអ្វី?’, (ខែកញ្ញា ឆ្នាំ២០១៦) ៣(១) The Arrow៖ ពុទ្ធសាសនានិងស្ត្រីនិយម ៤

Sumanbubbha, Parichart, ‘សិទ្ធិធ្វើផែនការគ្រួសារ, ការពន្យារកំណើតនិងការរំលូតកូន ក្នុងពុទ្ធសាសនាថៃ’ នៅក្នុង, Daniel C Maguire (ed), សិទ្ធិក្នុងសាសនា៖ ករណីការពន្យារកំណើតនិងការរំលូតកូន ក្នុងសាសនាសាកល (Oxford Scholarship Online, 2003) <https://oxford.universitypressscholarship.com/view/10.1093/acprof:oso/9780195160017.001.0001/acprof-9780195160017>

Tsomo, Karma L, ស្ត្រីពុទ្ធសាសនិកនិងយុត្តិធម៌សង្គម៖ ឧត្តមភាព ការប្រឈម និងសមិទ្ធផល (សាកលវិទ្យាល័យរដ្ឋញូយ៉ក, អាល់បានី, ២០០៤) ២។

ក្រសួងការបរទេសសហរដ្ឋអាមេរិច, នាយកដ្ឋានប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ, របាយការណ៍សេរីភាពសាសនាអន្តរជាតិ ឆ្នាំ២០១៨ សម្រាប់កម្ពុជា (របាយការណ៍, ២០១៨) ១, <https://www.state.gov/wp-content/uploads/2019/05/CAMBODIA-2018-INTERNATIONAL-RELIGIOUS-FREEDOM-REPORT.pdf>

Wight, Emily and Vandy Muong, ‘នយោបាយយេនឌ័រនៅក្នុងវត្តអារាម៖ សំឡេងស្ត្រីអំពាវនាវឲ្យមានការផ្លាស់ប្តូរ’, ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣) <https://www.phnompenhpost.com/7days/gender-politics-pagoda-female-voices-who-call-change>

អង្គការក្លាហាន ជាស្ថាប័នឯករាជ្យ និងប្រកាន់
គោលការណ៍ស្ត្រីនិយមបែបអន្តរវិស័យ មានបេសកកម្ម
បង្កើតបរិយាកាសសង្គមដែលស្ត្រីគ្រប់រូបអាចទទួលបាន
សមភាព យុត្តិធម៌ និងអាចប្រើប្រាស់
សក្តានុពលរបស់ខ្លួនពេញលេញ។

*www.klahaan.org*

សម្រាប់ព័ត៌មានបន្ថែម៖ rachana@klahaan.org